Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

ការពិភាក្សាលើវិស័យឯកជន
43931

លេខ ២៣

# រឿងក្តីអំពីការរំលោភលើសេចក្តីទុកចិត្ត

## ការអនុវត្តន៍ដោយមិនត្រឹមត្រូវ និងឥទ្ធិពល របស់វាមកលើសេដ្ឋកិច្ចកម្ពុជា



IFC
International Finance Corporation
World Bank Group
MPDF

# មាតិកា


សេចក្តីថ្លែងអំណរគុណ ៥
ខ្លឹមសារសង្ខេប ៩

ជំពូក ១: សេចក្តីផ្តើម ១៥
១. គោលបំណងនៃការសិក្សា ១៥
២. អ្វីទៅជាការរំលោភលើសេចក្តីទុកចិត្ត ១៥
៣. ហេតុអ្វីបានជាប្រទេសកម្ពុជាមានមាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្ត ១៦
៤. ហេតុដែលធ្វើអោយការអនុវត្តន៍មាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្ត ក្លាយទៅជាបញ្ហាចោទមួយ នៅក្នុងប្រទេសកម្ពុជា ១៧

ជំពូក ២: បទព្រហ្មទណ្ឌនៃការរំលោភលើសេចក្តីទុកចិត្ត ២១
១. ធាតុផ្សំរបស់បទព្រហ្មទណ្ឌនៃការរំលោភលើសេចក្តីទុកចិត្ត ២១
២. ធាតុផ្សំសំភារៈនៃការរំលោភសេចក្តីទុកចិត្ត ២៣
៣. ធាតុផ្សំផ្នែកសតិ - ចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ២៦
៤. ក្រមព្រហ្មទណ្ឌថ្មី ២៨

ជំពូក ៣: ការអនុវត្តន៍មិនត្រឹមត្រូវ នៃមាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្ត នៅក្នុងប្រទេសកម្ពុជា ៣១
១. ការអនុវត្តន៍មិនត្រឹមត្រូវនៃមាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្ត គឺជាបញ្ហាចោទមួយ ៣១
២. ការអនុវត្តន៍មិនត្រឹមត្រូវនៃមាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្ត: មូលហេតុ និងរបៀបប្រព្រឹត្តទៅរបស់វា ៣២

ជំពូក ៤: រឿងក្តីមិនត្រឹមត្រូវនៃការរំលោភលើសេចក្តីទុកចិត្ត ធ្វើអោយសេដ្ឋកិច្ចកម្ពុជាខាតបង់អស់រាប់លានដុល្លារ ៣៩

ជំពូក ៥: អនុសាសន៍ និងសេចក្តីសន្និដ្ឋាន ៤៥

ឧបសម្ព័ន្ធ ១ វិធីសាស្ត្រនៃការស្រាវជ្រាវ ៥១
ឧបសម្ព័ន្ធ ២ ករណីសិក្សា ៥៥
ឧបសម្ព័ន្ធ ៣ របាយការណ៍បានមកពីបណ្តាញផ្សាយព័ត៌មាន ៦៣
ឧបសម្ព័ន្ធ ៤ លទ្ធផលនៃការអង្កេត ៦៥
ឧបសម្ព័ន្ធ ៥ ការវិភាគបច្ចេកទេសផ្នែកច្បាប់ នៃមាត្រាស្តីអំពីការរំលោភលើសេចក្តីទុកចិត្ត ៦៩
ឧបសម្ព័ន្ធ ៦ ការវិភាគព័ត៌មានដែលទទួលបានមកពីក្រសួងយុត្តិធម៌ ៨៣
ឧបសម្ព័ន្ធ ៧ សេចក្តីណែនាំរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល ស្តីអំពីបទព្រហ្មទណ្ឌ នៃការរំលោភលើសេចក្តីទុកចិត្ត ៨៧

# សេចក្តីថ្លែងអំណរគុណ

*របាយការណ៍ពិភាក្សាលើវិស័យឯកជន* អំពីការអនុវត្តន៍មិនត្រឹមត្រូវនូវបញ្ញត្តិច្បាប់ស្តីអំពីការរំលោភលើសេចក្តីទុកចិត្ត នៃក្រមព្រហ្មទណ្ឌអន្តរកាលរបស់កម្ពុជា ត្រូវបានធ្វើឡើងដោយអនុគណៈកម្មាធិការពិសេសមួយ ដែលបានបង្កើតឡើងដោយក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនដែលមានឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោក Bretton G. Sciaroni នាយកគ្រប់គ្រងក្រុមហ៊ុន Sciaroni & Associates ដែលជាតំណាងផ្នែកឯកជន ជាសហប្រធាន។ សមាជិកអនុគណៈកម្មាធិការនេះ រួមមានតំណាងមកពីក្រសួងយុត្តិធម៌ សហគមន៍អាជីវកម្ម និងកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ នៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC MPDF)។

ទាំងឯកឧត្តម **គាត ឈន់** ទាំងលោក **Sciaroni** បានគាំទ្រយ៉ាងពេញទំហឹង និងបានផ្តល់ការណែនាំដ៏មានអត្ថប្រយោជន៍ជាច្រើនដល់អនុគណៈកម្មាធិការពិសេសនៅក្នុងដំណើរការនៃការរៀបចំរបាយការណ៍នេះ។ ការបន្តគាំទ្ររបស់ ឯកឧត្តម និងលោក Sciaroni បានធ្វើឱ្យការរៀបចំរបាយការណ៍នេះបញ្ចប់ទៅបានដោយជោគជ័យ។

*របាយការណ៍ពិភាក្សា* នេះបានធ្វើឡើង ដោយមានការជួយជ្រោមជ្រែងពីសំណាក់ ឯកឧត្តម លោក លោកស្រី ជាច្រើន ។ ក្នុងនោះ ឯកឧត្តម **ហ៊ី សោភា** រដ្ឋលេខាធិការ និងលោក **សឹង បញ្ញាវុឌ្ឍ** ប្រធាននាយកដ្ឋានកិច្ចការព្រះរាជអាជ្ញា មកពីក្រសួងយុត្តិធម៌ បានជួយសម្របសម្រួលការងាររបស់អនុគណៈកម្មាធិការពិសេស អោយបានសម្ភាសន៍ជាមួយតុលាការ និងក្នុងការទទួលបាននូវស្ថិតិអំពីករណីបណ្តឹងមកតុលាការនានា នៅក្នុងខេត្តចំនួនប្រាំ។ លោក **អេង ទូច** ប្រធានការិយាល័យ អភិវឌ្ឍន៍ផ្នែកឯកជន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលការងាររបស់ អនុគណៈកម្មាធិការពិសេសនេះ ជាមួយនឹងក្រសួងយុត្តិធម៌។

កញ្ញា **សេង ហ៊ុន** មកពីក្រុមហ៊ុន **Sciaroni & Associates** ជាតំណាងផ្នែកឯកជន បានចូលរួមយ៉ាងសកម្ម ក្នុងកិច្ចប្រជុំពិភាក្សាទៅលើសេចក្តីព្រាងនៃរបាយការណ៍នេះ ជាមួយក្រសួងយុត្តិធម៌។

លោក **James Brew** ដែលបានសម្របសម្រួល វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន រហូតដល់ខែ ធ្នូ ឆ្នាំ ២០០៧ នេះ បានជួយសម្របសម្រួលការពិភាក្សាជាមួយផ្នែកឯកជន តាមរយៈការចែកចាយសេចក្តីព្រាង នៃរបាយការណ៍នេះទៅឱ្យផ្នែកឯកជន និងសម្របសម្រួលក្នុងការទទួលត្រឡប់មកវិញនូវមតិយោបល់ពីផ្នែកឯកជន។ អាជីវករជាច្រើនបានចូលរួមក្នុងការងារនេះ ដោយសហការជាមួយក្រុមអ្នកស្រាវជ្រាវ តាមរយៈការផ្តល់បទសម្ភាសន៍ដោយផ្ទាល់ និងតាមរយៈការសរសេរឆ្លើយតបនឹងកំរងសំណួរអង្កេតនានា។

លោក **ហោ សុនាថ** មន្ត្រីអនុវត្តន៍គំរោង របស់ **IFC MPDF** ជាអ្នកទទួលខុសត្រូវរួមលើការសិក្សា និងចងក្រងរបាយការណ៍ដោយមានការណែនាំពី លោកស្រី **Trang Nguyen** និងលោក **Charles Schneider** ។ លោក **Stuart Ford** ជាអ្នកសរសេររបាយការណ៍នេះ ដោយមានការជួយជ្រោមជ្រែងយ៉ាងច្រើនពីលោក **Dugald Richards** និងកញ្ញា **Anita Surewics** ។

លោកស្រី **Ann Bishop** បានជួយពិនិត្យ និងកែសម្រួលពាក្យពេចន៍ក្នុងរបាយការណ៍នេះ។ លោក **គង់ វណ្ណារិទ្ធ** បានបកប្រែអត្ថបទជាភាសាខ្មែរ ដោយមាន លោក **ទុ ឃី** លោក **វស់ ខេមរា** និងលោក **អ៊ីង សុភាល័ក្ស** ជាអ្នកជួយកែសម្រួល។ លោក ស្រី **គា គន្ធា** ជាអ្នកទទួលខុសត្រូវលើការរៀបចំរបាយការណ៍ក្នុងកុំព្យូទ័រ។ លោកស្រី **តាន់ តូនី** បានផ្តល់ការគាំទ្រខាងផ្នែករដ្ឋបាល។

# ខ្លឹមសារសង្ខេប

## សេចក្តីផ្តើម

សមាគមន៏អាជីវកម្មបានបង្ហាញក្តីបារម្ភរបស់ពួកគេ អំពីបញ្ហាដែលមាត្រាស្តីអំពីការរំលោភលើសេចក្តីទុកចិត្ត នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ត្រូវបានប្រើប្រាស់មិនត្រឹមត្រូវ ធ្វើអោយមានការខាតបង់ដល់សមាគមន៏អាជីវិកម្ម និងសេដ្ឋកិច្ចកម្ពុជា។ នៅ ខែមករា ឆ្នាំ ២០០៦ ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្កើតអនុគណៈកម្មាធិការពិសេសមួយ ដើម្បី សិក្សាស្រាវ ជ្រាវ អំពីបញ្ហាទាំងឡាយ ទាក់ទងនឹងការរំលោភលើសេចក្តីទុកចិត្ត ព្រមទាំងចេញអនុសាសន៏នានា សម្រាប់បកស្រាយបំភ្លឺ និងកែលំអការអនុវត្តន៏ច្បាប់នេះ ។ របាយការណ៏នេះ គឺជាលទ្ធផលការងាររបស់អនុគណៈកម្មាធិការពិសេសនេះ និងបានចងក្រងឡើងដោយមានការប្រមូលព័តិមានពីការសម្ភាសន៏ជាមួយអ្នកដែលពាក់ព័ន្ធ ពីព័តិមានដែលមានជាសាធារណៈ និងពីកិច្ចសម្ភាសន៏ជាច្រើនជាមួយអាជីវកម្ម។ ការប្រើប្រាស់ និងការអនុវត្តន៏ មិនត្រឹមត្រូវនៃច្បាប់ស្តីអំពីការរំលោភលើសេចក្តីទុកចិត្ត អាចធ្វើអោយសេដ្ឋកិច្ចកម្ពុជាខាតបង់ទុនវិនិយោគ រាប់លានដុល្លារ ក្នុងមួយឆ្នាំៗ។ គេសង្ឃឹមថា អនុសាសន៏ដែលមានលើកឡើងក្នុងរបាយការណ៏នេះ នឹងរួមចំណែកជួយកាត់បន្ថយការខាតបង់ដល់សេដ្ឋកិច្ចកម្ពុជាយ៉ាងច្រើន ដែលបណ្តាលមកពីរឿងក្តីមិនត្រឹមត្រូវនៃការរំលោភលើសេចក្តីទុកចិត្តនេះ។

## ធាតុផ្សំនៃការរំលោភលើសេចក្តីទុកចិត្ត

ការរំលោភលើសេចក្តីទុកចិត្ត ជាបទល្មើសព្រហ្មទណ្ឌ ដែលបានចែងនៅក្នុងមាត្រាទី ៤៦ នៃ "បទបញ្ញត្តិ ស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យកាលអន្តរកាល" (ដែលបន្តទៅនេះ ហៅថា "ច្បាប់ព្រហ្មទណ្ឌអន្តរកាល")។ បទល្មើសនៃការរំលោភលើសេចក្តីទុកចិត្តអាចមានធាតុផ្សំសំភារៈសំខាន់ៗចំនួនបី និងធាតុផ្សំសតិចំនួនមួយ[១]។ ធាតុផ្សំសំភារៈសំខាន់ៗមានៈ

១. ទ្រព្យត្រូវតែបានគេទុកចិត្តប្រគល់ទៅអោយជនជាប់ចោទទទួលខុសត្រូវ

២. ជនជាប់ចោទត្រូវតែបានសន្យាថា នឹងសងទ្រព្យនោះទៅអោយម្ចាស់ដើមវិញ ឬមួយប្រើប្រាស់វាតាមគោលដៅមួយដែលបានកំណត់ជាក់លាក់ និង

៣. ជនជាប់ចោទត្រូវតែបានបំបាត់ ឬតែបន្លំទ្រព្យ តាមរយៈការបដិសេធមិនព្រមសង ឬមិនបានប្រើវា តាមគោលដៅដែលបានព្រមព្រៀងគ្នា។

---

១ ការវិភាគបច្ចេកទេសផ្នែកច្បាប់ អំពីបទល្មើសនៃការរំលោភលើសេចក្តីទុកចិត្តដោយ អ្នកច្បាប់កម្ពុជាដ៏ល្បី គឺលោក **កុយ នាម** មាននៅក្នុង ឧបសម្ព័ន្ធទី ៥

ចេតនាប្រព្រឹត្តបទល្មើស គឺជាធាតុផ្សំចាំបាច់នៃបទល្មើសនៃការរំលោភលើសេចក្តីទុកចិត្ត។ ជនជាប់ចោទ ត្រូវតែមានចេតនាធ្វើអំពើនេះ និងត្រូវតែដឹងថាអ្វីដែលគាត់ធ្វើជាអំពើខុស។ វាមិនអាចជាកំហុស ឬភាពធ្វេសប្រហែសមួយនោះទេ។

## រឿងក្តីរំលោភលើសេចក្តីទុកចិត្ត នៅប្រទេសកម្ពុជា

សហគមន៍អាជីវកម្មមានយោបល់ថា ការប្តឹងចោទពីបទរំលោភលើសេចក្តីទុកចិត្ត ត្រូវគេប្រើដោយមិនត្រឹមត្រូវ ក្នុងពេលមានវិវាទអាជីវកម្ម ដើម្បីបង្ខំមនុស្សអោយបង់ប្រាក់ទៅអ្នកដើមចោទ។ ពួកគេត្អូញត្អែរជាប្រចាំថា តុលាការមិនអើពើរ អំពីធាតុនានានៃច្បាប់ទេ ហើយបានចាត់ទុកវិវាទកិច្ចសន្យាសាមញ្ញៗ ថាជាការរំលោភលើសេចក្តីទុកចិត្ត។ ភាពស្មុគស្មាញ និងការចែងមិនច្បាស់លាស់នៃច្បាប់អាចរួមចំណែកបង្កឱ្យមានបញ្ហា ធ្វើអោយតុលាការចាត់ទុកវិវាទកិច្ចសន្យាសាមញ្ញៗ ថាជាករណីរំលោភលើសេចក្តីទុកចិត្ត។ យោងតាមន័យបច្ចេកទេស វិវាទកិច្ចសន្យាភាគច្រើន មិនអាចក្លាយទៅជាការប្តឹងចោទ ពីបទរំលោភលើសេចក្តីទុកចិត្តឡើយ ព្រោះមានតែវិវាទមួយចំនួនតូចប៉ុណ្ណោះ ដែលមានភាគីមួយទុកចិត្តប្រគល់ទ្រព្យអោយភាគីមួយទៀត ជាថ្នូរនឹងការសន្យាប្រគល់អ្វីមួយសងតបមកវិញ។

សហគមន៍អាជីវកម្មបាននិយាយថា ជារឿយៗ ការប្តឹងចោទពីបទរំលោភលើសេចក្តីទុកចិត្ត ត្រូវបានគេប្រើធ្វើជាឧបករណ៍តថ្លៃគ្នា ដើម្បីជំរុញអោយមានការដោះស្រាយបញ្ចប់វិវាទពាណិជ្ជកម្ម។ នៅពេលដែលការប្តឹងតាមរយៈនីតិវិធីរដ្ឋប្បវេណីដើម្បីទទួលបានប្រាក់ដែលគេជំពាក់មកវិញ មានភាពស្មុគស្មាញ និងត្រូវចំណាយអស់ពេលច្រើននោះ ករណីព្រហ្មទណ្ឌ នៃការរំលោភលើសេចក្តីទុកចិត្ត បានដាក់សម្ពាធដ៏សម្បើមភ្លាមៗទៅលើចុងចោទ ដើម្បីជំរុញគេអោយដោះស្រាយ បញ្ចប់វិវាទពាណិជ្ជកម្ម ព្រោះគេតែងចេញដីកាឃុំខ្លួនជនជាប់ចោទស្ទើរតែគ្រប់រូប ពីបទរំលោភលើសចក្តីទុកចិត្ត។

## រឿងដែលបានកើតឡើង ចំពោះជនជាប់ចោទពីបទរំលោភលើសេចក្តីទុកចិត្ត

ជនដែលរងការប្តឹងចោទពីបទរំលោភលើសេចក្តីទុកចិត្ត តែងតែប្រឈមមុខនឹងសម្ពាធដ៏ធំសម្បើម។ ជនជាប់ចោទ ពីបទរំលោភលើសេចក្តីទុកចិត្តស្ទើរតែគ្រប់រូប ត្រូវគេចេញដីកាឃុំខ្លួនពោលគឺ ជនជាប់ចោទតែងត្រូវគេចាប់ខ្លួន និងដាក់ឃុំខ្លួន រហូតដល់ត្រូវគេនាំខ្លួនទៅជួបចៅក្រមស៊ើបអង្កេត និងបញ្ជាក់ប្រាប់ការចោទប្រកាន់បឋម ពីបទរំលោភលើសេចក្តីទុកចិត្ត។ នេះមានន័យថា ជនជាប់ចោទអាចនឹងត្រូវគេឃុំខ្លួនមុនការជំនុំជំរះក្តីបានយ៉ាងងាយ។ ការឃុំខ្លួនមុនការជំនុំជំរះក្តី ជាប្រភពធំជាងគេនៃការដាក់សម្ពាធទៅលើជនជាប់ចោទ។ អ្នកផ្តល់សម្ភាសន៍ស្ទើរតែទាំងអស់បានបញ្ជាក់ថា ការជាប់ឃុំក្នុងពន្ធនាគារដោយសារតែវិវាទពាណិជ្ជកម្ម គឺជាអ្វីដែលគេចង់គេចអោយផុត ទោះត្រូវចំណាយអស់ប្រាក់ប៉ុន្មានក៏ដោយ។ ក្នុងពេលជាប់ឃុំ មុនការជំនុំជំរះក្តី ជនជាប់ចោទអាចយល់ព្រមបង់ "ប្រាក់ធានាខ្លួន" ដើម្បីបានរួចខ្លួនចេញពីពន្ធនាគារ។ ទំហំទឹកប្រាក់ដែលត្រូវបង់ អាស្រ័យនឹងទំហំទឹកប្រាក់នៃវិវាទ ប៉ុន្តែក្នុងរឿងក្តីភាគច្រើន វាមានទំហំពីរាប់ពាន់ ទៅរាប់ម៉ឺនដុល្លារ។ អ្នកផ្តល់សម្ភាសន៍ភាគច្រើនថ្លែងថា គេឃើញលទ្ធភាពតិចតួចណាស់ ឬគ្មានសោះតែម្តងក្នុងការទទួលបាន "ប្រាក់ធានាខ្លួន" នោះមកវិញ ទោះជារឿងក្តីចេញជាលទ្ធផលយ៉ាងណាក៏ដោយ។

ឧបសគ្គសេដ្ឋកិច្ច

ការពិភាក្សាលើវិស័យឯកជន លេខ ២៣

## ឥទ្ធិពលសេដ្ឋកិច្ចមកលើប្រទេសកម្ពុជា

គេពិបាកនឹងវាស់អោយបានជាក់លាក់ នូវឥទ្ធិពលរបស់រឿងក្តីមិនត្រឹមត្រូវនៃបទរំលោភសេចក្តីទុកចិត្ត ទៅលើប្រទេសកម្ពុជាណាស់ ព្រោះគ្មានមធ្យោបាយណាអាចប៉ាន់ស្មានចំនួនរឿងក្តីមិនត្រឹមត្រូវនៃបទរំលោភសេចក្តីទុកចិត្តដែលបានកើតឡើងក្នុងមួយឆ្នាំៗបានឡើយ។ ក៏ប៉ុន្តែ ព័ត៌មានដែលគេប្រមូលបានសម្រាប់របាយការណ៍នេះ បានបង្ហាញថា រឿងក្តីមិនត្រឹមត្រូវនៃបទរំលោភសេចក្តីទុកចិត្តច្រើនមានទំហំតូចៗ តែជាបញ្ហាចោទដ៏សំខាន់ចំពោះសហគមន៍អាជីវកម្ម។ គេឃើញមានថ្លៃចំណាយបីបួនប្រភេទ ជាប់ទាក់ទងនឹងរឿងក្តីមិនត្រឹមត្រូវ នៃបទរំលោភសេចក្តីទុកចិត្តទាំងនេះ។ ថ្លៃចំណាយជាក់ស្តែងបំផុត គឺថ្លៃចំណាយផ្ទាល់ ពោលគឺថ្លៃឈ្នួលមេធាវី និងថ្លៃចំណាយក្រៅផ្លូវការ។ តាមព័ត៌មានដែលទទួលបានពី អ្នកផ្តល់សម្ភាសន៍ និងពីការអង្កេតបង្ហាញឱ្យឃើញថា ថ្លៃចំណាយក្នុងរឿងក្តីនីមួយៗ មានទំហំចាប់ពីរាប់ពាន់ ដល់រាប់ម៉ឺនដុល្លារ។ ប្រភេទបន្ទាប់នៃថ្លៃចំណាយគឺការខាតបង់ក្នុងអាជីវកម្ម។ ប្រភេទធំជាងគេនៃថ្លៃចំណាយដែលជាប់ទាក់ទងនឹងរឿងក្តីមិនត្រឹមត្រូវនៃបទរំលោភសេចក្តីទុកចិត្តនេះ គឺការខាតបង់ឱកាសវិនិយោគ។ នេះគឺជាប្រាក់ដែលគេអាចនឹងយកមកវិនិយោគនៅក្នុងប្រទេសកម្ពុជា បើសិនជាគេគ្មានការបារម្ភអំពីរឿងក្តីមិនត្រឹមត្រូវនៃបទរំលោភសេចក្តីទុកចិត្តទាំងនោះទេ។ ការខាតបង់ឱកាសវិនិយោគ សម្រាប់ក្រុមហ៊ុន និងបុគ្គលឯកជន ដែលយើងបានអង្កេតសំរាប់របាយការណ៍នេះ មានចំនួនលើសពី ៥លានដុល្លារ ក្នុងមួយឆ្នាំ។ ការបកស្រាយបំភ្លឺអំពីមាត្រានៃការរំលោភលើសេចក្តីទុកចិត្ត និងការកែលំអការអនុវត្តន៍ច្បាប់នេះ អាចមានឥទ្ធិពលយ៉ាងធំដើម្បីបង្កើនការជឿទុកចិត្តរបស់អ្នកវិនិយោគ និងផ្តល់ផលប្រយោជន៍ ដល់សេដ្ឋកិច្ចកម្ពុជាទាំងមូល។

## សេចក្តីសង្ខេបនៃអនុសាសន៍របស់របាយការណ៍

ដោយផ្អែកលើការសិក្សាអំពីមាត្រាស្តីអំពីការរំលោភលើសេចក្តីទុកចិត្តនៃច្បាប់ព្រហ្មទណ្ឌអន្តរកាល កិច្ចសម្ភាសន៍លំអិត ជាមួយអាជីវកម្មចំនួន ១៨ និងអ្នកពាក់ព័ន្ធសំខាន់ៗ និងអ្នកដែលបានឆ្លើយតបនឹងការអង្កេតចំនួន ១១នាក់ អនុគណៈកម្មាធិការពិសេសបានលើកឡើងជា អនុសាសន៍ដូចខាងក្រោម:

១. អនុម័តសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ទាក់ទងនឹងការរំលោភលើសេចក្តីទុកចិត្ត

២ ផ្តោតការយកចិត្តទុកដាក់ទៅលើធាតុផ្សំស្តីពី ការទុកចិត្តប្រគល់អ្វីមួយអោយអ្នកដទៃទទួលខុសត្រូវ និងចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ

ក. ចេញសេចក្តីណែនាំរួមថ្មីមួយ ដែលតម្រូវអោយចៅក្រម ចេញសាលក្រមទាក់ទងនឹងករណីរំលោភលើសេចក្តីទុកចិត្ត ពិភាក្សាយ៉ាងច្បាស់លាស់ពីភស្តុតាងដែលគាំទ្រដល់ធាតុផ្សំនីមួយៗ នៃបទល្មើសព្រហ្មទណ្ឌ

ខ. ផ្តល់ការបណ្តុះបណ្តាលដល់ចៅក្រម អំពីធាតុផ្សំនានានៃការរំលោភលើសេចក្តីទុកចិត្ត ជាពិសេស ការបានប្រគល់អ្វីមួយអោយអ្នកដទៃទទួលខុសត្រូវ និងចេតនាប្រព្រឹត្តបទល្មើស

គ. បោះពុម្ពផ្សាយសាលក្រមទាំងអស់នៃរឿងក្តីរំលោភលើសេចក្តីទុកចិត្ត

៣. សម្របសម្រួលជាមួយរាជរដ្ឋាភិបាល សហគមន៍អាជីវកម្ម សង្គមស៊ីវិល និងបណ្តាញផ្សាយព័ត៌មានទាំងឡាយ ដើម្បីពិនិត្យតាមដានការអនុវត្តន៍ក្តីរំលោភលើសេចក្តីទុកចិត្ត

៤. បង្កើតយន្តការសម្រាប់ការរាយការណ៍ជាអនាមិក ពីបុគ្គលិកតុលាការ ឬនគរបាលណាដែលទារថ្លៃឈ្នួលក្រៅផ្លូវការ

៥. កាត់បន្ថយការឃុំខ្លួនមុនការជំនុំជំរះក្តីដោយចេញសេចក្តីណែនាំការងារជាផ្លូវការមួយដែលពិពណ៌នា យ៉ាងច្បាស់លាស់អំពីករណីដែលត្រូវប្រើការឃុំខ្លួនមុនការជំនុំជំរះក្តី ។

# សេចក្តីផ្តើម



## ១. គោលបំណងនៃការសិក្សា

សហគមន៍អាជីវកម្មនៅកម្ពុជាមានការបារម្ភជាច្រើន អំពីការអនុវត្តន៍មិនត្រឹមត្រូវនៃមាត្រាស្តីអំពីការរំលោភលើសេចក្តីទុកចិត្ត និងឥទ្ធិពលអវិជ្ជមានរបស់វាទៅលើសហគមន៍អាជីវកម្ម និងសេដ្ឋកិច្ចកម្ពុជា។ ចាប់តាំងពីឆ្នាំ ១៩៩៩ មក នៅពេលដែលរាជរដ្ឋាភិបាលបានបង្កើតវេទិការដ្ឋាភិបាល-ផ្នែកឯកជន ដើម្បីបំផុសការសន្ទនាគ្នា រវាងផ្នែកឯកជន និងរដ្ឋាភិបាល ផ្នែកឯកជនបានចាប់ផ្តើមលើកឡើង អំពីការប្រើប្រាស់មិនត្រឹមត្រូវនូវមាត្រាស្តីពីការរំលោភសេចក្តីទុកចិត្ត តាមរយៈក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច (LTGGWG) ដែលបង្កើតឡើងដោយវេទិកានេះ។ ឆ្លើយតបទៅនឹងការបារម្ភ ដែលផ្នែកឯកជនបានលើកឡើងនេះ ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការឧបត្ថម្ភពីកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC MPDF) បានបង្កើតអនុគណៈកម្មាធិការពិសេសមួយ នៃក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ចល្អ ដើម្បីសិក្សាបញ្ហាទាំងឡាយពាក់ពន្ធ័នឹងការអនុវត្តន៍ច្បាប់ស្តីពីការរំលោភលើសេចក្តីទុកចិត្តនេះ។

នាយករដ្ឋមន្ត្រីកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានបញ្ជាក់ថា ទំនុកចិត្តរបស់អ្នកវិនិយោគនៅក្នុងប្រទេសកម្ពុជាត្រូវការអោយគេធានា។ លើកលែងតែ វាជាទោសឧក្រិដ្ឋពិតប្រាកដ (មិនដូច្នោះ វិនិយោគិនមិនគួរត្រូវបានគេដាក់ទោសឧក្រិដ្ឋឡើយ) បញ្ហាទាំងឡាយដែលទាក់ទងនឹងការរំលោភលើសេចក្តីទុកចិត្តនោះត្រូវតែធ្វើអោយបានច្បាស់លាស់[២] ។ដូច្នេះគេសង្ឃឹមថា អនុសាសន៍ដែលលើកឡើង ក្នុងរបាយការណ៍ដែលជាសមិទ្ធផលនៃការងាររបស់អនុគណៈកម្មាធិការពិសេសនេះ នឹងរួមចំណែកជួយកាត់បន្ថយការខាតបង់ ដែលបណ្តាលមកពីរឿងក្តីមិនត្រឹមត្រូវនៃការរំលោភលើសេចក្តីទុកចិត្ត ចំពោះសេដ្ឋកិច្ចកម្ពុជាយ៉ាងច្រើន។

## ២. អ្វីទៅជាការរំលោភលើសេចក្តីទុកចិត្ត?

ការរំលោភលើសេចក្តីទុកចិត្តជាបទល្មើសមួយ ចែងនៅក្នុងមាត្រា ៤៦ នៃ ច្បាប់ព្រហ្មទណ្ឌអន្តរកាល។ ការរំលោភលើសេចក្តីទុកចិត្តមានធាតុផ្សំសំខាន់ៗផ្នែកសំភារៈបី និងធាតុផ្សំផ្នែកសតិមួយ។

[២] សង្ខេបសុន្ទរកថា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ទាក់ទងនឹងបញ្ហាការរំលោភលើសេចក្តីទុកចិត្ត នៅក្នុងវេទិការដ្ឋាភិបាល-ផ្នែក ឯកជន ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៧

មានធាតុផ្សំសំភារៈសំខាន់ទាំងនោះគឺ ៖

១. ទ្រព្យត្រូវតែបានគេទុកចិត្តប្រគល់ទៅអោយជនជាប់ចោទទទួលខុសត្រូវ

២. ជនជាប់ចោទត្រូវតែបានសន្យា ថានឹងសងទ្រព្យនោះទៅអោយម្ចាស់ដើមវិញ ឬមួយប្រើប្រាស់វាតាមគោលដៅ មួយដែលបានកំណត់ជាក់លាក់ និង

៣. ជនជាប់ចោទត្រូវតែបានបំបាត់ ឬតែបន្លំយកទ្រព្យគេ តាមរយៈការបដិសេធមិនព្រមសង ឬមិនបានប្រើវា តាមគោលដៅដែលបានព្រមព្រៀងគ្នា ។

ដើម្បីបញ្ជាក់ថា ជនជាប់ចោទមានទោសពីបទរំលោភលើសេចក្តីទុកចិត្ត ជនជាប់ចោទមិនត្រឹមតែបានប្រព្រឹត្តអំពើល្មើស សំភារៈទាំងឡាយដូចខាងលើនោះទេ ជននោះត្រូវតែប្រព្រឹត្តអំពើនោះដោយមានចេតនា ល្មើសច្បាប់ព្រហ្មទណ្ឌ ចង់តែបន្លំយកទ្រព្យពីអ្នកដទៃផងដែរ ។

## ៣. ហេតុអ្វីបានជាប្រទេសកម្ពុជាមានមាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្ត

អាជ្ញាធរបណ្តោះអាសន្នសហប្រជាជាតិនៅកម្ពុជា **(UNTAC)** ត្រូវបានបង្កើតឡើង នៅខែកុម្ភៈ ឆ្នាំ១៩៩២ ដើម្បីអនុវត្តកិច្ចព្រមព្រៀងក្រុងប៉ារីស ដែលបានចុះហត្ថលេខាខែតុលា ឆ្នាំ ១៩៩១ និងដែលជាលទ្ធផលនៃការចរចារផ្នែកទូតអស់ពេលជាច្រើនឆ្នាំ ។ ការងាររបស់គេ គឺដើម្បីធ្វើឱ្យមានសន្តិភាព បង្កើតរដ្ឋាភិបាលស៊ីវិលនៅកម្ពុជា និងរៀបចំការបោះឆ្នោតមួយដែលត្រឹមត្រូវ និងយុត្តិធម៌ ដើម្បីឈានទៅដល់ការបង្កើតឡើងនូវរដ្ឋធម្មនុញ្ញថ្មី និងចាប់ផ្តើមកសាងប្រទេសឡើងវិញ[៣] ។

UNTAC បានរាយការណ៍ថា កម្ពុជានៅក្នុងឆ្នាំ ១៩៩២ មានកង្វះខាតស្ថាប័នច្បាប់ជាមូលដ្ឋាន និងដំណើរការដែលប្រៀបដូចជាប្រព័ន្ធច្បាប់ ។ រចនាសម្ព័ន្ធ និងស្ថាប័នផ្នែកច្បាប់ដែលមានគឺជាអ្វីដែលបានតាក់តែង និងរៀបចំឡើងកាលពីទសវត្សរ៍កន្លងទៅ ។ ពេលនោះ កម្ពុជាមិនមានច្បាប់គ្រប់គ្រាន់ទេ ទោះជាច្បាប់រដ្ឋប្បវេណី ច្បាប់កិច្ចសន្យា ច្បាប់ទ្រព្យសម្បត្តិ ច្បាប់ និងនិតិវិធីព្រហ្មទណ្ឌ ច្បាប់អំពីតុលាការ ច្បាប់ស្តីពីភស្តុតាង ឬច្បាប់កាងារ ។ លើសពីនេះទៀត ស្ថាប័នដូចជា នគរបាល និងតុលាការ ស្ថិតនៅក្រោមការគ្រប់គ្រងយ៉ាងតឹងរឹងពីផ្នែកនយោបាយ ដែលមានការគាំទ្រដោយកំលាំងទ័ព ។

ការគ្រប់គ្រងផ្នែកនយោបាយមកលើតុលាការ និងការដាក់ទណ្ឌកម្មមិនសមស្រប បានជំរុញអោយ UNTAC ព្រាងច្បាប់ដែលទាក់ទងទៅនឹង តុលាការ ច្បាប់ និងនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបាននៅកម្ពុជាក្នុងកំឡុងពេលអន្តរកាល (ច្បាប់ព្រហ្មទណ្ឌអន្តរកាល) ។ ច្បាប់នេះត្រូវបានអនុម័តដោយឧត្តមក្រុមប្រឹក្សាជាតិ នៅថ្ងៃ ទី ១០ ខែកញ្ញា ឆ្នាំ ១៩៩២ ។ ច្បាប់នេះ គឺជាក្របខ័ណ្ឌច្បាប់ដែលគួរប្រើប្រាស់ដោយតុលាការ និងបរិធានសន្តិសុខនានា ក្នុងកំឡុងពេលអន្តរកាល ។ ច្បាប់នេះ ក៏បានសង្កត់ធ្ងន់ទៅលើ "ឯករាជ្យភាពរបស់តុលាការ និងបានរួមបញ្ចូលនូវបញ្ញត្តិពាក់ព័ន្ធទាំងអស់នៃលិខិតុបករណ៍

[៣] មើលឧទាហរណ៍ http://www.un.org/Depts/dpko/dpko/co_mission/untac.html

អន្តរជាតិ ស្តីពីសិទ្ធមនុស្សមកក្នុងច្បាប់ជាតិរបស់កម្ពុជា" (Hornoring Human Rights – Alice H Henkin)

UNTAC បានចាត់ទុកច្បាប់ព្រហ្មទណ្ឌអន្តរកាល ថាជាវិធានការបណ្តោះអាសន្នមួយ ដែលអាចនឹងជំនួសវិញយ៉ាងឆាប់រហ័សដោយច្បាប់ជាអចិន្ត្រៃមួយ[៤] ។ អាណត្តិរបស់ UNTAC បានឆ្លុះអោយឃើញនូវ "តំរូវការជាបន្ទាន់នៃការបញ្ជាក់ច្បាស់លាស់ ដល់គ្រប់គណៈបក្សកម្ពុជាទាំងអស់ អំពីច្បាប់ដែលត្រូវតែអនុវត្តជាទូទៅ នៅទូទាំងប្រទេសកម្ពុជា និងអំពីនីតិវិធីតុលាការដែលត្រូវការចាំបាច់ដើម្បីធ្វើអោយប្រាកដថា ច្បាប់នេះត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់នៅក្នុងដំណាក់កាលអន្តរកាល [៥]"

សព្វថ្ងៃនេះ ច្បាប់ព្រហ្មទណ្ឌអន្តរកាលនេះនៅតែជាមូលដ្ឋានគ្រឹះ សំរាប់ច្បាប់ព្រហ្មទណ្ឌភាគច្រើននៅកម្ពុជា រួមទាំង ខស្តីពីការរំលោភលើសេចក្តីទុកចិត្តផងដែរ ។ ច្បាប់ព្រហ្មទណ្ឌអន្តរកាលត្រូវបានបង្កើតឡើងដោយប្រញាប់ប្រញាល់ ហើយរំពឹងថានឹងត្រូវជំនួសដោយច្បាប់ថ្មី បន្ទាប់ពីរដ្ឋធម្មនុញ្ញត្រូវបានបង្កើត និងបន្ទាប់ពីកិច្ចប្រជុំសភាលើកទីមួយ ។ ប៉ុន្តែក្រោយ ពីរដ្ឋធម្មនុញ្ញត្រូវបានបង្កើតអស់រយៈពេលជាច្រើនឆ្នាំមកច្បាប់នេះនៅតែត្រូវបានគេប្រើនៅឡើយ ។អ្នកព្រាងច្បាប់នេះ ប្រហែលជានឹងមានការសំរេចចិត្តផ្សេងពីនេះ បើសិនជាគេដឹងថា ច្បាប់ព្រហ្មទណ្ឌអន្តរកាលនេះ ត្រូវបានបន្តប្រើប្រាស់រហូតមកដល់សតវត្សរ៍ទី ២១ ។

## ៤. ហេតុដែលធ្វើអោយការអនុវត្តន៍មាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្ត ក្លាយទៅជាបញ្ហាចោទមួយ នៅក្នុងប្រទេសកម្ពុជា

ភាពទន់ខ្សោយនៃប្រព័ន្ធច្បាប់ អំពើពុករលួយ និងការអនុវត្តន៍ច្បាប់មិនបានត្រឹមត្រូវ ដូចជាមាត្រាស្តីពីបទរំលោភលើសេចក្តីទុកចិត្ត នៃក្រមព្រហ្មទណ្ឌអន្តរកាល បានធ្វើអោយមានការរុញរាក្នុងការវិនិយោគ និងប៉ះពាល់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេស ។ ការស្ទាបស្ទង់ពីភាពប្រកួតប្រជែង របស់វេទិកាសេដ្ឋកិច្ចពិភពលោកឆ្នាំ ២០០៦ បានអោយចំណាត់ថ្នាក់កម្ពុជា លេខ ១០៣ ក្នុងចំណោមប្រទេស ១២៥ ដែលបានចូលរួមក្នុងការអង្កេត[៦] ។ ហើយរបាយការណ៍របស់ធានាគារពិភពលោក ពីការធ្វើអាជីវកម្ម ឆ្នាំ២០០៨ (Doing Business 2008) ក៏បានឱ្យចំណាត់ថ្នាក់ទាប

[៤] ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច
[៥] មើលឧទាហរណ៍ http://www.un.org/Depts/dpko/dpko/co_mission/untac.html
[៦] សន្ទស្សន៍ភាពប្រកួតប្រជែងពិភពលោក The Global Competitiveness Index (GCI) រៀបចំឡើងសំរាប់វេទិកាសេដ្ឋកិច្ចពិភពលោក ដោយសាស្ត្រាចារ្យ Xavier Sala-I Martine នៃសាកលវិទ្យាល័យកូឡំប៊ី និងដែលបានបោះពុម្ពផ្សាយលើកដំបូងនៅ ឆ្នាំ ២០០៤ ។ សន្ទស្សន៍នេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើកត្តា ១២ នៃភាពប្រកួតប្រជែងដែលរួមមាន: ស្ថាប័ន ហេដ្ឋារចនាសម្ព័ន្ធ ម៉ាក្រូសេដ្ឋកិច្ច ស្ថេរភាព សុខភាព និងការអប់រំបឋម ការអប់រំ និងការបណ្តុះបណ្តាលកំរិតខ្ពស់ ទីផ្សារល្អ ប្រសិទ្ធភាព និងទិន្នផលល្អ ទីផ្សារការងារ ភាពទំនើបនៃទីផ្សារហិរញ្ញវត្ថុ ការរីកចំរើនខាងបច្ចេកវិទ្យា ទំហំទីផ្សារ ភាពទំនើប និងការច្នៃប្រឌិតខាងអាជីវកម្ម ។

សំរាប់កម្ពុជាដែរ ទាក់ទងទៅនឹងភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម។ របាយការណ៍នេះបានអោយចំណាត់ថ្នាក់កម្ពុជា លេខ ១៤៥ ក្នុងចំណោមប្រទេស ១៧៨ ដែលបានចូលរួមក្នុងការស្ទាបស្ទង់[៧]។ ដោយអ្នកវិនិយោគជាច្រើន ស្ទាក់ស្ទើរក្នុងការវិនិយោគទុននៅកម្ពុជា ពាណិជ្ជកម្មអន្តរជាតិ និងការវិនិយោគ រួមចំណែកបានត្រឹមតែមួយផ្នែកតូច នៃសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ហើយវាផ្តោតទៅ លើតែវិស័យកាត់ដេរ សេវាកម្ម សំណង់ និងទេសចរណ៍ តែប៉ុណ្ណោះ។

ការអនុវត្តន៍មិនត្រឹមត្រូវនៃមាត្រាស្តីអំពីការរំលោភលើសេចក្តីទុកចិត្ត បានធ្វើអោយខាតបង់ដល់សេដ្ឋកិច្ចកម្ពុជា។ នាពេលថ្មីនេះ ក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល បានចេញសេចក្តីណែនាំរួមមួយ ទទួលស្គាល់ថា ការអនុវត្តន៍មិនត្រឹមត្រូវនៃមាត្រាស្តីអំពីការរំលោភលើសេចក្តីទុកចិត្ត គឺជាបញ្ហាមួយ នៅពេលដែលយើងគិតទៅដល់ការការពារសិទ្ធិប្រជាពលរដ្ឋ ដើម្បីឱ្យចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងអំពីការបង្កើនទំនុកចិត្តរបស់សាធារណៈជន និងអ្នកវិនិយោគ មកលើប្រព័ន្ធតុលាការ និងច្បាប់របស់កម្ពុជា[៨]។ ថ្វីបើគេពិបាកធ្វើការសន្និដ្ឋានជាទូទៅមួយ ចេញពីលទ្ធផលនៃការសម្ភាសន៍ និងអង្កេត ដែលអនុគណៈកម្មាធិការពិសេសបានធ្វើក្តី តួលេខសរុបនៃការខាតបង់ឱកាសវិនិយោគនៅកម្ពុជា មានកម្រិតខ្ពស់ណាស់។ យើងបានសួរទៅមជ្ឈដ្ឋានពាក់ព័ន្ធ និងអាជីវករទាំងឡាយថា "តើឱកាសវិនិយោគដែលលោកអ្នកបានបោះបង់ចោល ដោយសារតែហានិភ័យនៃការរំលោភលើសេចក្តីទុកចិត្តមានតម្លៃប៉ុន្មាន? ការបូកសរុបទឹកប្រាក់ដែលអាជីវករ ៧ នាក់បានឆ្លើយបង្ហាញថា ការបាត់បង់ឱកាសវិនិយោគមានប្រមាណពី ៣លាន ទៅដល់ ១២.១លានដុល្លារអាមេរិក។[៩]

ការអនុវត្តន៍មិនត្រឹមត្រូវ នៃច្បាប់ស្តីពីការរំលោភលើសេចក្តីទុកចិត្ត អាចធ្វើអោយវិនិយោគិនបរទេសមានការស្ទាក់ស្ទើរចិត្តក្នុងការវិនិយោគ ដោយហេតុថាគេបារម្ភអំពីលទ្ធភាពនៃការប្រើប្រាស់បទព្រហ្មទណ្ឌប្រឆាំងនឹងពួកគេ សំរាប់ករណីវិវាទកិច្ចសន្យា ឬក៏ដោយសារបំណងព្យាបាទណាមួយ។ អស់រយៈពេលជាច្រើនឆ្នាំ សហគមន៍អាជីវកម្មបានរាយការណ៍ថា បទរំលោភលើសេចក្តីទុកចិត្ត ត្រូវបានប្រើប្រាស់មិនត្រឹមត្រូវ ដើម្បីបង្ខំអោយពលរដ្ឋចំណាយលុយទៅអោយដើមចោទ និងថា វិវាទកិច្ចសន្យាសាមញ្ញៗ ជារឿយៗត្រូវបានចាត់ទុកជាករណីព្រហ្មទណ្ឌនៃការរំលោភលើសេចក្តីទុកចិត្ត ដោយសារតែការអនុវត្តន៍ ឬការយល់មិនបានត្រឹមត្រូវអំពីបញ្ញត្តិច្បាប់នេះ។ ក្តីបារម្ភរបស់ផ្នែកឯកជននេះ គឺជាការបារម្ភត្រឹមត្រូវ ព្រោះថា បុគ្គលដែលត្រូវបានចោទប្រកាន់ពីបទរំលោភលើសេចក្តីទុកចិត្ត ភាគច្រើនអាចនឹងត្រូវឃាត់ខ្លួន ហើយប្រសិនបើរកឃើញថាមានកំហុស អាចនឹងត្រូវកាត់ទោសអោយជាប់ពន្ធនាគារ។ នាពេលកន្លងមក អាជ្ញាធរតុលាការប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌស្តីពីការរំលោភលើសេចក្តីទុកចិត្ត មិនបានត្រឹមត្រូវសំរាប់ករណីកិច្ចសន្យាមិនមែនព្រហ្មទណ្ឌ និងករណីរដ្ឋប្បវេណី ផ្សេងៗទៀត

[៧] របាយការណ៍ អំពីការធ្វើអាជីវកម្ម ឆ្នាំ ២០០៨ (Doing Business 2008) ធនាគារពិភពលោក ២០០៧
[៨] សូមមើលឧបសម្ព័ន្ធ ៧
[៩] សូមមើលឧបសម្ព័ន្ធ ៤

ដែលគួរតែត្រូវបានដោះស្រាយក្រោមច្បាប់រដ្ឋប្បវេណី ជាជាងច្បាប់ព្រហ្មទណ្ឌ។ ការអនុវត្តន៍ដែលប្រែក្លាយ រឿងក្ដីរដ្ឋប្បវេណី ទៅជារឿងក្ដីព្រហ្មទណ្ឌ គឺជាបញ្ហាចម្បងមួយក្នុងចំណោមបញ្ហាធំៗជាច្រើននៃការអនុវត្តន៍មាត្រា ស្ដីពីការរំលោភលើសេចក្ដីទុកចិត្តនៃក្រមព្រហ្មទណ្ឌអន្តរកាល របស់តុលាការ។ ការរើករំពៃកឱ្យឃើញភាពខុសគ្នា រវាងវិវាទរដ្ឋប្បវេណី ដែលកើតចេញពីការខកខានមិនបានបំពេញករណីយកិច្ច និងវិវាទដែលកើតចេញពីការប្រព្រឹត្តដែលមានធាតុផ្សំ នៃការរំលោភលើសេចក្ដីទុកចិត្ត នៅតែជាបញ្ហាដែលត្រូវបញ្ជាក់អោយបានច្បាស់លាស់។ ការស្រាយបំភ្លឺអំពីច្បាប់ស្ដីពីការរំលោភលើសេចក្ដីទុកចិត្តនាពេលបច្ចុប្បន្ន និងការធ្វើអោយប្រសើរឡើងនៃការអនុវត្តន៍ច្បាប់នេះអាចនឹងរួមចំណែកយ៉ាងធំធេង ក្នុងការបង្កើនជំនឿចិត្តរបស់អ្នកវិនិយោគ និងផ្ដល់អត្ថប្រយោជន៍ច្រើនសំរាប់សេដ្ឋកិច្ចទាំងមូល។

> *"ការប្រើប្រាស់មិនត្រឹមត្រូវនៃបញ្ញត្តិស្ដីពីការរំលោភលើសេចក្ដីទុកចិត្ត បានជះឥទ្ធិពលអវិជ្ជមានទៅលើអាជីវកម្ម។ វាបានបង្អាក់ អ្នកវិនិយោគមិនអោយមកបណ្ដាក់ទុនវិនិយោគនៅកម្ពុជា។ វិវាទពាណិជ្ជកម្មអាចកើតឡើងនៅគ្រប់កន្លែងក្នុងពិភពលោក ប៉ុន្ដែជាទូទៅគេចាត់ទុកវាថាជាបទល្មើសរដ្ឋប្បវេណី។ នៅពេលដែលវិនិយោគិនដឹងថា នៅកម្ពុជា វិវាទពាណិជ្ជកម្មសាមញ្ញអាចនឹងត្រូវបានប្រែក្លាយទៅជា បទល្មើសព្រហ្មទណ្ឌបានដោយងាយនោះ ពួកគេមិនចូលមកវិនិយោគនៅកម្ពុជាទេ ដើម្បីជៀសវាងហានិភ័យនៃការចាប់ដាក់ពន្ធនាគារ។ ជាលទ្ធផល គឺកម្ពុជាខាតបង់ ដោយសារវិនិយោគិន បោះបង់ឱកាសវិនិយោគ។"*

លោក Bretton G. Sciaroni,
សហប្រធានក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច
នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន

ជំពូក ១

ការពិភាក្សាលើវិស័យឯកជន
លេខ ២៣

# បទព្រហ្មទណ្ឌនៃការរំលោភលើសេចក្ដីទុកចិត្ត

## ១. ធាតុផ្សំរបស់បទព្រហ្មទណ្ឌនៃការរំលោភលើសេចក្ដីទុកចិត្ត

បទល្មើសរំលោភលើសេចក្ដីទុកចិត្ត មានចែងនៅក្នុងមាត្រា ៤៦ នៃ "ច្បាប់ព្រហ្មទណ្ឌអន្តរកាល" ដែលបានព្រាងឡើងដោយអាជ្ញាធរបណ្ដោះអាសន្នសហប្រជាជាតិនៅកម្ពុជា (UNTAC) និងអនុម័តដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ គឺជាគ្រឹះនៃច្បាប់ព្រហ្មទណ្ឌដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា។ មាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល បានកំណត់និយមន័យនៃបទល្មើសរំលោភលើសេចក្ដីទុកចិត្តថា:

> **មាត្រា ៤៦ : ការរំលោភលើសេចក្ដីទុកចិត្ត**
>
> ជនណាដែលតែបន្លំ ឬចំបាត់ អោយខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់ទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញ ឬត្រប់ឯកសារដែលមាន ឬដែលចែងអំពីកាតព្វកិច្ច ឬការដោះបន្ទុកដែលគេប្រគល់អោយមកខ្លួន ក្នុងលក្ខណៈជាការជួល ជាការដាក់ផ្ញើកល់ទុក ជាអាណត្តិ ជាការអោយខ្ចីប្រើ ឬដើម្បីការងារមានបៀវត្ស ឬគ្មានបៀវត្ស ដែលត្រូវប្រគល់អោយគេវិញ ឬធ្វើជាតំណាង ឬសំរាប់ប្រើប្រាស់ ឬជាមុខការមានកំណត់ ត្រូវមានទោសមជ្ឈិមពីបទរំលោភលើទំនុកចិត្ត ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។[១០]

ជាអកុសល មាត្រា ៤៦ ជាមាត្រាវែង ស្មុគស្មាញ និងមានប្រការច្រើន។ មាត្រានេះពិបាកយល់បានណាស់ បើសិនជាគេមិនបានអានដោយប្រុងប្រយ័ត្ន។ មេធាវីកម្ពុជាមួយចំនួនដែលយើងបានជួបសម្ភាសបានត្អូញត្អែរថា ភាសានៅក្នុងមាត្រានេះ (ទាំងអត្ថបទជាភាសាអង់គ្លេស ទាំងជាភាសាខ្មែរ) បណ្ដាលអោយមានការយល់ច្រឡំ និងរួមចំណែកធ្វើអោយមានបញ្ហាចោទ ទាក់ទងនឹងរឿងក្ដីមិនត្រឹមត្រូវនៃការរំលោភលើសេចក្ដីទុកចិត្ត។

គេឃើញមានហេតុផលមួយចំនួន ចំពោះភាពពិបាកយល់នៃអត្ថបទនេះ។ ទីមួយ ភាសានៃមាត្រានេះ បានផ្អែកលើមាត្រា ៤០៨ នៃច្បាប់ព្រហ្មទណ្ឌបារាំងឆ្នាំ ១៨១០ ដែលស្មុគស្មាញ និងពិបាកយល់ដូចគ្នានេះដែរ។ នៅប្រទេសបារាំង គេបានប្ដូរច្បាប់ព្រហ្មទណ្ឌឆ្នាំ ១៨១០ នេះរួចហើយ

១០ កំណត់សំគាល់របស់អ្នកនិពន្ធរបាយការណ៍ជាភាសាអង់គ្លេស: "គេមិនឃើញមានការបកប្រែផ្លូវការជាភាសាអង់គ្លេសនៃច្បាប់ព្រហ្មទណ្ឌអន្តរកាលទេ។ ឯកសារច្បាប់ផ្លូវការតែមួយគត់នៃច្បាប់នេះ គឺអត្ថបទជាភាសាខ្មែរ។ ការបកប្រែដែលប្រើនៅទីនេះ ជាការបកប្រែដោយ UNTAC និងបោះពុម្ពផ្សាយដោយការិយាល័យស្នងការជាន់ខ្ពស់ ខាងសិទ្ធិមនុស្សនៅកម្ពុជា នៅក្នុង "ច្បាប់ជាធរមានមួយចំនួននៅ ព្រះរាជាណាចក្រកម្ពុជា" (២០០១)។ អ្នកផ្សេងៗទៀត បានបកប្រែមាត្រា ៤៦ ខុសៗពីគ្នាបន្តិចបន្តួច។ ឧទាហរណ៍ ក្រុមប្រឹក្សាអ្នកច្បាប់បកប្រែអត្ថបទនេះផ្សេងពីនេះ នៅក្នុងទម្រង់ដែលផ្សាយនៅលើគេហទំព័ររបស់គេ។"

ហើយភាសានៅក្នុងច្បាប់ព្រហ្មទណ្ឌបារាំងបច្ចុប្បន្ន មានភាពងាយយល់ជាងមុនជាច្រើន។ គេមិនបានដឹងច្បាស់ទេថា ហេតុអ្វីបានជាមន្ត្រីទាំងឡាយ នៃអាជ្ញាធរបណ្តោះអាសន្នសហប្រជាជាតិនៅកម្ពុជា (UNTAC) ដែលបានព្រាងច្បាប់នេះ បានជ្រើសរើសយកមកប្រើនូវភាសាដ៏ស្មុគស្មាញ ចេញពីច្បាប់ព្រហ្មទណ្ឌបារាំងចាស់ដូចនេះ ប៉ុន្តែវានឹងមានអត្ថប្រយោជន៍ច្រើន បើអត្ថបទច្បាប់នេះត្រូវបានកែសម្រួលដើម្បីបង្កើនភាពច្បាស់លាស់របស់វា។ ទីពីរ យោងតាមសម្តីរបស់អតីតបុគ្គលិក UNTAC មួយចំនួន ជាដំបូងគេបានព្រាងច្បាប់នេះជាភាសាបារាំង បន្ទាប់មកគេបកប្រែវាជាភាសាអង់គ្លេស ហើយជាបញ្ចប់ទើបបកប្រែមកជាភាសាខ្មែរ។ និយាយអោយខ្លី អត្ថបទជាភាសាខ្មែរ គឺជាការបកប្រែចេញពីការបកប្រែ។ ដោយហេតុនេះហើយ ទើបមេធាវី និងបញ្ញវន្តខ្មែរមួយចំនួន បានកត់សំគាល់ឃើញថា អត្ថបទជាភាសាខ្មែរមានលក្ខណៈច្របូកច្របល់។

ថ្វីបើមានភាពស្មុគស្មាញ និងជួនកាលមានភាសាច្របូកច្របល់នៅក្នុងមាត្រា ៤៦ នេះក្តី បទល្មើសជាក់ស្តែងនៃការរំលោភលើសេចក្តីទុកចិត្ត មានភាពសាមញ្ញខ្លាំងណាស់។ គេអាចបំបែកបទល្មើសជាធាតុផ្សំសំភារៈ និងធាតុផ្សំផ្នែកសតិ។ ធាតុផ្សំសំភារៈ សំដៅទៅលើអំពើជាក់ស្តែងទាំងឡាយ ដែលជនត្រូវគេប្តឹងពីបទល្មើស(ជនជាប់ចោទ) ត្រូវប្រព្រឹត្ត ដើម្បីជាប់ទោសពីបទរំលោភលើសេចក្តីទុកចិត្ត។ ធាតុផ្សំផ្នែកសតិ សំដៅលើចេតនាចង់ប្រព្រឹត្តធាតុផ្សំសំភារៈទាំងឡាយនោះ។ ជារឿយៗ ធាតុផ្សំផ្នែកសតិជាកត្តាសំខាន់ជាងគេបង្អស់។ តាមពិត បទល្មើសព្រហ្មទណ្ឌជាច្រើន មានធាតុផ្សំសំភារៈដូចៗគ្នា ហើយគេអាចញែកវាអោយខុសពីគ្នាបាន តែតាមរយៈចេតនារបស់ជនជាប់ចោទប៉ុណ្ណោះ។

ជាឧទាហរណ៍ យោងតាមច្បាប់ព្រហ្មទណ្ឌអន្តរកាល មនុស្សឃាតដោយចេតនា និងមនុស្សឃាតដោយអចេតនា មានធាតុផ្សំសំភារៈដូចគ្នាបេះបិទ គឺការសម្លាប់មនុស្ស។ បើសិនជាការសម្លាប់ធ្វើឡើងដោយគិតទុកជាមុន (មានចេតនាសម្លាប់) ឧក្រិដ្ឋកម្មនោះ គឺជាមនុស្សឃាតដោយចេតនា។ មនុស្សឃាតដោយចេតនា ត្រូវទទួលទោសជាប់ពន្ធនាគារពីប្រាំបី ទៅដប់ប្រាំឆ្នាំ។ បើសិនជាមនុស្សឃាតកើតឡើងដោយសារ "ការធ្វេសប្រហែស ការប្រមាទ ការមិនប្រុងប្រយ័ត្ន ឬការថ្លោះធ្លោយ មិនគោរពតាមបទបញ្ជានានា" នោះវាជាមនុស្សឃាតដោយអចេតនា។ មនុស្សឃាតដោយអចេតនា ត្រូវទទួលទោសជាប់ពន្ធនាគារពី មួយឆ្នាំ ទៅបីឆ្នាំ តែប៉ុណ្ណោះ។ ការសម្លាប់មនុស្សដោយចៃដន្យទាំងស្រុង ដែលជាឃាតកម្មកើតឡើងដោយគ្មានចេតនាសម្លាប់ ឬគ្មានការធ្វេសប្រហែសណាមួយពីសំណាក់អ្នកសម្លាប់ មិនមែនជាឧក្រិដ្ឋកម្មសោះឡើយ។ តាមការបង្ហាញ ជាឧទាហរណ៍ទាំងនេះ ធាតុផ្សំផ្នែកសតិ ដែលនាំអោយមានការប្រព្រឹត្តអំពើជាសំភារៈ ជារឿយៗ គឺជាអ្នកកំណត់អត្ថិភាព និងទម្ងន់ទោសនៃបទល្មើស។

## ២. ធាតុផ្សំសំខាន់ៗនៃការរំលោភសេចក្តីទុកចិត្ត

ថ្វីបើភាសានៃមាត្រា ៤៦ មានភាពស្មុគស្មាញខ្លាំងក្តី គេឃើញមានធាតុផ្សំសំភារៈសំខាន់ៗនៃបទល្មើសរំលោភលើសេចក្តីទុកចិត្តចំនួនបី គឺៈ

១. ទ្រព្យ (រួមទាំងទ្រព្យអរូបី) ត្រូវតែបានគេទុកចិត្តប្រគល់ទៅអោយ ជនជាប់ចោទទទួលខុសត្រូវ

២. ជនជាប់ចោទត្រូវតែបានសន្យាថា នឹងសងទ្រព្យនោះទៅអោយម្ចាស់ដើមវិញ ឬមួយប្រើប្រាស់វាតាមគោលដៅ មួយដែលបានកំណត់ជាក់លាក់ និង

៣. ជនជាប់ចោទត្រូវតែបានបំបាត់ ឬតែបន្លំទ្រព្យ តាមរយៈការបដិសេធមិនព្រមសង ឬមិនបានប្រើវា តាមគោលដៅដែលបានព្រមព្រៀងគ្នា។

យើងនឹងពិភាក្សាពីធាតុផ្សំនីមួយៗ ដូចខាងក្រោម។ ការពិភាក្សានេះ មិនមែនជាការវិភាគបច្ចេកទេសផ្នែកច្បាប់ទេ។ ផ្ទុយទៅវិញ ការពិភាក្សានេះផ្តោតទៅលើធាតុផ្សំសំខាន់ៗនៃបទល្មើសតែប៉ុណ្ណោះ ហើយគេពន្យល់បកស្រាយវាតាមរបៀបមួយ ដែលច្បាស់លាស់ និងអាចយល់បានយ៉ាងងាយ។ អ្នកអានគោលដៅរបស់យើងគឺ សហគមន៍អាជីវកម្ម អ្នកផ្តល់ជំនួយ និងរាជរដ្ឋាភិបាលកម្ពុជា។ របាយការណ៍នេះ មិនបានពិភាក្សាសំណួរផ្នែកច្បាប់ពិបាកៗជាបង្គួរមួយចំនួន ដែលអាចលេចឡើងនៅក្នុងរឿងក្តីមួយចំនួនតូចនោះទេ។ ការវិភាគបច្ចេកទេសច្បាប់បែបនេះ ត្រូវបានធ្វើឡើង និងផ្សព្វផ្សាយរួចហើយ ដោយ លោក **កុយ នាម** ដែលជាមេធាវីសញ្ជាតិកម្ពុជាដ៏ល្បីមួយរូប ហើយយើងបានបញ្ចូលការវិភាគនេះ ទៅក្នុងឧបសម្ព័ន្ធ ៥ សម្រាប់ជាប្រយោជន៍ដល់អ្នកទាំងឡាយណា ដែលចង់ទទួលបានព័ត៌មានកាន់តែលំអិតទៅទៀត។

### ២.១ ទ្រព្យត្រូវតែបានគេទុកចិត្តប្រគល់អោយជនជាប់ចោទទទួលខុសត្រូវ

ធាតុផ្សំសំភារៈទីមួយគឺ ទ្រព្យត្រូវតែបានគេទុកចិត្តប្រគល់អោយជនជាប់ចោទទទួលខុសត្រូវ។ កត្តាធាតុផ្សំសំភារៈ ចាំបាច់ទីមួយនេះមាននៅក្នុងភាសាថា "ទ្រព្យ ប្រាក់កាស ទំនិញ ឬឯកសារណាមួយ ដែលមាន ឬដែលចែងអំពីកាតព្វកិច្ច ឬការដោះបន្ទុក ដែលគេប្រគល់អោយមកខ្លួនក្នុងលក្ខណៈជាការជួល ជាការដាក់ដឹកល់ទុក ជាអាណត្តិ ជាការអោយខ្ចីប្រើ ឬជាប្រាក់កម្រៃសម្រាប់ការងារមាន ឬគ្មានប្រាក់បៀវត្ស ..."។ ភាសានេះស្មុគស្មាញ ប៉ុន្តែ នៅក្នុងរឿងក្តីជាច្រើន "ទ្រព្យ ប្រាក់កាស ទំនិញ ឬឯកសារ ណាមួយដែលមាន ឬដែលចែងអំពីកាតព្វកិច្ច ឬការដោះបន្ទុក" អាចនិយាយឡើងវិញយ៉ាងសាមញ្ញថាជា "**ទ្រព្យ**"។

ផ្នែកបន្តនៃឃ្លានេះបញ្ជាក់ថា ទ្រព្យនោះត្រូវតែបានគេទុកចិត្តប្រគល់អោយជនជាប់ចោទ "ជាការជួល ជាការដាក់ដឹកល់ទុក ជាអាណត្តិ ជាការអោយខ្ចីប្រើ ឬជាប្រាក់កម្រៃសម្រាប់ការងារមាន ឬគ្មានប្រាក់បៀវត្ស ..."។ ភាសានេះ ទំនងជាមិនចាំបាច់ឡើយ។ វាបានពិពណ៌នាកិច្ចសន្យាខុសគ្នា

ចំនួនប្រាំមួយប្រភេទ ដែលគេអាចបង្កើតឡើងតាមរយៈការប្រគល់ទ្រព្យអោយជនដទៃទទួលខុសត្រូវ។ ក្នុងការអនុវត្តន៏ជាក់ស្តែង ការប្រគល់ទ្រព្យអោយជនដទៃ ទំនងជានឹងនិយាយដល់ទម្រង់ណាមួយនៃកិច្ចសន្យាទាំងប្រាំមួយបែប តាមរយៈការកាត់យល់ ឬមួយដោយជាក់លាក់។ ក្នុងករណីភាគច្រើន បញ្ហាសំខាន់គឺ តើគេបានប្រគល់ទ្រព្យអោយជនជាប់ចោទឬអត់ មិនមែនប្រភេទកិច្ចសន្យាដែលគេបានបង្កើតឡើង រវាងជនជាប់ចោទ និងម្ចាស់ទ្រព្យឡើយ។ ហេតុដូច្នេះហើយ ការនិយាយអំពីធាតុផ្សំនៃបទល្មើសនេះ ក្នុងករណីភាគច្រើន គេអាចនឹងនិយាយឡើងវិញថាៈ ទ្រព្យត្រូវតែបានគេទុកចិត្តប្រគល់អោយជនជាប់ចោទទទួលខុសត្រូវ។[១១]

### ២.២ ជនជាប់ចោទត្រូវតែបានសន្យាថានឹងសងទ្រព្យនោះទៅអោយម្ចាស់ទ្រព្យវិញ ឬមួយប្រើប្រាស់វាតាមគោលដៅមួយ ដែលគេបានកំណត់ជាក់លាក់

ធាតុផ្សំនេះបង្កប់នៅក្នុងភាសាថា "...ដោយបានសន្យាថាសងវិញ ឬប្រគល់អោយវិញ ឬប្រើប្រាស់តាមការព្រមព្រៀងគ្នាណាមួយ ..."។ ច្បាស់ណាស់ថា ធាតុផ្សំនេះអាស្រ័យនឹងអត្ថិភាពនៃធាតុផ្សំទីមួយ។ ជនជាប់ចោទ ត្រូវតែបានគេទុកចិត្ត ប្រគល់ទ្រព្យអោយទទួលខុសត្រូវ មុននឹងគេអាចសន្យាថា "សងវិញ ឬប្រគល់អោយវិញ ឬប្រើប្រាស់តាមការព្រមព្រៀងគ្នាណាមួយ។" ភាសានេះពិពណ៌នាអំពីទង្វើបីយ៉ាង ដែលជនជាប់ចោទត្រូវតែបានសន្យាថា នឹងធ្វើចំពោះទ្រព្យនោះ។ ទីមួយ ជនជាប់ចោទ អាចសន្យាថានឹងសងទ្រព្យនោះវិញ។ ការណ៏នេះ ពិពណ៌នាពីស្ថានភាពដែលជនជាប់ចោទបានខ្ចីរបស់អ្វីមួយ ដូចជា រថយន្ត ហើយបានសន្យាថានឹងប្រគល់របស់នោះសងទៅម្ចាស់វិញ។ ជនជាប់ចោទកាន់កាប់ទ្រព្យដោយស្របច្បាប់ ព្រោះម្ចាស់ទ្រព្យ បានប្រគល់វាទៅអោយរូបគេដោយស្ម័គ្រចិត្ត ប៉ុន្តែគេបានសន្យាចំពោះម្ចាស់របស់នោះថា នឹងប្រគល់សងវិញ។ ប្រការនេះបានកំហិតសិទ្ធិរបស់គេលើទ្រព្យនោះ។ គេមិនអាចលក់វា ឬប្រគល់វាជាបន្តអោយទៅនរណាទៀតបានទេ។ គេត្រូវតែប្រគល់ទ្រព្យនោះសងម្ចាស់វិញ។

ពាក្យថា "ស្នើប្រគល់អោយគេវិញ" និយាយសំដៅស្ថានភាព ដែលជនជាប់ចោទត្រូវបានគេទុកចិត្តប្រគល់ទ្រព្យអោយ តែបានសន្យាផ្តល់ឱកាសអោយម្ចាស់ទ្រព្យ ទទួលបានទ្រព្យនោះវិញ មុនពេល ដែលជនជាប់ចោទចាត់ចែងការអ្វីមួយលើទ្រព្យនោះ។ ឧទាហរណ៏ ជនជាប់ចោទអាចជួលគ្រឿងចក្រកសិកម្មមួយគ្រឿង សម្រាប់រយៈពេលបីឆ្នាំ។ ម្ចាស់ទ្រព្យ និងជនជាប់ចោទបានព្រមព្រៀងគ្នាថា ម្ចាស់ទ្រព្យមានសិទ្ធិទិញគ្រឿងចក្រនោះវិញ ក្នុងតម្លៃមួយដែលបានព្រមព្រៀងគ្នា នៅពេលចប់រយៈពេលកំណត់បីឆ្នាំនោះ។ បើសិនជាម្ចាស់ទ្រព្យ មិនចង់ទិញយកគ្រឿងចក្រនោះវិញទេ ទើបជនជាប់ចោទមានសិទ្ធិលក់វាទៅអោយអ្នកដែលហ៊ានថ្លៃខ្ពស់ជាងគេ។ នៅក្នុងបណ្តាប្រទេសដែលគោរពតាម

---

[១១] អាចមានរឿងក្តីមួយចំនួន ដែលជាអត្ថិភាពនៃបទល្មើសស្តីពីការរំលោភលើសេចក្តីទុកចិត្ត ពិតជាអាស្រ័យលើប្រភេទណាមួយនៃកិច្ចសន្យា ដែលបានបង្កើតឡើង រវាងជនជាប់ចោទ និងម្ចាស់ទ្រព្យមែន។ នេះជាប្រធានបទដ៏លំបាកមួយ និងមានលក្ខណៈបច្ចេកទេស ហើយបញ្ហានេះកម្ពុជាបានវិភាគរួចហើយ។ ជាឧទាហរណ៏ អត្ថបទរបស់លោក **កុយ នាម** ក្រោមចំណងជើងថា "ការរំលោភលើសេចក្តីទុកចិត្ត" (ដែលយើងបានដាក់បញ្ចូលទៅក្នុងឧបសម្ព័ន្ធ ៥) បានពិភាក្សាពីបញ្ហានេះ យ៉ាងល្អិតល្អន់។

ប្រព័ន្ធច្បាប់អង់គ្លេស (Common law) គេអាចពិពណ៌នាករណីនេះ ថាជាការអាចយកបានទ្រព្យដែលជាកម្មវត្ថុនៃ "សិទ្ធិមានឱកាសទិញមុនគេ"។ ចំណុចសំខាន់នោះគឺ ជនជាប់ចោទបានសន្យាចំពោះម្ចាស់ទ្រព្យថា គេកំហិតសិទ្ធិរបស់គេក្នុងការចាត់ចែងលើទ្រព្យនោះ។គេមិនអាចលក់ទ្រព្យនោះបានតាមចិត្ត ដោយមិនបានស្នើផ្តល់វាទៅអោយម្ចាស់របស់វិញមុនគេនោះទេ។

បែបផែនទីបី ដែលធាតុផ្សំនេះត្រូវបំពេញគឺ តាមរយៈការសន្យាថានឹងប្រើប្រាស់ទ្រព្យនោះ តាមការព្រមព្រៀងគ្នា។ ជាថ្មីម្តងទៀត ចំណុចសំខាន់នៅទីនេះគឺ ជនជាប់ចោទបានសន្យាចំពោះម្ចាស់របស់ថា ទប់ស្កាត់ខ្លួនឯងមិនអោយចាត់ទុកទ្រព្យនោះ ដូចជារបស់ផ្ទាល់ខ្លួនទេ។ ករណីជាគំរូគឺករណីនិយោជិតម្នាក់ ដែលត្រូវបាននិយោជកទុកចិត្តប្រគល់ប្រាក់អោយកាន់ សម្រាប់បំពេញគោលដៅកំណត់មួយ។ ឧទាហរណ៍ និយោជិតនោះត្រូវបាននិយោជក ប្រគល់ប្រាក់អោយយកទៅដាក់ផ្ញើនៅធនាគារ ពោលគឺបានទទួលទ្រព្យសម្រាប់ប្រើប្រាស់តាមការកំណត់មួយ។ គេកាន់កាប់វាស្របច្បាប់ ប៉ុន្តែគេកាន់កាប់វាសម្រាប់តែគោលដៅមួយដែលបានកំណត់តែប៉ុណ្ណោះ គឺយកប្រាក់នោះទៅធនាគារ ហើយដាក់ផ្ញើវានៅទីនោះ។ គេបានធ្វើការសន្យាយ៉ាងជាក់លាក់ ឬតាមការកាត់យល់ ហើយប្រការនោះបានកំហិតលទ្ធភាពរបស់គេ មិនអោយចាត់ទុកប្រាក់នោះ ថាជារបស់ផ្ទាល់ខ្លួនទេ។ ចំណុចសំខាន់សម្រាប់ផ្នែកទាំងបីនៃធាតុផ្សំនេះគឺ ជនជាប់ចោទបានសន្យាចំពោះម្ចាស់ទ្រព្យ ដែលដាក់កំហិតដល់សិទ្ធិរបស់គេ ក្នុងការចាត់ចែងការលើទ្រព្យនោះ។ ការរំលោភដោយចេតនាលើការសន្យានេះគឺជាការរំលោភលើសេចក្តីទុកចិត្ត។

## ២.៣ ជនជាប់ចោទត្រូវតែបានបំបាត់ ឬគៃបន្លំទ្រព្យគេ

ធាតុផ្សំនេះកើតឡើង នៅពេលដែលជនជាប់ចោទថ្លោះធ្លោយ មិនបានធ្វើតាមការសន្យាទាក់ទងនឹងទ្រព្យ។ វាកើតចេញពីភាសាថា "ជនណាដែលគៃបន្លំ ឬបំបាត់(ទ្រព្យ) ធ្វើអោយខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់..." ទ្រព្យ[១២]។ ប្រការនេះទាក់ទងនឹងការថ្លោះធ្លោយ គោរពមិនបានតាមការសន្យាក្នុងធាតុផ្សំទីពីរ។ បើសិនជាជនជាប់ចោទបានសន្យាសងទ្រព្យវិញ នោះគេត្រូវតែខំប្រឹងសងវាវិញ។ បើសិនជាគេបានសន្យាថា ស្នើប្រគល់អោយវិញ នោះគេត្រូវតែខំប្រឹងស្នើប្រគល់វាអោយវិញ។ បើសិនជាគេបានសន្យាថា នឹងប្រើប្រាស់វាសម្រាប់គោលដៅកំណត់ណាមួយនោះ គេត្រូវតែខំប្រឹងប្រើប្រាស់វាអោយត្រូវតាមគោលដៅនោះ។ ការគៃបន្លំអាចកើតឡើងតាមវិធីជាច្រើន ប៉ុន្តែរូបភាពទូទៅបំផុតអាចជាការបំផ្លាញទ្រព្យ ការលក់ទ្រព្យទៅអោយជនទីបី ការរក្សាវាទុក និងបដិសេធមិនព្រមប្រគល់អោយវិញ ឬមួយប្រើវាតាមគោលដៅផ្សេងៗទៀត ដែលខុសពីគោលដៅគ្រោងទុកដូចដែលបានព្រមព្រៀងគ្នា។ ជាឧទាហរណ៍ ការគៃបន្លំ

[១២] ពាក្យថា "ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់" ត្រូវគេប្រើនៅក្នុងច្បាប់នេះ ជាជំនួសអោយពាក្យថា "ម្ចាស់ទ្រព្យ" ដែលងាយស្រួលប្រើជាងនេះ ដើម្បីបញ្ជាក់អោយច្បាស់ថា ការរំលោភសេចលើក្តីទុកចិត្ត អាចប្រព្រឹត្តលើជនណាម្នាក់ ដែលជាអ្នកកាន់កាប់ទ្រព្យ នោះដោយស្របច្បាប់ ទោះបីអ្នកនោះមិនមែនជាម្ចាស់ពិតប្រាកដក៏ដោយ។ ក្នុងករណីជាច្រើន ភាពខុសគ្នានេះ មិនមានន័យអ្វីទេ ពីព្រោះអ្នកដែលប្រគល់ទ្រព្យអោយជនជាប់ចោទទទួលខុសត្រូវគឺជាម្ចាស់ពិតប្រាកដ។

ទ្រព្យអាចកើតឡើង នៅពេលដែលនរណាម្នាក់បានខ្ចីម៉ូតូពីមិត្តភក្តិ រួចលក់ម៉ូតូនោះទៅអោយបុគ្គលទីបី ។ ដូចគ្នានេះ វាអាចកើតឡើង ក្នុងស្ថានភាពដែលនិយោជិតម្នាក់បានទទួលប្រាក់ សម្រាប់យកទៅទិញគ្រឿងប្រើប្រាស់សម្រាប់ការិយាល័យ តែគេបែរជាយកប្រាក់នោះទៅចាក់ល្បែងភ្នាល់បាល់ទាត់ទៅវិញ ។ ក្នុងករណីទាំងពីរនេះ សកម្មភាពរបស់ជនជាប់ចោទបានទប់ស្កាត់ពួកគេ មិនអោយធ្វើតាមការសន្យាបានឡើយ ។

ធាតុផ្សំនេះ ក៏តម្រូវអោយមានការខូចខាតដល់ម្ចាស់ទ្រព្យសម្បត្តិផងដែរ ។ ការដែលជនជាប់ចោទបានថ្លោះធ្លោយ មិនបានបំពេញតាមកិច្ចសន្យា វាមិនគ្រប់គ្រាន់ទេ ។ ផ្ទុយទៅវិញការថ្លោះធ្លោយត្រូវតែកើតចេញពីការគេចបន្លំ ឬការចាត់ចែងលើទ្រព្យ ផ្ទុយពីផលប្រយោជន៍របស់ម្ចាស់ទ្រព្យនោះ ។ ម្យ៉ាងទៀត ការថ្លោះធ្លោយត្រូវតែមានលក្ខណៈថា ម្ចាស់របស់មិនអាចទទួលទ្រព្យបានមកវិញឡើយ ។ ជាឧទាហរណ៍ បើសិនជាស្ត្រីម្នាក់បានជួលរថយន្តមួយ សម្រាប់រយៈពេលមួយសប្តាហ៍ ហើយបានសងវាវិញយឺតជាងការសន្យាមួយថ្ងៃ នោះគាត់មិនបានគេចបន្លំយករថយន្តនោះទេ ។ វាជាការពិតថា គាត់មិនអាចបំពេញតាមលក្ខខណ្ឌកំណត់ដ៏ជាក់លាក់នៃការសន្យាបានមែន ប៉ុន្តែ សកម្មភាពរបស់គាត់ មិនបានធ្វើអោយខូចផលប្រយោជន៍ម្ចាស់ទ្រព្យ ដោយសាររថយន្តនោះទេ ។ ស្ត្រីនោះ អាចត្រូវបង់ថ្លៃជួលរថយន្ត មួយថ្ងៃថែមទៀត ប៉ុន្តែយោងតាមអត្ថន័យ នៃមាត្រា ៤៦ គាត់មិនបាន "គេចបន្លំ ឬបំបាត់អោយខូចប្រយោជន៍" លើរថយន្តនោះទេ ។ ក៏ប៉ុន្តែ ចំពោះបុរសម្នាក់ដែលជួលត្រាក់ទ័រ សម្រាប់រយៈពេលមួយសប្តាហ៍ ដើម្បីដឹកដីនៅក្នុងភូមិកររបស់គាត់ ហើយបានលក់ត្រាក់ទ័រនោះ ទៅអោយភាគីទីបី ពិតជាបានគេចបន្លំត្រាក់ទ័រនោះមែន ព្រោះម្ចាស់ទ្រព្យមិនអាចទទួលបានត្រាក់ទ័រនោះ ពីជនជាប់ចោទមកវិញឡើយ ។

### ៣. ធាតុផ្សំផ្នែកសតិ ៖ ចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ

ជនម្នាក់ អាចជាប់ទោសដោយសារបទល្មើសរំលោភលើសេចក្តីទុកចិត្ត បើជននោះមិនមែនត្រូវប្រព្រឹត្តត្រឹមតែអំពើជាសំភារៈ ដូចបានពិពណ៌នាខាងលើនេះទេ គេត្រូវតែធ្វើអំពើនោះដោយចេតនាទៀតផង ។ វាជាការមិនគ្រប់គ្រាន់ទេ បើសិនជាជនជាប់ចោទប្រព្រឹត្តតែអំពើជាសំភារៈទាំងឡាយដែលពិពណ៌នាខាងលើ ។ គេអាចបង្ហាញពីស្ថានភាពនេះ ដោយប្រើឧទាហរណ៍ងាយៗពីរ ដូចតទៅ:

- បុរសម្នាក់ខ្ចីប្រាក់ ៥០០ ដុល្លារ ពីអ្នកជិតខាងរបស់គាត់ដើម្បីយកទៅដាំពោត ។ គាត់បានសន្យាថានឹងយកប្រាក់នោះទៅទិញគ្រាប់ពូជពោត និងជី ព្រមទាំងបានសន្យាថានឹងសងប្រាក់នោះវិញក្នុងរយៈពេល ប្រាំមួយខែក្រោយ នៅពេលដែលគាត់លក់ផលពោតបាន ។ គាត់បានដាំពោត ប៉ុន្តែមានគ្រោះរាំងស្ងួតយ៉ាងអាក្រក់ បណ្តាលអោយពោតរបស់គាត់ងាប់អស់ ។ គាត់មិនអាចធ្វើអ្វីដើម្បីទប់ស្កាត់ស្ថានភាពនោះបានឡើយ ។ គាត់មិនអាចសងប្រាក់ ដល់អ្នកជិតខាងរបស់គាត់វិញបានទេ ។
- បុរសម្នាក់ខ្ចីប្រាក់ ៥០០ ដុល្លារ ពីអ្នកជិតខាងរបស់គាត់ ដោយប្រាប់គេថា គាត់មានបំណងប្រើវាដើម្បីដាំពោត ។ គាត់បានសន្យាថានឹងយកប្រាក់នោះ ទៅទិញគ្រាប់ពូជពោត និងជី ព្រមទាំងបាន

សន្យាថា នឹងសងប្រាក់នោះវិញ ក្នុងរយៈពេលប្រាំមួយខែក្រោយ នៅពេលដែលគាត់លក់ផលពោតបាន។ ប៉ុន្តែ គាត់គ្មានបំណងដាំពោតពិតប្រាកដឡើយ។ គាត់បែរជាមានបំណងយកប្រាក់នោះ ហើយផ្លាស់ទីលំនៅទៅភ្នំពេញ។ នៅពេលដែលគាត់ទៅខ្ចីប្រាក់គេ គាត់បានដឹងខ្លួនឯងថា គាត់មិនប្រុងសងប្រាក់នោះ ទៅអោយអ្នកជិតខាងគាត់វិញ ក្នុងរយៈពេលប្រាំមួយខែទៀតនោះឡើយ។ មួយរយៈខ្លីក្រោយពីខ្ចីបានប្រាក់ គាត់បានផ្លាស់ទីលំនៅទៅភ្នំពេញ និងគេចខ្លួនបាត់។

គេឃើញច្បាស់ណាស់ថា គេមិនគួរចាត់ទុកមនុស្សទាំងពីរនាក់នេះដូចគ្នាទេ។ បុរសម្នាក់ជាជនល្មើស ឯបុរសម្នាក់ទៀត ជាជនរងគ្រោះដោយជួបនឹងសំណាងអាក្រក់។ ប៉ុន្តែបុរសទាំងពីរនាក់បានប្រព្រឹត្តធាតុផ្សំសំភារៈនៃបទល្មើសរំលោភសេចក្តីទុកចិត្តដូចគ្នា។ បុរសទាំងពីរនាក់ត្រូវបានគេទុកចិត្តប្រគល់ទ្រព្យមួយចំនួនអោយ។ ទាំងពីរនាក់ បានសន្យាថា នឹងសងទ្រព្យនោះទៅម្ចាស់ទ្រព្យវិញ។ ក្នុងករណីទាំងពីរ មានហេតុការណ៍មួយកើតឡើងចំពោះទ្រព្យនោះ ដែលរារាំងមិនអោយគេអាចសងវាទៅម្ចាស់ដើមវិញបាន។

ប្រការខុសគ្នាគឺ ចេតនារបស់បុរសទាំងពីរនាក់។ បុរសក្នុងឧទាហរណ៍ទីមួយ គ្មានបំណងគេចវេសពីការសងបំណុលទេ។ គាត់បានដាំពោត និងខំធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីបំពេញករណីយកិច្ចរបស់គាត់អោយបាន។ ក៏ប៉ុន្តែ គ្រោះរាំងស្ងួតបានសម្លាប់ផលដំណាំរបស់គាត់ ហើយនោះមិនមែនជាកំហុសរបស់គាត់ផ្ទាល់ទេ។ បុរសក្នុងឧទាហរណ៍ទីពីរ មានចេតនាប្រព្រឹត្តបទល្មើស។ គាត់បានកុហកអ្នកជិតខាងគាត់អំពីមូលហេតុនៃការចង់ខ្ចីប្រាក់ ហើយនៅពេលដែលគាត់យកប្រាក់នោះ គាត់គ្មានបំណងសងវាវិញឡើយ។ មួយរយៈខ្លីក្រោយពីខ្ចីប្រាក់បាន គាត់គេចខ្លួនដោយយកប្រាក់នោះទៅជាមួយ។ នេះជាសក្ខីភាពដ៏គ្រប់គ្រាន់ ដែលបង្ហាញថា គាត់មានបំណងប្រព្រឹត្តបទល្មើស។

ចេតនាប្រព្រឹត្តបទល្មើស គឺជាធាតុផ្សំចាំបាច់នៃបទល្មើសព្រហ្មទណ្ឌ នៃការរំលោភលើសេចក្តីទុកចិត្ត។ ជនជាប់ចោទ ត្រូវតែមានចេតនាធ្វើអំពើនេះ និងត្រូវតែដឹងថាអ្វីដែលគាត់ធ្វើជាអំពើខុស។ វាមិនអាចជាកំហុស ឬភាពចៃដន្យមួយនោះទេ។ ប្រការនេះ មានការបញ្ជាក់ច្បាស់តាមរយៈការប្រើពាក្យ "គៃបន្លំ" នៅក្នុងអត្ថបទនៃមាត្រា៤៦។ គៃបន្លំ មានន័យថាយកអ្វីមួយ តែក៏មានន័យផងដែរថាការយកនោះប្រព្រឹត្តទៅតាមផ្លូវខុស ឬដោយទុច្ចរិត។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូលបានធ្វើការសន្និដ្ឋានដូចគ្នានេះដែរនៅក្នុង "សេចក្តីណែនាំរួម" ថ្មីៗនេះរបស់ខ្លួន ចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ២០០៥ ស្តីពីការរំលោភលើសេចក្តីទុកចិត្ត។ ថ្វីបើកន្លែងខ្លះក្នុងអត្ថបទនៃសេចក្តីណែនាំរួមនេះមានភាពច្របូកច្របល់ក្តី សេចក្តីណែនាំនេះកត់សំគាល់ថា ជនជាប់ចោទត្រូវតែមាន "បំណងអាក្រក់" ឬត្រូវ "កេងប្រវ័ញ្ច ឬគៃបន្លំ" យកទ្រព្យដែលគេបានទុកចិត្តប្រគល់អោយ។ នៅក្នុងការសម្ភាសន៍មួយជាមួយព្រះរាជអាជ្ញាអមតុលាការរាជធានីភ្នំពេញម្នាក់ លោកបានផ្តោតទៅលើចេតនាប្រព្រឹត្តបទល្មើសថាជាធាតុផ្សំដ៏សំខាន់មួយ ដើម្បីអាចសម្រេចថា តើត្រូវដាក់ ឬមិនត្រូវដាក់បណ្តឹងព្រហ្មទណ្ឌ។ តុលាការកំពូលក៏បានទទួលស្គាល់ដែរថា ចេតនាប្រព្រឹត្តបទល្មើសគឺជាធាតុផ្សំមួយនៃបទល្មើសព្រហ្មទណ្ឌ ហើយ

នៅក្នុងឆ្នាំ ២០០២ គេបានដោះលែងស្ត្រីម្នាក់ពីការឃុំខ្លួនមុនការជំនុំជំរះ ដោយសារមូលហេតុថា គ្មានភស្តុតាងបញ្ជាក់ចេតនាប្រព្រឹត្តបទល្មើសនោះ ។[១៣]

## ៤. ក្រមព្រហ្មទណ្ឌថ្មី

ច្បាប់ព្រហ្មទណ្ឌអន្តរកាល នឹងត្រូវជំនួសដោយក្រមព្រហ្មទណ្ឌថ្មី ក្នុងឆ្នាំ ២០០៧។ មាត្រា ៤៦ នឹងត្រូវឈប់ប្រើ ហើយមាត្រាថ្មីស្តីពីការរំលោភសេចក្តីទុកចិត្ត នឹងចូលមកជំនួស។ មាត្រាថ្មីស្តីពីការរំលោភលើសេចក្តីទុកចិត្ត (ដោយសន្មតថា វាមិនរងការផ្លាស់ប្តូរណាមួយ មុនពេលប្រកាសអោយប្រើនេះទេ) នឹងមានភាពងាយយល់ជាងមាត្រាដែលមាន នាពេលបច្ចុប្បន្ននេះ

> *ការរំលោភសេចក្តីទុកចិត្តកើតឡើង នៅពេលដែលយោងតាមបុរេនិច្ឆ័យនៃអ្នកឯទៀត ជនម្នាក់បានតែបន្លំមូលនិធិ ទ្រព្យមានតម្លៃ ឬទ្រព្យណាមួយ ដែលគេបានប្រគល់អោយទទួលខុសត្រូវ ហើយជននោះបានយល់ព្រមទទួលវត្ថុនោះ ទៅតាមលក្ខខណ្ឌនៃការសងវិញ ប្រគល់អោយវិញ ឬប្រើប្រាស់វាតាមរបៀបកំណត់មួយ ។*

មាត្រាថ្មីដែលចែងពីការរំលោភលើសេចក្តីទុកចិត្ត នឹងមិនខុសគ្នាខ្លាំង ពីមាត្រាដែលស្ថិតនៅជាធរមានសព្វថ្ងៃនេះប៉ុន្មានទេ។ វាបន្តផ្តោតទៅលើធាតុផ្សំសំភារៈទាំងបីដូចគ្នា និងបញ្ចូលធាតុផ្សំផ្នែកសតិដូចគ្នា។ ប្រការសំខាន់ជាងគេគឺ គេបានលុបចោលពាក្យមួយចំនួន ដែលបានបង្កបញ្ហាដូចដែលបានបកស្រាយមាត្រា ៤៦។ ឧទាហរណ៍ មាត្រានៃច្បាប់ព្រហ្មទណ្ឌថ្មី លែងមាននិយាយដល់ប្រភេទជាក់លាក់នៃកិច្ចសន្យា ដែលគេបានបង្កើតឡើងដោយការទុកចិត្តប្រគល់ទ្រព្យទៅអោយអ្នកដទៃ ឬការយោងទៅលើដើមចោទដែលជាម្ចាស់ជាអ្នកមានទ្រព្យ ឬជាអ្នកកាន់កាប់ទ្រព្យទៀតហើយ។ ការផ្លាស់ប្តូរទាំងនេះ ផ្តល់ប្រយោជន៍ច្រើន និងធ្វើអោយច្បាប់នេះមានភាពងាយយល់ និងងាយអនុវត្តជាងមុន។





[១៣] សូមមើល **កែវ តាម**, ជាដើមចោទ ទល់នឹង **ឈុន ណៃ សួរ** ជាចុងចោទ (តុលាការកំពូលនៃកម្ពុជា, រឿងក្តីព្រហ្មទណ្ឌលេខ ៦២, ចុះថ្ងៃ ទី ៤-កញ្ញា-២០០១។ សាលក្រមលេខ ៤ ចុះថ្ងៃទី ៩-មករា-២០០២)។

# ការអនុវត្តន៍មិនត្រឹមត្រូវ នៃមាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្ត នៅក្នុងប្រទេសកម្ពុជា

## ១. ការអនុវត្តន៍មិនត្រឹមត្រូវនៃមាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្ត គឺជាបញ្ហាចោទមួយ

សហគមន៍អាជីវកម្ម បានព្រួយបារម្ភអំពីការអនុវត្តន៍មិនត្រឹមត្រូវ នូវមាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្ត។ ជាទូទៅ ការស្រាវជ្រាវដែលអនុគណៈកម្មាធិការពិសេស បានយល់ស្របជាមួយជំហររបស់សហគមន៍អាជីវកម្ម ស្តីពីការអនុវត្តន៍មិនត្រឹមត្រូវនូវបទល្មើសរំលោភលើសេចក្តីទុកចិត្ត។ គេឃើញថាបញ្ហាចោទរបស់ការអនុវត្តន៍មិនត្រឹមត្រូវនូវបទល្មើសរំលោភលើសេចក្តីទុកចិត្តមានទំហំតូច ប៉ុន្តែជាបញ្ហាធំសម្រាប់សហគមន៍អាជីវកម្ម។ ថ្វីបើស្ថិតិពុំមានលក្ខណៈជាតំណាងក្តី ស្ថិតិទាំងនោះឆ្លុះបញ្ចាំងពីប្រភេទនៃបញ្ហា និងថ្លៃចំណាយពាក់ព័ន្ធនឹងរឿងក្តីនៃការរំលោភលើសេចក្តីទុកចិត្ត។ ក្នុងស្ថិតិនោះ មិនត្រឹមតែមានចំនួនរឿងក្តីរំលោភលើសេចក្តីទុកចិត្តដ៏ច្រើន នៅក្នុងរាជធានីភ្នំពេញទេ ប៉ុន្តែទិន្នន័យ ស្ថិតិក៏បានចង្អុលបង្ហាញថា ការប្តឹងចោទពីបទល្មើសរំលោភលើសេចក្តីទុកចិត្ត បានបង្កើតសម្ពាធដ៏ធំទៅលើជនជាប់ចោទ ដោយសារគេអាចឃុំខ្លួន ជនជាប់ចោទមុនការជំនុំជំរះក្តីបានយ៉ាងងាយ ។[១៤]

- រឿងក្តីនៅភ្នំពេញប្រមាណ ៨,២% ជារឿងក្តីរំលោភលើសេចក្តីទុកចិត្ត (សូមមើលតារាង ២ នៃឧបសម្ព័ន្ធ ៦)។ ថ្វីបើគេមិនអាចកំណត់បានថា ក្នុងចំណោមរឿងក្តីទាំងនេះ មានរឿងក្តីចំនួនប៉ុន្មានដែលជារឿងក្តីមិនត្រឹមត្រូវនៃការរំលោភលើសេចក្តីទុកចិត្តក្តី វាពិតជាមានចំនួនច្រើន បើយោងតាមអង្គហេតុថា រឿងក្តីរំលោភលើសេចក្តីទុកចិត្ត មានចំនួនប្រមាណជិតពាក់កណ្តាលនៃចំនួនរឿងក្តីចោរកម្ម និងការបង្ករបួសស្នាម។
- ក្នុងចំណោមរឿងក្តីសរុបចំនួន ៣៤ នៅក្នុងទិន្នន័យពីបណ្តាញផ្សាយព័ត៌មាន ដែលមានព័ត៌មានស្តីពីការប្រើដីកាឃាត់ខ្លួន (សូមមើលឧបសម្ព័ន្ធ ៣) គេបានចេញដីកាឃាត់ខ្លួនជនជាប់ចោទនៅក្នុងរឿងក្តី ៣៣ (ពោលគឺ ៩៧%)។
- ក្នុងចំណោមរឿងក្តីសរុបចំនួន ៣១ នៅក្នុងទិន្នន័យពីបណ្តាញផ្សាយព័ត៌មាន ដែលមានព័ត៌មានស្តីពីការឃុំខ្លួន មុនការជំនុំជំរះ (សូមមើលឧបសម្ព័ន្ធ ៣) គេបានឃុំខ្លួនជនជាប់ចោទនៅក្នុងរឿងក្តី ២៩ (ពោលគឺ ៩៤%)។
- ដើមចោទនៅក្នុងរឿងក្តីចំនួន ១៣ ក្នុងចំណោមរឿងក្តីសរុបចំនួន ៣៦ នៅក្នុងទិន្នន័យពីបណ្តាញផ្សាយព័ត៌មាន បានទាមទារសំណងជំងឺចិត្តលើសពី ១០០ ០០០ ដុល្លារអាមេរិក។

[១៤] ទិន្នន័យផ្តល់ដោយក្រសួងយុត្តិធម៌។

សេចក្តីណែនាំរួម របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល បានទទួលស្គាល់ថា ការអនុវត្តន៍ច្បាប់ព្រហ្មទណ្ឌទាក់ទងនឹងការរំលោភលើសេចក្តីទុកចិត្តនៅក្នុងតុលាការ មិនទាន់មានភាពត្រូវវគ្គាឡើយ ហើយបានបញ្ជា "តុលាការខេត្ត-ក្រុង និងការិយាល័យព្រះរាជអាជ្ញាទាំងអស់ អោយយកចិត្តទុកដាក់ និងយកគោលគំនិតទាំងឡាយដែលមានចែងនៅក្នុង មាត្រា ៤៦ មកគិតពិចារណា។" ជាពិសេស សេចក្តីណែនាំរួមនោះ បានបញ្ជាក់ច្បាស់ថា ភាពខុសគ្នារវាងវិវាទរដ្ឋប្បវេណី ដែលកើតចេញមកពីការខកខានមិនបានបំពេញតាមកាតព្វកិច្ចនៃកិច្ចសន្យា និងវិវាទដែលកើតចេញមក សកម្មភាពដែលជាធាតុផ្សំនៃការរំលោភលើសេចក្តីទុកចិត្ត នៅតែជាបញ្ហាដែលគេត្រូវបកស្រាយបំភ្លឺ។

គេឃើញថា ទាំងរាជរដ្ឋាភិបាល ទាំងសហគមន៍អាជីវកម្ម ព្រួយបារម្ភដូចគ្នា អំពីភាពមិនត្រឹមត្រូវនៃបណ្តឹករណី រំលោភលើសេចក្តីទុកចិត្ត។ ថ្វីបើបច្ចុប្បន្ននេះ យើងមានការលំបាកក្នុងការកំណត់អោយបានច្បាស់អំពីទំហំនៃបញ្ហាក្តី គេឃើញច្បាស់ថា ទាំងរាជរដ្ឋាភិបាល ទាំងសហគមន៍អាជីវកម្មបានទទួលស្គាល់សារៈសំខាន់នៃបញ្ហាចោទនេះ និងថាវាជះឥទ្ធិពលអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជា។

## ២. ការអនុវត្តន៍មិនត្រឹមត្រូវនៃមាត្រាស្តីពីការរំលោភលើសេចក្តីទុកចិត្តៈ មូលហេតុ និងរបៀបប្រព្រឹត្តទៅរបស់វា

### ក. វិវាទកិច្ចសន្យាអាចក្លាយទៅជាការប្តឹងចោទប្រកាន់ពីបទរំលោភលើសេចក្តីទុកចិត្ត

សេចក្តីណែនាំរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល ទទួលស្គាល់ថា កន្លងមកនេះ អាជ្ញាធរយុត្តិធម៌មិនបានអនុវត្តមិនត្រឹមត្រូវ នូវបទល្មើសរំលោភលើសេចក្តីទុកចិត្ត ចំពោះវិវាទកិច្ចសន្យា និងវិវាទរដ្ឋប្បវេណីផ្សេងៗទៀតដែលគេគួរដោះស្រាយទៅតាម នីតិវិធីនៃច្បាប់រដ្ឋប្បវេណីជាជាងតាមច្បាប់ព្រហ្មទណ្ឌ។

*ភាពខុសគ្នារវាងវិវាទរដ្ឋប្បវេណី ដែលកើតចេញមកពីការខកខានមិនបានបំពេញតាមកាតព្វកិច្ចនៃកិច្ចសន្យា និងវិវាទដែលកើតចេញមកពីសកម្មភាពដែលជាធាតុនៃ ការរំលោភលើសេចក្តីទុកចិត្ត នៅតែជាបញ្ហាដែលគេត្រូវបកស្រាយបំភ្លឺ។*[១៥]

លើសពីនេះ សេចក្តីណែនាំរួមនោះ បានបញ្ជាក់យ៉ាងច្បាស់ថា គេមិនគួរប្រើប្រការទាំងឡាយរបស់បទល្មើសរំលោភលើសេចក្តីទុកចិត្ត នៅក្នុងករណីរឿងក្តីដែលគ្មានធាតុផ្សំចាំបាច់នៃបទល្មើសរំលោភលើសេចក្តីទុកចិត្តទេ។

*ទោះបីអ្នកទទួលទ្រព្យទុក ខកខានមិនបានបំពេញកាតព្វកិច្ចរបស់គេ ដោយប្រការណាមួយក៏ដោយ ដោយគិតរួមទាំងការសងទ្រព្យនោះទៅម្ចាស់ទ្រព្យវិញ ការខកខាននោះ មិនមែនជាអំពើគៃបន្លំយក ឬការលួចយកដែលជាកម្មវត្ថុនៃការរំលោភលើសេចក្តីទុកចិត្ត។*[១៦]

---

[១៥] សេចក្តីណែនាំការងាររួម លេខ ២ ចុះថ្ងៃទី ៨ សីហា ២០០៥ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល
[១៦] សេចក្តីណែនាំការងាររួម លេខ ២ ចុះថ្ងៃទី ៨ សីហា ២០០៥ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល

ក៏ប៉ុន្តែ សហគមន៍អាជីវកម្ម និងភាគីពាក់ព័ន្ធឯទៀតៗ បានសំដែងការបារម្ភថា មាត្រានៃការរំលោភលើសេចក្តីទុកចិត្ត មិនមែនសុទ្ធតែត្រូវគេអនុវត្តដោយត្រឹមត្រូវ និងស្របទៅតាមសេចក្តីណែនាំរួមនោះឡើយ។ ការត្អូញត្អែរជាប្រចាំជាងគេមួយ គឺគេបានចាត់ទុកវិវាទកិច្ចសន្យាសាមញ្ញៗ ថាជាករណីព្រហ្មទណ្ឌនៃការរំលោភលើសេចក្តីទុកចិត្ត ព្រោះគេមិនយកលក្ខខណ្ឌ ដែលទ្រព្យត្រូវតែបានគេប្រគល់ឱ្យជនជាប់ចោទទទួលខុសត្រូវ និងចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលជាធាតុផ្សំមួយ នៃបទល្មើសរំលោភលើសេចក្តីទុកចិត្តមកអនុវត្តតាមឡើយ។ អ្នកផ្តល់សម្ភាសន៍ស្ទើរតែគ្រប់រូប ដែលជាអាជីវករ ឬមេធាវី ជាជនកម្ពុជា ឬជនបរទេស បាននិយាយត្អូញត្អែរអំពីបញ្ហានេះ ។[១៧] អ្នកឆ្លើយអង្កេតទាំង ១១ នាក់ (សូមមើល ឧបសម្ព័ន្ធ ៤) បានបញ្ជាក់ថា ការអនុវត្តន៍ត្រឹមត្រូវនូវមាត្រានៃការរំលោភលើសេចក្តីទុកចិត្ត ត្រូវបានប្រព្រឹត្តទៅ "ស្ទើរតែមិនដែលសោះ" ឬ "ម្តងម្កាល"។

វិវាទកិច្ចសន្យាភាគច្រើន មិនអាចត្រូវប្តឹងចោទថាជាការរំលោភលើសេចក្តីទុកចិត្តឡើយ ព្រោះវិវាទកិច្ចសន្យាគ្មាន ធាតុផ្សំសំភារៈ និងធាតុផ្សំផ្នែកសតិ របស់បទល្មើសរំលោភលើសេចក្តីទុកចិត្តទេ។ ជាឧទាហរណ៍ ការរំលោភលើសេចក្តីទុកចិត្តទាមទារដើមចោទត្រូវតែទុកចិត្តប្រគល់ទ្រព្យរបស់ខ្លួនអោយទៅជនជាប់ចោទជួយមើលថែ ហើយជនជាប់ចោទបានសន្យាប្រគល់សងទ្រព្យនោះមកវិញ ឬមួយប្រើវាទៅតាមគោលដៅកំណត់ដ៏ជាក់លាក់ណាមួយ។ មានកិច្ចសន្យាតែមួយចំនួនតូចប៉ុណ្ណោះ ដែលក្នុងនោះភាគីមួយទុកចិត្តប្រគល់អ្វីមួយ ហើយភាគីមួយទៀតត្រូវប្រគល់វាសងមកវិញ។ កិច្ចសន្យា លក់ ទិញ ទំនិញដែលជាទម្រង់ទូទៅបំផុតនៃកិច្ចសន្យា មិនអាចក្លាយទៅជាការរំលោភលើសេចក្តីទុកចិត្តឡើយ ព្រោះក្នុងនោះ គ្មានភាគីណាមួយបានទុកចិត្តប្រគល់ទ្រព្យខ្លួនអោយភាគីមួយទៀតទទួលខុសត្រូវ ហើយទ្រព្យនោះត្រូវតែប្រគល់សងមកម្ចាស់ដើមវិញនោះឡើយ។

ទោះបីមានកិច្ចសន្យាជាប់ទាក់ទងនឹងការប្រគល់ទ្រព្យពិតមែនក្តី ការថ្លោះធ្លោយរបស់ភាគីមួយ ក្នុងការបំពេញចិត្តភាគីម្ខាងទៀត ក៏នៅតែមិនអាចក្លាយទៅជាការប្តឹងចោទបទព្រហ្មទណ្ឌជាស្វ័យប្រវត្តិបានឡើយ។ បរាជ័យនៃកិច្ចសន្យាមួយ អាចបង្កអោយមានការប្តឹងទាមទារជម្ងឺចិត្តតាមនិតិវិធីរដ្ឋប្បវេណី ប៉ុន្តែមិនអាចក្លាយទៅជាការប្តឹងចោទ ពីបទរំលោភលើសេចក្តីទុកចិត្តទេ លុះណាតែមានភស្តុតាងបញ្ជាក់ថា ការមិនបានបំពេញតាមកិច្ចសន្យាកើតឡើងដោយសារបំណងទុច្ចរិតរបស់ជនជាប់ចោទ។ បរាជ័យនៃអាជីវកម្ម ឬការខាតបង់ទ្រព្យតែមួយមុខ មិនមែនជាភស្តុតាងផ្ទាល់នៃចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឡើយ ។ត្រូវតែមានភស្តុតាងថាជនជាប់ចោទបានទទួលយកទ្រព្យនោះ ដោយចិត្តប៉ុនប៉ងលួច ឬគៃបន្លំ ។ល។

គេបានចងក្រងករណីសិក្សាចំនួនប្រាំ ដើម្បីបកស្រាយបង្ហាញពីប្រភេទផ្សេងៗនៃបញ្ហាចោទ ដែលធ្វើអោយសហគមន៍ អាជីវកម្មព្រួយបារម្ភ ទាក់ទងនឹងបទព្រហ្មទណ្ឌនៃការរំលោភលើសេចក្តី

១៧ ជាបន្ថែមលើការទទួលស្គាល់បញ្ហាចោទនេះ នៅក្នុងសេចក្តីណែនាំរួម ស្តីពីការរំលោភលើសេចក្តីទុកចិត្ត បញ្ហានេះក៏មានការទទួលស្គាល់ ពីសំណាក់បញ្ញាវ័ន្តច្បាប់កម្ពុជាដែរ។ ក្នុងចំណោមនោះ លោក **កុយ នាម** បានសរសេរវគ្គមួយទាំងមូលនៃ អត្ថបទស្តីពីការរំលោភលើសេចក្តីទុកចិត្ត ដើម្បីពន្យល់ពីហេតុថា ការខកខានមិនបានបំពេញកាតព្វកិច្ចកិច្ចសន្យា ឬការចរចាកិច្ចសន្យា មិនមែនជាករណីរំលោភលើសេចក្តីទុកចិត្ត ដោយស្វ័យប្រវត្តិនោះឡើយ (សូមមើលឧបសម្ព័ន្ធ ៥)។

ទុកចិត្ត (សូមអានឧបសម្ព័ន្ធ ២)។ ករណីសិក្សា ១ ២ និង ៣ ត្រូវគេចងក្រងឡើង ដោយផ្អែកលើការសម្ភាសន៍ជាមួយបុគ្គល ដែលប្តឹងចោទគេអំពីបទល្មើសរំលោភលើសេចក្តីទុកចិត្ត និងមេធាវីដែលការពារមនុស្សនៅក្នុងក្តីបែបនេះ។ ករណីសិក្សា ៤ និង ៥ ផ្អែកលើសេចក្តីសម្រេចរបស់តុលាការនៅក្នុងរឿងក្តីពាក់ព័ន្ធនឹងបទល្មើសរំលោភលើសេចក្តីទុកចិត្ត។

ករណីសិក្សា ១ និង ៣ គឺជាឧទាហរណ៍នៃរបៀបដែលវិវាទកិច្ចសន្យាសាមញ្ញៗ បានក្លាយទៅជាបណ្តឹងទាក់ទងនឹងការរំលោភលើសេចក្តីទុកចិត្ត[១៨]។ នៅក្នុងករណីសិក្សា ១ លោក **គ** ជាអ្នករំលោភលើកិច្ចសន្យា ដោយសារមិនបានផ្គត់ផ្គង់ទំនិញ តាមការព្រមព្រៀងគ្នា។ ប៉ុន្តែគេបានប្តឹងចោទលោក **ក** ពីបទរំលោភលើសេចក្តីទុកចិត្ត នៅពេលដែលលោកបដិសេធមិនព្រមបង់ប្រាក់តាមកិច្ចសន្យា។ វាជាការច្បាស់ណាស់ថា រឿងនេះមិនអាចជារឿងក្តីនៃការរំលោភសេចក្តីទុកចិត្តនោះទេ ព្រោះលោក **គ** មិនដែលបានទុកចិត្តប្រគល់អ្វីមួយអោយទៅលោក **ក** ទេ ហើយលោក **ក** ក៏មិនបានតែបន្លំអ្វីពីលោក **គ** ដែរ។ ផ្ទុយទៅវិញ គេឃើញថា គឺលោក **គ** ទៅវិញទេ ដែលបានរំលោភកិច្ចសន្យាលក់ទំនិញ។ រឿងក្តីមិនត្រឹមត្រូវនៃការរំលោភលើសេចក្តីទុកចិត្តនេះ ធ្វើអោយលោក **ក** ខាតបង់ប្រាក់អស់ ៦០ 000 ដុល្លា ជាប់ពន្ធនាគារអស់ពីរបីសប្តាហ៍ ព្រមទាំងបាត់បង់កិត្តិយស និងអាជីវកម្មអស់ជាច្រើន។

ករណីសិក្សា ៣ ក៏មិនអាចជាការរំលោភលើសេចក្តីទុកចិត្តដែរ ព្រោះដើមចោទមិនដែលបានទុកចិត្តប្រគល់អ្វីមួយទៅអោយក្រុមហ៊ុន **ង** ឡើយ ហើយក៏គ្មានភស្តុតាងណាមួយបញ្ជាក់ថាក្រុមហ៊ុន **ង** បានតែបន្លំអ្វីមួយដែរ។ តាមពិតទៅ វាក៏មិនមែនជាការរំលោភកិច្ចសន្យាដែរ។ កិច្ចសន្យារវាងដើមចោទ និងចុងចោទ គឺជាកិច្ចសន្យាសម្រាប់រយៈពេលកំណត់មួយ ហើយវាត្រូវរសាយដោយខ្លួនឯង នៅពេលចប់រយៈពេលនោះ។ ការប្តឹងចោទទំនងជាកើតឡើង ដោយសារតែដើមចោទមានបំណងចង់រារាំង មិនអោយក្រុមហ៊ុន **ង** អាចរកអ្នកចែកចាយផ្សេងទៀតសម្រាប់លក់កុំព្យូទ័ររបស់គេ។ ទីបំផុត ដើមចោទបានទទួលជោគជ័យ ឯក្រុមហ៊ុន **ង** បានដកខ្លួនចេញពីទីផ្សារកម្ពុជាទាំងស្រុង។

### ខ. ថ្លៃឈ្នួលក្រៅផ្លូវការទំនងជាដើរតួនាទីយ៉ាងសំខាន់ ក្នុងរឿងក្តីមិនត្រឹមត្រូវ នៃការរំលោភលើសេចក្តីទុកចិត្ត

តើស្ថានភាពនៅក្នុងករណីសិក្សា ១ និង ៣ ដែលមិនជាប់ទាក់ទងនឹងការរំលោភលើសេចក្តីទុកចិត្តសោះនេះ អាចក្លាយ ទៅជាការចោទប្រកាន់បទព្រហ្មទណ្ឌតាមរបៀបណា? អ្នកដែលយើងបានសម្ភាសជាច្រើន បានទម្លាក់កំហុសទាក់ទងនឹងរឿងក្តីមិនត្រឹមត្រូវនៃការរំលោភលើសេចក្តីទុកចិត្តទៅលើបុគ្គលទាំងឡាយ ដែលព្យាយាមទារថ្លៃឈ្នួលក្រៅផ្លូវការ។ អ្នកដែល យើងបានសម្ភាសមួយចំនួនបានបង្ហាញថា គេអាចសូកប៉ាន់ព្រះរាជអាជ្ញា អោយបើករឿងក្តីព្រហ្មទណ្ឌនៃការរំលោភលើសេចក្តីទុកចិត្ត ប្រឆាំងទល់នឹងដៃគូ ឬគូប្រជែងអាជីវកម្មណាម្នាក់បាន។ អ្នកផ្តល់សម្ភាសម្នាក់ដែលជាមេធាវីកម្ពុជា បានពោលថា ប្រាក់ឈ្នួលនេះអាចមានទំហំតិចតួច ប្រមាណជា ១ 000 ដុល្លា សម្រាប់រឿង

---

[១៨] ករណីសិក្សាទាំងនេះ ផ្អែកលើបទពិសោធន៍របស់មនុស្សពិតប្រាកដ។ ក៏ប៉ុន្តែ ព័ត៌មានដែលអាចកំណត់អត្តសញ្ញាណរបស់បុគ្គលនៅក្នុងរឿងរ៉ាវទាំងនេះ ត្រូវបានផ្លាស់ប្តូរ ដើម្បីបិទបាំងអត្តសញ្ញាណពិតរបស់អ្នកចូលរួម។

ក្តីតូចបង្គួរ ហើយវាអាចខ្ពស់ច្រើនជាងនេះ បើសិនជារឿងក្តីនោះជាប់ទាក់ទងនឹងទំហំទឹកប្រាក់សំណង ច្រើន។ អ្នកឆ្លើយអង្កេតប្រាំបួននាក់ ក្នុងចំណោមដប់នាក់ បាននិយាយថា បណ្តឹងពីបទរំលោភលើសេចក្តីទុកចិត្ត ត្រូវគេប្តឹងដោយមិនត្រឹមត្រូវ "ម្តងម្កាល" "ជាញឹកញយ" ឬ "ស្ទើរតែជានិច្ចកាល"។ អ្នកឆ្លើយអង្កេតប្រាំបីនាក់ក្នុងចំណោមដប់មួយនាក់(សូមមើលឧបសម្ព័ន្ធ៤) បាននិយាយថា"ស្ទើរតែជានិច្ចកាល" ថ្លៃឈ្នួលក្រៅផ្លូវការតែងតែជះឥទ្ធិពលទៅលើ រឿងក្តីរំលោភលើសេចក្តីទុកចិត្ត ចំណែកឯអ្នកឆ្លើយអង្កេតបីនាក់ទៀត និយាយថា ថ្លៃឈ្នួលក្រៅផ្លូវការជះឥទ្ធិពល ទៅលើរឿងក្តីរំលោភលើសេចក្តីទុកចិត្ត "ជាញឹកញាប់"។

ហេតុអ្វីបានជាដើមចោទចង់សូកប៉ាន់ ដើម្បីប្តឹងចោទអ្នកឯទៀត ពីបទល្មើសព្រហ្មទណ្ឌ? គេតែងនិយាយជារឿយៗថា គេបានប្រើបណ្តឹងមិនត្រឹមត្រូវនៃករណីរំលោភលើសេចក្តីទុកចិត្ត ធ្វើជាឧបករណ៍តថ្លៃគ្នា ដើម្បីដោះស្រាយបញ្ចប់វិវាទអាជីវកម្ម។ នៅពេលដែលការទាមទារប្រាក់សំណងនៃការរំលោភកិច្ចសន្យា តាមបណ្តឹងនៃនីតិវិធីរដ្ឋប្បវេណី អាចនឹងមានភាពស្មុគស្មាញ និងត្រូវចំណាយពេលអស់ច្រើន ពាក្យបណ្តឹងពីបទល្មើសរំលោភលើសេចក្តីទុកចិត្ត បានដាក់សម្ពាធយ៉ាងធំសម្បើមភ្លាមៗទៅលើជនជាប់ចោទ ជំរុញអោយគេដោះស្រាយវិវាទដែលមាន។

នៅក្នុងរឿងក្តីស្ទើរតែទាំងអស់ ពីបទល្មើសរំលោភលើសេចក្តីទុកចិត្ត គេតែងចេញដីកាឃុំខ្លួនចុងចោទ។ សេចក្តីសន្និដ្ឋាននេះ មានការគាំទ្រដោយព័ត៌មាននៅក្នុងមូលដ្ឋានទិន្នន័យនៃបណ្តាញផ្សាយព័ត៌មាននានា (សូមមើលឧបសម្ព័ន្ធ ៣)។ អ្នកផ្តល់សម្ភាសន៍ម្នាក់បាននិយាយថា វាជាទំលាប់ទូទៅសម្រាប់នគរបាល ក្នុងការចាប់ឃុំមនុស្សនៅល្ងាចថ្ងៃសុក្រ ហើយឃុំខ្លួន ជននោះ រហូតដល់ថ្ងៃអង្គារ ឬថ្ងៃពុធនៃសប្តាហ៍បន្ទាប់។ ជាបន្ថែមលើនោះ ជនជាប់ចោទត្រូវគេដាក់សម្ពាធនៅនឹងកន្លែង បង្ខំអោយសងប្រាក់ដែលគេចោទថាបានគៃបន្លំយក។ ឧទាហរណ៍ នៅក្នុងករណីសិក្សា ១ គេបានប្រាប់លោក **ក** ថា លោកអាច នឹងត្រូវគេដោះលែង បើសិនជាលោកសងប្រាក់ ចំនួន ៨០ ០០០ ដុល្លា ដែលគេបានចោទថាលោកបានគៃបន្លំយក។ គេឃើញថា ជួនកាលជនជាប់ចោទអាចត្រូវគេឃុំខ្លួន ក្នុងរយៈពេលវែងជាងការអនុញ្ញាតរបស់ច្បាប់កម្ពុជា ក្នុងគោលបំណងទាមទារអោយជនជាប់ចោទសងប្រាក់ដែលគេចោទថាលោកបានគៃបន្លំយកកាន់តែច្រើន និងដើម្បីដោះស្រាយបញ្ចប់រឿងក្តីមុនពេលដែលជនជាប់ចោទបង្ហាញខ្លួននៅមុខតុលាការ។

បើសិនជាជនជាប់ចោទបដិសេធមិនព្រមបង់ប្រាក់ គេនឹងបញ្ជូនជននោះទៅកាន់ចៅក្រមស៊ើបអង្កេត ហើយចៅក្រមនោះ នឹងបញ្ជាក់អំពីការចោទប្រកាន់ដំបូង អំពីការរំលោភលើសេចក្តីទុកចិត្ត។ អ្នកផ្តល់សម្ភាសន៍ទាំងឡាយបានថ្លែងថា នៅក្នុងរឿងក្តីស្ទើរតែទាំងអស់ គេបានឃុំខ្លួនជនជាប់ចោទមុនការជំនុំជំរះក្តី[១៩]។ មូលដ្ឋានទិន្នន័យនៃបណ្តាញផ្សាយព័ត៌មាន (ឧបសម្ព័ន្ធ ៣) មានព័ត៌មានត្រូវគ្នាជាមួយនឹងសេចក្តីសន្និដ្ឋាននេះ ដោយក្នុងចំណោម ៣១ រឿងក្តី មាន ២៩ ករណី (ត្រូវជា ៩៤%)

[១៩] ផ្អែកតាមព័ត៌មានដែលទទួលបានពីអ្នកផ្តល់សម្ភាសន៍ និងមូលដ្ឋានទិន្នន័យនៃបណ្តាញផ្សាយព័ត៌មាន សមាជិកទាំងឡាយនៃអង្គចៅក្រមបាន ថ្លែងថា អត្រានៃការឃុំខ្លួនមុនការជំនុំជំរះក្តី ក្នុងរឿងក្តីរំលោភលើសេចក្តីទុកចិត្ត "មានកំរិតទាបមែនទែន"។ ពួកគេបានអោយយោបល់ថា លទ្ធផលទាំងឡាយក្នុងមូលដ្ឋានទិន្នន័យនៃបណ្តាញផ្សាយព័ត៌មាន អាចឆ្លុះបញ្ចាំងពីគុណភាពនៃសារព័ត៌មាននៅកម្ពុជា។

ដែលនាំទៅដល់ការឃុំខ្លួនមុនការជំនុំជំរះក្តី ។ រយៈពេលដែលមនុស្សទាំងឡាយត្រូវជាប់ឃុំ មុនការជំនុំជំរះក្តីប្រែប្រួលខុសគ្នាជាខ្លាំង ។ យោងតាមមូលដ្ឋានទិន្នន័យនៃបណ្តាញផ្សាយព័ត៌មានអ្នកខ្លះត្រូវជាប់ឃុំ មុនការជំនុំជំរះក្តីអស់រាប់ខែ ឯអ្នកខ្លះទៀត ដែលអាចដោះស្រាយបង់ប្រាក់ធានាខ្លួន បានត្រូវជាប់ឃុំតែក្នុងរវាងពីរបីថ្ងៃប៉ុណ្ណោះ ។

ការឃុំខ្លួនមុនការជំនុំជំរះក្តី ជាប្រភពធំជាងគេនៃការដាក់សម្ពាធ ទៅលើជនជាប់ចោទ ។ អ្នកជំនួញទាំងឡាយដែលបានផ្តល់សម្ភាសន៍ បានយល់ស្របគ្នាថា ការជាប់ឃុំក្នុងពន្ធនាគារ ដោយសារតែវិវាទពាណិជ្ជកម្ម គឺជាអ្វីដែលគេចង់គេចអោយផុត ទោះត្រូវចំណាយអស់ប៉ុន្មានក៏ដោយ ។ នៅក្នុងករណីសិក្សា ១ គឺដោយសារការមើលឃើញថា ខ្លួនត្រូវជាប់ឃុំមុនការជំនុំជំរះក្តីរាប់សប្តាហ៍ ឬរាប់ខែនេះហើយ ដែលបានជំរុញអោយលោក **ក** សុខចិត្តបង់ប្រាក់អស់ ៤០,០០០ ដុល្លា ដើម្បីបាននៅក្រៅឃុំ ។ ដូចគ្នានេះដែរ នៅក្នុងករណីសិក្សា ៣ ការគំរាមចាប់ខ្លួន និងឃុំខ្លួនមុនការជំនុំជំរះក្តី បានរារាំងមិនអោយបុគ្គលិកក្រុមហ៊ុន **ខ** ចូលមកក្នុងប្រទេសកម្ពុជា ទោះបីក្នុងដំណើរទេសចរណ៍ក៏មិនហ៊ានមកដែរ ។ អ្នកឆ្លើយអង្កេតចំនួនប្រាំមួយ ក្នុងចំណោមប្រាំបី បាននិយាយថា ពួកគេ "បារម្ភខ្លាំងណាស់" អំពីយថាភូតថាត្រូវជាប់ឃុំខ្លួនមួយរយៈ នៅក្នុងពន្ធនាគារដោយសាររឿងក្តីរំលោភលើសេចក្តីទុកចិត្ត ។ អ្នកផ្តល់សម្ភាសន៍ និងអ្នកឆ្លើយអង្កេតភាគច្រើន ក៏បានយល់ស្របគ្នាដែរថា ពួកគេបារម្ភខ្លាំងណាស់អំពីការខាតបង់ប្រាក់ ឬអាជីវកម្ម និងការបាត់បង់កិត្តិយស ដែលអាចនឹងកើតឡើង ។

ក្រោយពីត្រូវជាប់ឃុំមុនការជំនុំជំរះ ជនជាប់ចោទមានសិទ្ធិប្តឹងតវ៉ា ទៅចៅក្រមស៊ើបអង្កេតសុំអោយគេដោះលែងខ្លួន ។ បើសិនជាបណ្តឹងតវ៉ានោះ ត្រូវគេបដិសេធ ជនជាប់ចោទមានសិទ្ធិប្តឹងសាទុក្ខអំពីការសម្រេចនោះ ទៅតុលាការឧទ្ធរណ៍ ។ ក៏ប៉ុន្តែ ដំណើរការនេះអាចមានដំណើរយឺត និងគ្មានការធានាថា ជនជាប់ចោទនឹងត្រូវគេដោះលែងនោះឡើយ ។ ចន្លោះពេលនោះ ជនជាប់ចោទត្រូវនៅជាប់ឃុំជាបន្ត ។ អ្នកផ្តល់សម្ភាសន៍មួយចំនួនបានចង្អុលបង្ហាញថា គេអាចបង់ប្រាក់ដើម្បីបានរួចខ្លួនពីការឃុំខ្លួនមុនជំនុំជំរះក្តីបាន ។ គេអាចហៅប្រាក់ដែលគេបង់នោះថាជា "ប្រាក់ធានាខ្លួន" ប៉ុន្តែ តាមការពិតវាជាថ្លៃចំណាយក្រៅផ្លូវការ ដើម្បីអោយបានរួចខ្លួនពីការឃុំខ្លួន ។ គេមានសំណាងតិចណាស់ក្នុងការទទួលបានប្រាក់នោះមកវិញ ទោះបីជាជនជាប់ចោទឈ្នះក្តី ដោយត្រូវគេលើកលែងពីការចោទប្រកាន់ក៏ដោយ ។

អ្នកផ្តល់សម្ភាសន៍ភាគច្រើនបានយល់ស្របគ្នាថា ចំនួនទឹកប្រាក់ដែលត្រូវចំណាយ ដើម្បីបានរួចពីការឃុំខ្លួនមុនការជំនុំជំរះក្តី មានទំហំខុសៗគ្នា ដោយអាស្រ័យទៅតាមចំនួនទឹកប្រាក់ដែលជាកម្មវត្ថុនៃបណ្តឹង ។ កាលណាដើមចោទប្តឹងទាមទារកាន់តែច្រើន នោះចំនួនទឹកប្រាក់ដែលចាំបាច់ត្រូវបង់ដើម្បីបានរួចខ្លួនពីពន្ធនាគារ ក៏កាន់តែច្រើនដែរ ។ អ្នកផ្តល់សម្ភាសម្នាក់បានថ្លែងថា គេត្រូវចាយអស់យ៉ាងតិច ២០ ០០០ ដុល្លា ។ នៅក្នុងករណីសិក្សា ១ លោក **ក** បានបង់ប្រាក់អោយគេអស់ ៤០ ០០០ ដុល្លា ឬស្មើនឹងពាក់កណ្តាលនៃទឹកប្រាក់ ដែលគេចោទថាគាត់បានគៃបន្លំ ។ រឿងក្តីចំនួន ១៣ ក្នុងចំណោមរឿងក្តី

[20] ជាឧទាហរណ៍ ស្ត្រីនៅក្នុងអង្គហេតុ ៤ ពិតជាបានចេញផុតពីការឃុំខ្លួនមុនការជំនុំជំរះក្តី ក្រោយពីបានប្តឹងតវ៉ាជាបន្តបន្ទាប់ រហូតដល់ តុលាការកំពូល ។ គាត់បានជាប់ឃុំមុនការជំនុំជំរះ អស់រយៈពេល ៨ ខែ ក្នុងពេលដំណើរការបណ្តឹងសាទុក្ខនោះ ។

៣៦ នៅក្នុងមូលដ្ឋានទិន្នន័យនៃបណ្ដាញផ្សាយព័ត៌មាន ដែលស្រង់ចេញពីបណ្ដាសារព័ត៌មានកម្ពុជា សំណុំរឿងជំងឺចិត្តដែលអ្នកដើមចោទបានប្ដឹងទាមទារ មានលើសពី ១០០ ០០០ ដុល្លា។ បើសិនជាមានការបង់ប្រាក់ធានាខ្លួនចេញក្រៅការឃុំខ្លួន ប្រាក់ធានាខ្លួននៅក្នុងរឿងក្ដីនីមួយៗ មានចំនួនដល់ទៅរាប់ម៉ឺនដុល្លា។អ្នកផ្ដល់សម្ភាសន៍មួយចំនួនបានចង្អុលបង្ហាញថានៅពេលដែលគេបានបង់"ប្រាក់ធានាខ្លួន" រួចហើយ បណ្ដឹងចោទប្រកាន់ទាំងឡាយ ត្រូវដើមចោទដកលែងប្ដឹងវិញ ឬមួយត្រូវចៅក្រម បដិសេធមិនចាត់ការ ឬមួយសកម្មភាពទាំងឡាយទាក់ទងនឹងរឿងក្ដីត្រូវបញ្ចប់តែម្ដង។

អ្នកផ្ដល់សម្ភាសន៍ទាំងឡាយបានចង្អុលបង្ហាញថា រឿងក្ដីមិនត្រឹមត្រូវពីបទរំលោភលើសេចក្ដីទុកចិត្តភាគច្រើន ត្រូវគេបញ្ចប់តាមរយៈការបង់ប្រាក់តាមរូបភាពផ្សេងៗ មុនមានការជំនុំជំរះក្ដី ព្រោះមានមនុស្សតិចណាស់ ដែលចង់ប្រថុយនឹងគ្រោះថ្នាក់ ដោយត្រូវគេរកឃើញថាខ្លួនមានទោស និងត្រូវគេកាត់ទោសអោយជាប់ពន្ធនាគារ។ ការណ៍នេះអាចបកស្រាយ ភាពចំឡែកជាក់ស្ដែងមួយនៃព័ត៌មានដែលគេប្រមូលពីសារព័ត៌មានកម្ពុជាទាំងឡាយ ពោលគឺ គេឃើញមានបណ្ដឹងអំពីការរំលោភសេចក្ដីទុកចិត្តយ៉ាងច្រើន លើសពីចំនួនក្ដីដែលគេបានជំនុំជំរះ។ ថ្វីបើមានមូលហេតុជាច្រើនទាក់ទងនឹងបាតុភូតនេះ ដោយរួមមានទាំងធម្មជាតិគ្មានលក្ខណៈជាតំណាងរបស់សំណាកផងដែរ គេក៏ឃើញមានភាពត្រូវគ្នាជាមួយនឹងសំដីរបស់អ្នក ផ្ដល់សម្ភាសន៍ទាំងឡាយថា រឿងក្ដីទាក់ទងនឹងការរំលោភលើសេចក្ដីទុកចិត្តភាគច្រើន តែងត្រូវគេដោះស្រាយបញ្ចប់មុនការជំនុំជំរះក្ដី។

### គ. ប្រព័ន្ធយុត្តិធម៌អាចធ្វើការបានល្អ

នៅពេលដែលជារឿយៗ គេឃើញថា មាត្រាស្ដីពីការរំលោភលើសេចក្ដីទុកចិត្ត ត្រូវគេអនុវត្តខុសគេក៏ឃើញដែរថា រឿងក្ដីទាំងឡាយដែលជាប់ទាក់ទងនឹងប្រជាពលរដ្ឋក្រីក្រ ហើយបញ្ហាលុយមិនចូលមកពាក់ព័ន្ធទេនោះ រឿងក្ដីនោះ បានប្រព្រឹត្តទៅធម្មតាជាងនេះ។ ជាឧទាហរណ៍ ករណីសិក្សាទី ២ គឺជាឧទាហរណ៍ពីរបៀបដែលប្រព័ន្ធនេះត្រូវធ្វើការ។ រឿងក្ដីបានចាប់ផ្ដើមចេញដំណើរយ៉ាងអាក្រក់ ដោយអ្នកស្រី ខ ត្រូវគេប្ដឹងចោទដោយមិនត្រឹមត្រូវ ពីបទរំលោភលើសេចក្ដីទុកចិត្ត។ គេបានទុកចិត្តប្រគល់ទ្រព្យអោយគាត់ ហើយគាត់បានសន្យាថាសងវិញ តែគាត់ពិតជាមិនអាចសងវិញបានមែន។ ក៏ប៉ុន្តែ គាត់បានបាត់ខ្សែកនោះដោយអចេតនា។ គាត់មិនបានយកវាទៅបញ្ចាំ លក់ ឬបដិសេធមិនទទួលស្គាល់ថាគាត់បានខ្ចីពីគេឡើយ។ ដោយហេតុនេះ គាត់គ្មានចេតនាប្រព្រឹត្តបទល្មើស ដែលចាំបាច់សម្រាប់ការចោទប្រកាន់ពីការរំលោភលើសេចក្ដីទុកចិត្តឡើយ។ គាត់ត្រូវគេចាប់ឃុំខ្លួនមុនការជំនុំជំរះក្ដីអស់រយៈពេលពីរខែ ដែលជាការណ៍មួយមិនសមថាចាំបាច់ឡើយ។ ក៏ប៉ុន្តែ មេធាវីរបស់គាត់មានលទ្ធភាពធានាគាត់អោយនៅក្រៅឃុំ ដោយមិនបាច់បង់ប្រាក់អោយតុលាការឡើយ។ មេធាវី របស់គាត់បានជជែកវែកញែកជាមួយតុលាការ ប្រកបដោយជោគជ័យថា អង្គហេតុនៃរឿងក្ដីនេះបង្ហាញថា អ្នកស្រី ខ គ្មានចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយទេ។ ចៅក្រមស៊ើបអង្កេតបានយល់ព្រមតាម និងបានរំសាយរឿងក្ដីនោះ។ក្រោយពីបានចាប់ផ្ដើមយ៉ាងអាក្រក់ គេសម្រេចបានលទ្ធផលត្រឹមត្រូវដោយអ្នកស្រី ខ មិនបានបង់ប្រាក់ឈ្នួល"មិនផ្លូវការ" ណាមួយឡើយ។

# រឿងក្ដីមិនត្រឹមត្រូវនៃការរំលោភលើសេចក្ដីទុកចិត្ត ធ្វើអោយសេដ្ឋកិច្ចកម្ពុជា ខាតបង់អស់រាប់លានដុល្លារ

គេមិនអាចទទួលបានជាសាធារណៈ នូវព័ត៌មានស្ថិតិនៃរឿងក្ដីរំលោភលើសេចក្ដីទុកចិត្តទេ ហើយការណ៍នេះធ្វើអោយគេជួបការលំបាក ក្នុងការគណនាចំនួនរឿងក្ដីរំលោភលើសេចក្ដីទុកចិត្ត ដែលបានកើតមានក្នុងមួយឆ្នាំៗ នៅកម្ពុជា។ យោងតាមទិន្នន័យដែលក្រសួងយុត្តិធម៌បានផ្ដល់ជូនអនុគណៈកម្មាធិការពិសេស សម្រាប់រៀបចំរបាយការណ៍នេះ គេឃើញថា ចំនួនរឿងក្ដីរំលោភលើសេចក្ដីទុកចិត្តក្នុងមួយឆ្នាំៗ អាចមានរាប់រយ (សូមមើលតារាង ១ ឧបសម្ព័ន្ធ ៦)[២១] ។ គ្មានមធ្យោបាយណាមួយអាចប៉ាន់ស្មានអោយបានជាក់លាក់ថា ក្នុងចំណោមរឿងក្ដីទាំងនោះ មានប៉ុន្មានភាគរយជារឿងក្ដីមិនត្រឹមត្រូវនោះទេ។ អ្នកឆ្លើយអង្កេតប្រាំបួននាក់ ក្នុងចំណោមដប់នាក់ បាននិយាយអំពីភាពញឹកញាប់នៃបណ្ដឹងពីបទល្មើសរំលោភលើសេចក្ដីទុកចិត្ត ត្រូវគេប្ដឹងដោយមិនត្រឹមត្រូវ ថាកើតមាន "ម្ដងម្កាល" "ជាញឹកញយ" ឬ "ស្ទើរតែជានិច្ចកាល" ហើយអ្នកផ្ដល់សម្ភាសន៍ភាគច្រើន បានយល់ស្របគ្នាថា រឿងក្ដីមិនត្រឹមត្រូវពីបទរំលោភលើសេចក្ដីទុកចិត្ត គឺជាបញ្ហាចោទទូទៅ។ ប៉ុន្តែ ដោយសារការអង្កេត និងការសម្ភាសន៍ទាំងនោះ គ្មានលក្ខណៈជាតំណាងទេ នោះការរកឃើញនេះមិនអាចនិយាយចំពោះគ្រប់រឿងក្ដីរំលោភលើសេចក្ដីទុកចិត្តបានឡើយ។ ទោះយ៉ាងណាក៏ដោយ វាពិតជាគួរអោយភ្ញាក់ផ្អើលខ្លះដែរចំពោះតួលេខថា ៨,២% នៃរឿងក្ដីទាំងអស់នៅភ្នំពេញ ជារឿងក្ដីពាក់ព័ន្ធនឹងការរំលោភលើសេចក្ដីទុកចិត្ត។ គេឃើញថារឿងក្ដីចោរកម្ម ឬបង្ករបួសស្នាមដោយចេតនា មានប្រមាណជាពាក់កណ្ដាលនៃរឿងក្ដីរំលោភលើសេចក្ដីទុកចិត្ត (សូមមើលតារាង ២ នៃឧបសម្ព័ន្ធ ៦)។ ជាបញ្ចប់ ព័ត៌មានដែលគេប្រមូលបានសម្រាប់របាយការណ៍នេះបង្ហាញថា បញ្ហានេះមានទំហំតូច តែមានសារៈសំខាន់ចំពោះសហគមន៍ អាជីវកម្ម ទោះបីជាយើងគ្មានមធ្យោបាយសម្រាប់ប៉ាន់ស្មានអោយបានជាក់លាក់ អំពីចំនួនរឿងក្ដីមិនត្រឹមត្រូវនៃការរំលោភលើសេចក្ដីទុកចិត្ត ដែលគេបានប្ដឹងក្នុងមួយឆ្នាំៗ ក៏ដោយ។

ព័ត៌មានដែលយើងបានប្រមូលសម្រាប់របាយការណ៍នេះ គ្មានលក្ខណៈជាតំណាងទេ។ ការអង្កេត និងសម្ភាសន៍ទាំងនេះ ទំនងជាសុទ្ធតែល្អៀង ដោយសារបញ្ហាជ្រើសរើសខ្លួនឯងក្នុងចំណោមអ្នកឆ្លើយតប។ ដោយហេតុនេះ គ្មានមធ្យោបាយណាមួយ សម្រាប់ធ្វើចំណោលចេញពីលទ្ធផលនៃការសម្ភាសន៍ ឬអង្កេត ទៅរកតួលេខទូទៅមួយស្ដីពីឥទ្ធិពលរបស់រឿងក្ដីរំលោភលើសេចក្ដីទុកចិត្តមកលើសេដ្ឋកិច្ចកម្ពុជាទេ។ ក៏ប៉ុន្តែ ការរកឃើញទាំងនេះអាចជួយបានពីរយ៉ាង។ ទីមួយ វាអាចជួយកំណត់

[២១] ក្នុងមួយឆ្នាំៗ តុលាការរាជធានីភ្នំពេញទទួលរឿងក្ដីរំលោភលើសេចក្ដីទុកចិត្ត ជាមធ្យម ចំនួនជាង ២០០ ករណី ប៉ុន្តែ គេឃើញថា ភ្នំពេញជាប្រភពធំជាងគេនៃរឿងក្ដីរំលោភលើសេចក្ដីទុកចិត្ត នៅកម្ពុជា។

ប្រភេទនៃថ្លៃចំណាយ ដែលជាប់ទាក់ទងជាមួយនឹងរឿងក្តីមិនត្រឹមត្រូវពីបទរំលោភលើសេចក្តីទុកចិត្ត ហើយទីពីរ គេអាចប្រើវាដើម្បីប៉ាន់ស្មានថ្លៃចំណាយសម្រាប់បុគ្គល និងក្រុមហ៊ុនទាំងឡាយ ដែលយើងបានសម្ភាស ឬបានអង្កេត។

គេឃើញថា រឿងក្តីមិនត្រឹមត្រូវពីបទរំលោភលើសេចក្តីទុកចិត្ត អាចជះឥទ្ធិពលមកលើសេដ្ឋកិច្ចកម្ពុជា តាមរបៀបផ្សេងៗមួយចំនួន។ ការចំណាយជាក់ស្តែងជាងគេ គឺការចំណាយផ្ទាល់ ដែលរួមមានថ្លៃឈ្នួលមេធាវី ថ្លៃចំណាយក្រៅផ្លូវការ ដែលជាប់ទាក់ទងនឹងការត្រូវគេប្តឹងពីបទរំលោភលើសេចក្តីទុកចិត្ត។ រឿងក្តីរំលោភលើសេចក្តីទុកចិត្តមួយចំនួនត្រូវគេបង្កើតឡើង ដើម្បីទទួលបានថ្លៃចំណាយផ្ទាល់ទាំងនោះ។ អ្នកផ្តល់សម្ភាសន៍ម្នាក់បាននិយាយថា ថ្លៃចំណាយតិចបំផុតដែលត្រូវបង់ដើម្បីបានរួចខ្លួនចេញមកនៅក្រៅឃុំគឺ ២០០០០ ដុល្លា ឯអ្នកផ្តល់សម្ភាសន៍មួយចំនួនទៀតនិយាយថា ថ្លៃចំណាយនេះមានចំនួនច្រើន តែវាអាស្រ័យលើទឹកប្រាក់ដែលគេបានប្តឹងទាមទារអោយសង។ នៅក្នុងករណីសម្រាប់សិក្សា ១ លោក ក បានចំណាយ អស់ ៤០០០០ ដុល្លា ដើម្បីបានរួចខ្លួននៅក្រៅឃុំ និង ២០០០០ ដុល្លាទៀត ទៅលើថ្លៃឈ្នួលមេធាវី។ អ្នកឆ្លើយអង្កេតដប់នាក់ បានឆ្លើយឯកភាពគ្នាថា ថ្លៃចំណាយបណ្តាលមកពីត្រូវគេប្តឹងពីបទរំលោភលើសេចក្តីទុកចិត្តស្ថិតនៅចន្លោះពី៥០០០ទៅ៥០០០០ ដុល្លា។ ថ្វីបើគេមិនអាចគណនាថ្លៃចំណាយជាមធ្យម សម្រាប់រឿងក្តីមិនត្រឹមត្រូវពីបទរំលោភលើសេចក្តីទុកចិត្តនៅកម្ពុជា អោយបានជាក់លាក់ចេញពីទិន្នន័យនេះបានក្តី សក្ខីភាពជាការដំណាលត។គ្នា បង្ហាញថា ថ្លៃចំណាយក្នុងរឿងក្តីនីមួយៗ អាចមានទំហំពីរាប់ពាន់ ទៅរាប់ម៉ឺនដុល្លា។

ប្រភេទបន្ទាប់នៃថ្លៃចំណាយ គឺការខាត់បង់អាជីវកម្ម ដែលបណ្តាលមកពីត្រូវគេប្តឹងពីបទរំលោភលើសេចក្តីទុកចិត្ត ពោលគឺការខាតបង់អាជីវកម្ម ដោយត្រូវចំណាយពេលវេលានៅក្នុងពន្ធនាគារ និងការខូចកិត្តិយស ។ល។ ជាថ្មីម្តងទៀត គេមិនអាចកំណត់ទំហំជាក់លាក់នៃទឹកប្រាក់នេះបានទេ។ ការអង្កេតមិនបានសួរអោយអ្នកឆ្លើយបែងចែកដាច់ពីគ្នា នូវថ្លៃចំណាយផ្ទាល់ ថ្លៃតុលាការ និងការចំណាយក្រៅផ្លូវការផ្សេងៗ និងការខាតបង់ការរកស៊ី ដែលបណ្តាលមកពីមានគេប្តឹងទេ ហើយគ្មានអ្នកផ្តល់សម្ភាសន៍ណាម្នាក់ ចង់កំណត់ចំនួនទឹកប្រាក់នៃការខាតបង់ក្នុងការរកស៊ី អោយលើសពីការនិយាយថាវាមានទំហំ "ច្រើនណាស់" ឡើយ។

ថ្លៃចំណាយប្រភេទទីបី ទាក់ទងនឹងការគំរាមដាក់ពាក្យបណ្តឹងពីបទរំលោភលើសេចក្តីទុកចិត្ត។ មេធាវីមួយចំនួនដែលយើងបានសម្ភាសជាមួយ បានត្អូញត្អែរថា មេធាវីផ្សេងៗទៀត តែងតែគំរាមដដែលៗ ថានឹងដាក់ពាក្យបណ្តឹងពីបទរំលោភលើសេចក្តីទុកចិត្ត នៅពេលដែលគេទាមទារប្រាក់ក្នុងការចរចាគ្នា និងនៅពេលមានវិវាទកិច្ចសន្យា។ គេយល់ថា ទាំងនេះគឺជាការគំរាមបំបិទមាត់ដើម្បីចាប់អ្នកទទួលការគំរាមនោះដាក់ពន្ធនាគារ បើសិនជាគេមិនព្រមបង់ប្រាក់អោយ។ អ្នកផ្តល់សម្ភាសន៍ទាំងឡាយបាននិយាយថា ស្ទើរតែជានិច្ចកាល គេគ្មានមូលដ្ឋានអ្វីសម្រាប់ប្តឹងពីបទរំលោភលើសេចក្តីទុកចិត្តទេ ប៉ុន្តែរឿងក្តីមិនត្រឹមត្រូវពីបទរំលោភសេចក្តីទុកចិត្ត ជាករណីដែលកើតឡើងជាទូទៅ ដែលជួនកាល វាសមល្មមនឹងធ្វើអោយអតិថិជនរបស់គេ សុខចិត្តបង់ប្រាក់អោយអ្នកដើមចោទ ដើម្បីតែចៀសវាងអោយផុតពីហានិភ័យថា គេជាប់ពាក់ព័ន្ធនឹងរឿងក្តីបែបនេះ។ គេមិនអាចកំណត់ចំនួនទឹកប្រាក់ដែលគេបានចំណាយក្នុងមួយឆ្នាំៗ ដោយសារតែការគំរាមទាំងនោះបានទេ។

ប្រភេទចុងក្រោយនៃការចំណាយ ហើយប្រហែលជាប្រភេទធំជាងគេបង្អស់ គឺការខាតបង់ឱកាសវិនិយោគ។ ប្រភេទនេះ គ្របលើទំនាក់ទំនងអាជីវកម្ម ដែលគេអាចនឹងធ្វើទៅបាន បើកុំតែភ័យខ្លាចត្រូវគេប្តឹងចោទពីបទរំលោភលើសេចក្តីទុកចិត្ត។ អ្នកជំនួញស្ទើរតែទាំងអស់ដែលយើងបានសម្ភាស បានចង្អុលបង្ហាញថា ពួកគេបានបដិសេធឱកាសវិនិយោគដែលគេបានជួប ដោយសារតែភ័យខ្លាចការចោទប្រកាន់ពីបទរំលោភលើសេចក្តីទុកចិត្ត។ មេធាវីអាជីវកម្ម និងទីប្រឹក្សាអាជីវកម្មស្ទើរតែទាំងអស់ បានរាយការណ៍ថា គេបានផ្តល់យោបល់ដល់អតិថិជនរបស់ពួកគេ អោយជ្រើសរើសដៃគូអាជីវកម្មដោយប្រុងប្រយ័ត្ន ព្រោះតែការប្តឹងមិនត្រឹមត្រូវពីបទរំលោភសេចក្តីទុកចិត្តទាំងនោះ។ ក្នុងចំណោមចម្លើយនៃការអង្កេតទាំងដប់ (សូមមើល ឧបសម្ព័ន្ធ ៤) មានចម្លើយបី បង្ហាញថា ពួកគេបានបដិសេធឱកាសវិនិយោគ "ជាញឹកញយ" ឯបីទៀតនិយាយថា "ជារឿយៗ" និងបីផ្សេងទៀត និយាយថា "ម្តងម្កាល"។ មានអ្នកឆ្លើយអង្កេតតែម្នាក់ប៉ុណ្ណោះ ដែលបានរាយការណ៍ថា គេមិនដែលបដិសេធឱកាសវិនិយោគណាមួយ ដោយសារតែហានិភ័យនៃការត្រូវគេប្តឹងចោទពីបទរំលោភលើសេចក្តីទុកចិត្តទេ។

គេមិនអាចទាញរកតួលេខទូទៅ នៃការខាតបង់ឱកាសវិនិយោគទាំងឡាយ នៅកម្ពុជា ចេញពីលទ្ធផលនៃការអង្កេត និងសម្ភាសន៍ដែលបានធ្វើនេះទេ។ ប៉ុន្តែ ការសរុបទឹកប្រាក់ដែលអ្នកឆ្លើយអង្កេតចំនួនប្រាំពីរនាក់ បានរាយការណ៍តបទៅនឹងសំណួរថា "តើឱកាសវិនិយោគនានាដែលលោក-អ្នក បានបដិសេធដោយសារហានិភ័យនៃការរំលោភលើសេចក្តីទុកចិត្ត មានតម្លៃប៉ុន្មាន? បានបង្ហាញពីលំដាប់នៃការខាតបង់ការវិនិយោគ សម្រាប់បុគ្គលទាំងប្រាំពីរនាក់ដែលបានឆ្លើយអង្កេតនេះថាវា មានទំហំចន្លោះពី ៣លាន ទៅ ១២,១លាន ដុល្លា។ គេបានបូកសរុបលទ្ធផលទាំងនោះនៅក្នុងតារាងខាងក្រោម។ គេបានសួរអ្នកផ្តល់សម្ភាសន៍ នូវសំណួរដដែលនេះ ហើយទំហំទឹកប្រាក់សរុបនៃការបោះបង់ចោលឱកាសវិនិយោគ មានចំនួនលើសពី ៥លាន ដុល្លារ ក្នុងមួយឆ្នាំៗ។ សរុបចូលគ្នាទៅតួលេខនេះ តាងអោយការខាតបង់ឱកាសវិនិយោគ ក្នុងចំណោមមនុស្ស និងក្រុមហ៊ុនចំនួនតិចជាង ១២។ ទោះបីជាមនុស្ស និងក្រុមហ៊ុនទាំងនោះ អាចតាងអោយក្រុមអ្នកដែលបដិសេធឱកាសអាជីវកម្មច្រើនជាងគេ ការរកឃើញនានានៅតែបង្ហាញថា រឿងក្តីមិនត្រឹមត្រូវនៃការរំលោភលើសេចក្តីទុកចិត្តធ្វើអោយកម្ពុជាខាតបង់ការវិនិយោគអស់ជាច្រើនលាន និងអាចដល់រាប់សិបលានដុល្លារ ក្នុងមួយឆ្នាំៗ។

ជំពូក ៤

ការពិភាក្សាលើវិស័យឯកជន លេខ ២៣

## ការខាតបង់ឱកាសវិនិយោគ ដោយសាររឿងក្តីមិនត្រឹមត្រូវនៃការរំលោភលើសេចក្តីទុកចិត្ត

| | តើលោក-អ្នកយល់ថាត្រូវចំណាយ អស់ប៉ុន្មានក្នុងករណីដែលត្រូវគេប្តឹងចោទពីបទរំលោភលើសេចក្តីទុកចិត្ត? | តើលោក-អ្នកធ្លាប់បានបដិសេធឱកាសវិនិយោគ ដោយសារហានិភ័យនៃការរំលោភសេចក្តីទុកចិត្ត ញឹកញាប់យ៉ាងណា? | តើឱកាសវិនិយោគដែលលោក-អ្នក ធ្លាប់បានបដិសេធ ដោយសារហានិភ័យនៃការរំលោភសេចក្តីទុកចិត្ត មានតម្លៃប៉ុន្មាន? |
|---|---|---|---|
| ១ | ៥000 - ៥0000 ដុល្លា | ញឹកញាប់ណាស់ | ១ - ៥លាន ដុល្លា |
| ២ | ៥000 - ៥0000 ដុល្លា | ជារឿយៗ | ២៥0 000 - ៥00 000 ដុល្លា |
| ៣ | ៥000 - ៥0000 ដុល្លា | ញឹកញាប់ណាស់ | គ្មានចម្លើយ |
| ៤ | ៥000 - ៥0000 ដុល្លា | ម្តងម្កាល | គ្មានចម្លើយ |
| ៥ | ៥000 - ៥0000 ដុល្លា | មិនដែលសោះ | គ្មានចម្លើយ |
| ៦ | តិចជាង ៥000 ដុល្លា | ម្តងម្កាល | តិចជាង ៥0 000 ដុល្លា |
| ៧ | ៥000 - ៥0000 ដុល្លា | ជារឿយៗ | ២៥0 000 - ៥00 000 ដុល្លា |
| ៨ | ៥000 - ៥0000 ដុល្លា | ម្តងម្កាល | គ្មានចម្លើយ |
| ៩ | ៥000 - ៥0000 ដុល្លា | ញឹកញាប់ណាស់ | ១ - ៥លាន ដុល្លា |
| ១0 | ៥000 - ៥0000 ដុល្លា | ជារឿយៗ | ៥00 000 - ១លាន ដុល្លា |
| ១១ | គ្មានចម្លើយ | គ្មានចម្លើយ | តិចជា ៥00 000 ដុល្លា |
| | | | សរុប = ៣ 000 000 - ១២ ១00 000 ដុល្លា |

ព័ត៌មាននៅក្នុងតារាងនេះ ទទួលបានមកពីការអង្កេតគ្មានភាពចៃដន្យនៃអាជីវកម្មកម្ពុជា។

# អនុសាសន៍ និងសេចក្តីសន្និដ្ឋាន

## អនុសាសន៍

### កាត់បន្ថយការអនុវត្តន៍ដោយមិនត្រឹមត្រូវនូវរឿងក្តីរំលោភលើសេចក្តីទុកចិត្ត និងឥទ្ធិពលរបស់វាមកលើសេដ្ឋកិច្ចកម្ពុជា

យើងបានពិភាក្សាជាមួយអ្នកផ្តល់សម្ភាសន៍ និងទទួលបានសំណើមួយចំនួន អំពីយន្តការផ្សេងៗ សម្រាប់កាត់បន្ថយ ឥទ្ធិពលនៃរឿងក្តីមិនត្រឹមត្រូវនៃការរំលោភលើសេចក្តីទុកចិត្ត។ ក្រៅពីនេះ ការអង្កេតបានសួរអ្នកឆ្លើយអង្កេត អំពីកំណែទម្រង់មួយចំនួនដែលគួរមាន។ ការអង្កេតក៏មានទុកចន្លោះចំហទំនេរពីរកន្លែងដែរ សម្រាប់អោយអ្នកឆ្លើយអាចសរសេរអនុសាសន៍ផ្ទាល់របស់គេ ហើយអ្នកឆ្លើយមួយចំនួន ពិតជាបានសរសេរអនុសាសន៍នានាចូលមែន។ គេបានវាយតម្លៃលើយោបល់ និងការពិភាក្សាទាំងនោះ ដោយយោងតាមព័ត៌មានទាំងឡាយដែលគេប្រមូលបានសម្រាប់របាយការណ៍នេះ ហើយគេទទួលបានលទ្ធផលជាអនុសាសន៍នានា សម្រាប់កាត់បន្ថយឥទ្ធិពលនៃរឿងក្តីមិនត្រឹមត្រូវនៃការរំលោភលើសេចក្តីទុកចិត្តមកលើសេដ្ឋកិច្ចកម្ពុជាដូចតទៅ

#### អនុម័តសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ទាក់ទងនឹងការរំលោភលើសេចក្តីទុកចិត្ត

សេចក្តីព្រាងច្បាប់ព្រហ្មទណ្ឌទាក់ទងនឹងការរំលោភលើសេចក្តីទុកចិត្ត មានលក្ខណៈប្រសើរជាងច្បាប់ដែលនៅជាធរមានសព្វថ្ងៃនេះយ៉ាងច្រើន។ វារក្សាធាតុផ្សំស្នូលសំខាន់ៗនៅដដែល ដោយប្រើភាសាងាយយល់ជាង ដូច្នេះវាប្រហែលជាអាចធ្វើអោយមានការយល់ច្រឡំតិចជាងមុន។ គេគួរតែអនុម័តសេចក្តីព្រាងច្បាប់នេះ អោយបានឆាប់តាមដែលអាចធ្វើទៅបាន ដោយរក្សាពាក្យពេចន៍តាមទម្រង់ដែលមាននាពេលបច្ចុប្បន្ននេះ។

#### ផ្តោតការយកចិត្តទុកដាក់ ទៅលើធាតុផ្សំស្តីពីការទុកចិត្តប្រគល់អ្វីមួយអោយអ្នកដទៃ ទទួលខុសត្រូវ និងចេតនាប្រព្រឹត្ត បទល្មើសព្រហ្មទណ្ឌ

វិធីមួយសម្រាប់កាត់បន្ថយឥទ្ធិពលអាក្រក់នៃរឿងក្តីរំលោភលើសេចក្តីទុកចិត្ត គឺត្រូវផ្តោតការចាប់អារម្មណ៍ទៅលើ ធាតុផ្សំស្តីពីការទុកចិត្តប្រគល់អ្វីមួយ និងចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ នៅក្នុងរឿងក្តីដែលគេចោទដោយមិនត្រឹមត្រូវ ភាគច្រើន ជនជាប់ចោទមិនត្រូវបាន ដើមចោទទុកចិត្តប្រគល់ទ្រព្យអ្វីមួយអោយទេ ហើយក៏ប្រហែលជាគ្មានភស្តុតាងនៃចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ

ដែរទេ ។ តាមពិតទៅ តាមការបង្ហាញរបស់ករណីសិក្សា ១ និង ៣ គេថែមទាំងអាចឃើញ មានភស្តុតាងថា គឺដើមចោទទេដែលបានធ្វេសប្រហែស មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ។ ដោយហេតុនេះ តាមរយៈការទាមទារយ៉ាងតឹងតែងអោយមានភស្តុតាងច្បាស់លាស់ ពីការបានទុកចិត្តប្រគល់អ្វីមួយអោយអ្នកដទៃទទួលខុសត្រូវ និងពីចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ វាមានភាពងាយស្រួលជាងក្នុងការកំណត់ និងការជៀសវាង រឿងក្តីមិនត្រឹមត្រូវនៃ ការរំលោភសេចក្តីទុកចិត្ត ។

*ចេញសេចក្តីណែនាំរួមថ្មីមួយ ដែលតម្រូវអោយចៅក្រមចេញសាលក្រមទាក់ទងនឹងករណីរំលោភលើសេចក្តីទុកចិត្ត ពិភាក្សាយ៉ាងច្បាស់លាស់ពីភស្តុតាងដែលគាំទ្រដល់ធាតុផ្សំនីមួយៗ នៃបទល្មើសព្រហ្មទណ្ឌ*

សេចក្តីណែនាំការងារជាផ្លូវការ ស្តីពីរបៀបសរសេរយោបល់របស់តុលាការ អាចជួយអោយមានភាពត្រឹមត្រូវ និងតម្លាភាពក្នុងរឿងក្តីរំលោភលើសេចក្តីទុកចិត្តនេះបាន ព្រមទាំងជួយធានាថា មន្ត្រីតុលាការទាំងឡាយ នឹងលើកយកធាតុផ្សំ នៃបទល្មើសព្រហ្មទណ្ឌនីមួយៗ មកដោះស្រាយដោយឡែកពីគ្នា និងយ៉ាងត្រឹមត្រូវ មុននឹងរកឃើញថាមានទោសពីបទរំលោភលើសេចក្តីទុកចិត្ត ។ សេចក្តីណែនាំការងារជាផ្លូវការបែបនេះ ត្រូវតែបញ្ជាក់ថា សាលក្រមនីមួយៗរបស់តុលាការ ត្រូវមានការពិភាក្សាដោយឡែកៗពីគ្នា អំពីភស្តុតាងដែលគាំទ្រដល់ធាតុផ្សំនីមួយៗនៃបទល្មើសព្រហ្មទណ្ឌ ។ ការធ្វើរបៀបនេះ នាំអោយគេឃើញច្បាស់ ថាតើគេមានភស្តុតាងសម្រាប់ធាតុផ្សំណាមួយ ឬធាតុផ្សំទាំងអស់ដែរ ឬអត់ ។ ការពិភាក្សាយ៉ាងច្បាស់លាស់ អំពីភស្តុតាងដែលគាំទ្រដល់ធាតុផ្សំនីមួយៗ នៃបទល្មើសព្រហ្មទណ្ឌ ដោយមានសរសេរជាលាយលក្ខអក្សរ នៅក្នុងយោបល់របស់តុលាការជំនុំជំរះក្តី ក៏អាចជួយបន្ថយបញ្ហាទាក់ទងនឹងបណ្តឹងសាទុក្ខ ព្រមទាំងជួយសម្រាលទម្ងន់ការងារ របស់តុលាការថ្នាក់ខ្ពស់ផងដែរ ។

*ផ្តល់ការបណ្តុះបណ្តាលដល់ចៅក្រម អំពីធាតុផ្សំនានានៃការរំលោភលើសេចក្តីទុកចិត្ត ជាពិសេសការបានប្រគល់អ្វីមួយ អោយអ្នកដទៃទទួលខុសត្រូវ និងចេតនាប្រព្រឹត្តបទល្មើស*

អ្នកឆ្លើយអង្កេតភាគច្រើនជឿថា ការបណ្តុះបណ្តាលដល់នគរបាល និងចៅក្រម អំពីរឿងក្តីរំលោភលើសេចក្តីទុកចិត្ត អាចផ្តល់លទ្ធផលជាការ "កែលំអស្ថានការណ៍ដ៏ធំមួយ" ។ ការប្រើពាក្យនៅក្នុងច្បាប់ស្តីពីការរំលោភលើសេចក្តីទុកចិត្ត ងាយធ្វើអោយគេយល់ច្រឡំ ហើយការបណ្តុះបណ្តាលបន្ថែមអាចផ្តល់ផលប្រយោជន៍មួយចំនួន ។ បើសិនជាគេត្រូវផ្តល់ការបណ្តុះបណ្តាលបន្ថែម នោះវាគួរតែផ្តោតទៅលើការតម្រូវអោយមានភស្តុតាងសម្រាប់ធាតុផ្សំនីមួយៗនៃបទល្មើស ជាពិសេស ការបានប្រគល់អ្វីមួយអោយគេនិងចេតនាប្រព្រឹត្តបទល្មើសហើយគួរផ្តល់ការបណ្តុះបណ្តាលនោះភ្ជាប់ជាមួយនឹងការចេញសេចក្តីណែនាំរួមថ្មី ដូចបានលើកឡើងខាងលើ ។

## បោះពុម្ពផ្សាយសាលក្រមទាំងអស់នៃរឿងក្តីរំលោភលើសេចក្តីទុកចិត្ត

ការបោះពុម្ពផ្សាយសាលក្រមនៃរឿងក្តីការរំលោភលើសេចក្តីទុកចិត្ត អាចជួយអោយគេផ្តោតការចាប់អារម្មណ៍ទៅលើធាតុផ្សំ ស្តីពីការប្រគល់អ្វីមួយអាយគេទទួលខុសត្រូវ និងចេតនាប្រព្រឹត្តបទល្មើសព្រោះវាអនុញ្ញាតអោយគេអាចពិនិត្យពិច្ច័យ លើការទាញហេតុផលដែលនៅពីក្រោយការចេញសាលក្រម។ កង្វះលទ្ធភាពទទួលព័ត៌មានអំពីសាលក្រមរបស់តុលាការនៅកម្ពុជា បានធ្វើអោយគេជួបការលំបាកក្នុងការតាមពិនិត្យមើលថា តើធាតុផ្សំនីមួយៗនៃបទល្មើសព្រហ្មទណ្ឌមាន ភស្តុតាងច្បាស់លាស់ដែរ ឬទេ។

## សម្របសម្រួលជាមួយរាជរដ្ឋាភិបាល សហគមន៍អាជីវកម្ម សង្គមស៊ីវិល និងបណ្តាញផ្សាយព័ត៌មានទាំងឡាយ ដើម្បីពិនិត្យពិច្ច័យ លើរឿងក្តីរំលោភលើសេចក្តីទុកចិត្ត

អនុសាសន៍នេះ កើតចេញពីយោបល់របស់អ្នកផ្តល់សម្ភាសន៍ ចំពោះសេចក្តីណែនាំរួមស្តីពីការរំលោភលើសេចក្តីទុកចិត្ត ដែលចេញរួមគ្នាដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល កាលពីខែ សីហា ២០០៥។ អ្នកផ្តល់សម្ភាសន៍ម្នាក់ ដែលជាមេធាវីសញ្ជាតិកម្ពុជា បាននិយាយថា ចាប់តាំងពីការចេញសេចក្តីណែនាំរួមមក លោកមើលឃើញស្ថានភាពមានដំណើរល្អប្រសើរជាងមុន ព្រោះបុគ្គលិកតុលាការជឿថា សកម្មភាពទាំងឡាយរបស់គេ កំពុងស្ថិតក្រោមការវាយតម្លៃដោយរាជរដ្ឋាភិបាល។ ការណ៍នេះមានន័យល្អ ហើយនាំអោយគេមើលឃើញថា ការពិនិត្យពិច្ច័យយ៉ាងដិតដល់ជាងមុន លើរឿងក្តីរំលោភលើសេចក្តីទុកចិត្ត នឹងអាចមានប្រយោជន៍ច្រើន។ មានវិធីជាច្រើនសម្រាប់ធ្វើអោយសម្រេចការងារនេះបាន ក្នុងនោះ មានការតាមដានដិតដល់ជាងមុនដោយក្រសួងយុត្តិធម៌ ឬឧត្តមក្រុមប្រឹក្សាអង្គចៅក្រមលើករណីបំពាននានាដែលអាចកើតមាន។ សង្គមស៊ីវិល និងបណ្តាញផ្សាយព័ត៌មានទាំងឡាយ ក៏អាចដើរតួមួយផងដែរ ក្នុងការរំលេចអោយឃើញ និងនាំអោយសាធារណជនចាប់អារម្មណ៍ ចំពោះរឿងក្តីមិនត្រឹមត្រូវទាំងឡាយដែលអាចកើតមាន។ គេឃើញមានតម្រូវការអោយមានកិច្ចសហការគ្នាប្រសើរជាងមុន រវាងផ្នែកឯកជន សង្គមស៊ីវិល បណ្តាញផ្សាយព័ត៌មាន និងរាជរដ្ឋាភិបាល ដើម្បីធ្វើកិច្ចការនេះ។

ដោយទទួលស្គាល់នូវតម្រូវការតាមឃ្លាំមើលរឿងក្តីរំលោភលើសេចក្តីទុកចិត្ត នៅថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០០៦ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានចេញលិខិតបង្គាប់ការមួយ ទៅកាន់តុលាការ និងព្រះរាជអាជ្ញាទាំងឡាយ ដោយបញ្ជាក់ថា គេមិនទាន់អនុវត្តមាត្រានៃការរំលោភលើសេចក្តីទុកចិត្តបានត្រឹមត្រូវទេ និងថាចាប់ពីពេលនេះតទៅ គេត្រូវតែជូនដំណឹងដល់ក្រសួងយុត្តិធម៌ អំពីរឿងក្តីរំលោភលើសេចក្តីទុកចិត្តដែលគេប្តឹងចោទទៅលើវិនិយោគិនទាំងឡាយ។

### បង្កើតយន្តការសម្រាប់ការរាយការណ៍ជាអនាមិក ពីបុគ្គលិកតុលាការ ឬនគរបាលណាដែលទារថ្លៃឈ្នួលក្រៅផ្លូវការ

ជាទូទៅ អនុសាសន៍នេះទាក់ទងនឹងគំនិតស្តីពីការតាមឃ្លាំមើលជិតដល់ជាងមុន លើរឿងក្តីរំលោភលើសេចក្តីទុកចិត្ត។ អ្នកកាន់អំណាចទាំងឡាយ ប្រហែលជាមិនសូវទារថ្លៃឈ្នួលក្រៅផ្លូវការទៀតទេ បើសិនជាគេដឹងថា ជនជាប់ចោទអាចរាយការណ៍ពីពួកគេ ដល់នរណាម្នាក់ដែលអាចនឹងមកអង្កេតមើល ដោយយោងតាមសេចក្តីរាយការណ៍នោះ។ ដោយហេតុនេះ វាអាចនឹងមានប្រយោជន៍ណាស់ បើសិនជាមានយន្តការអនាមិក និងឯករាជ្យ សម្រាប់អោយបុគ្គល ឬក្រុមហ៊ុនទាំងឡាយ រាយការណ៍អំពីអ្នកកាន់អំណាចដែលប្រព្រឹត្តមិនត្រឹមត្រូវ។ ចំណុចដ៏ច្បាស់មួយចេញពីការរាយការណ៍នេះគឺ ដរាបណាគេមិនបានទទួលការធានាពីភាពអនាមិកទាំងស្រុងទេនោះ បុគ្គលទាំងឡាយនឹងមិនរាយការណ៍អំពីករណីរឿងក្តីមិនត្រឹមត្រូវណាមួយ ដល់នរណាម្នាក់ទេ។

### កាត់បន្ថយការឃុំខ្លួនមុនការជំនុំជំរះក្តី ដោយចេញសេចក្តីណែនាំការងារជាផ្លូវការមួយ ដែលពិពណ៌នាយ៉ាងច្បាស់លាស់ អំពីករណីដែលត្រូវប្រើការឃុំខ្លួនមុនការជំនុំជំរះក្តី

អ្នកផ្តល់សម្ភាសន៍ភាគច្រើន និងអ្នកឆ្លើយអង្កេតទាំងអស់ជឿថា ការកាត់បន្ថយការឃុំខ្លួនមុនជំនុំជំរះក្តី នៅក្នុងរឿងក្តីរំលោភលើសេចក្តីទុកចិត្ត អាចជួយកែលំអស្ថានភាពអោយបានល្អប្រសើរជាងមុន។ អ្នកឆ្លើយអង្កេតដែលគេបានបែងចែកជាបីក្រុមស្មើៗគ្នា យល់ឃើញថាការដាក់កំរិតបែបនេះ អាចជួយកែលំអស្ថានភាពអោយប្រសើរជាងមុន បន្តិចបន្តួច ច្រើនបង្គួរ និងច្រើនខ្លាំង។ ការគំរាមឃុំខ្លួនមុនការជំនុំជំរះក្តី គឺជាប្រភពនៃការដាក់សម្ពាធអោយអាជីវករបង់ប្រាក់ នៅក្នុងរឿងក្តីមិនត្រឹមត្រូវនៃការរំលោភលើសេចក្តីទុកចិត្ត។ ដោយហេតុនេះ គេឃើញមានហេតុផលសមស្របថា ការកាត់បន្ថយការឃុំខ្លួនមុនការជំនុំជំរះក្តី អាចនឹងកាត់បន្ថយឥទ្ធិពលអាក្រក់នៃការប្តឹងចោទមិនត្រឹមត្រូវ។ ការណ៍នេះក៏អាចត្រូវគ្នាផងដែរ ជាមួយនឹងច្បាប់ព្រហ្មទណ្ឌអន្តរកាលដែលចែងថា គេត្រូវប្រើការឃុំខ្លួនមុនការជំនុំជំរះក្តី តែនៅពេលណាដែលគេមានហេតុផល និងតម្រុយច្បាស់លាស់ថា ជនជាប់ចោទប្រុងនឹងរត់គេចខ្លួន។

គេអាចអនុវត្តអនុសាសន៍នេះបាន តាមរយៈសេចក្តីណែនាំការងារជាលាយលក្ខអក្សរដល់អង្គចៅក្រម ដែលពន្យល់បកស្រាយយ៉ាងលំអិត អំពីកត្តាទាំងឡាយសម្រាប់វាយតម្លៃ ក្នុងការកំណត់ថា តើជនជាប់ចោទអាចរត់គេចខ្លួន ឬទេ។ ឧទាហរណ៍ អ្នកទាំងឡាយដែលមានសម្ព័ន្ធយ៉ាងច្រើនជាមួយនឹងប្រទេសកម្ពុជា (គ្រួសារផ្ទាល់ខ្លួន ទ្រព្យសម្បត្តិ អាជីវកម្ម។ល។) អាចលើកលែងចេញបានពីការឃុំខ្លួនមុនការជំនុំជំរះក្តី ក្នុងរឿងក្តីរំលោភលើសេចក្តីទុកចិត្ត។ ដោយសន្មតថា ជនជាប់ចោទអាចរត់គេចខ្លួន សេចក្តីណែនាំការងារនោះគួរតែកំណត់ អំពីលក្ខខណ្ឌដែលគេអាចអនុវត្តការធានាខ្លួននៅក្រៅឃុំបាន និងកំណត់របៀបគណនាចំនួនទឹកប្រាក់សម្រាប់ធានាខ្លួននោះ ព្រមទាំងយន្តការសម្រាប់អោយជនជាប់ចោទអាចទទួលបានប្រាក់ ធានាខ្លួនរបស់គេមកវិញ។

## សេចក្តីសន្និដ្ឋាន

គេសង្ឃឹមថា អនុសាសន៍ទាំងឡាយដែលមាននៅក្នុងរបាយការណ៍នេះ នឹងរួមចំណែកកាត់បន្ថយឥទ្ធិពលនៃការអនុវត្តន៍មិនត្រឹមត្រូវនូវបទល្មើសរំលោភលើសេចក្តីទុកចិត្ត មកលើសេដ្ឋកិច្ចកម្ពុជា ដែលបានធ្វើអោយសេដ្ឋកិច្ចកម្ពុជា ខាតបង់យ៉ាងច្រើន។ ការសិក្សាដែលគណៈកម្មាធិការពិសេសបានធ្វើនេះ បានបញ្ជាក់ថា ការអនុវត្តន៍មិនត្រឹមត្រូវ នូវបទល្មើសរំលោភលើសេចក្តីទុកចិត្តធ្វើអោយខូចខាតដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ព្រមទាំងធ្វើឱ្យសាធារណជន និងអ្នកវិនិយោគបាត់បង់សេចក្តីទុកចិត្តចំពោះប្រព័ន្ធតុលាការ និងប្រព័ន្ធច្បាប់កម្ពុជា។ ការសិក្សាស្រាវជ្រាវបង្ហាញថាមានការយល់ឃើញជាទូទៅក្នុងចំណោមមជ្ឈដ្ឋានពាក់ព័ន្ធ ទាំងជនកម្ពុជា ទាំងជនបរទេសថា មាត្រានៃការរំលោភលើសេចក្តីទុកចិត្ត ត្រូវគេយកទៅអនុវត្តខុសជារឿយៗ ហើយប្រការនេះបង្កអោយសេដ្ឋកិច្ចកម្ពុជាខាតបង់យ៉ាងច្រើន។ រឿងក្តីមិនត្រឹមត្រូវនៃការរំលោភលើសេចក្តីទុកចិត្ត ធ្វើអោយប្រទេសកម្ពុជាខាតបង់ការវិនិយោគដែលមានតម្លៃរាប់លានដុល្លារ ឬអាចដល់ទៅរាប់សិបលានដុល្លារក្នុងមួយឆ្នាំៗ។ ជាមួយនឹងការព្រួយបារម្ភរបស់រដ្ឋាភិបាល និងផ្នែកឯកជន អំពីការខាតបង់ដ៏ច្រើនដែលបណ្តាលមកពីរឿងក្តីមិនត្រឹមត្រូវនៃការរំលោភលើសេចក្តីទុកចិត្ត ឥឡូវនេះវាជាពេលវេលាដ៏សមស្របបំផុត ក្នុងការបញ្ជាក់អោយឃើញថា គេពិតជាអាចអនុវត្តប្រការទាំងឡាយនៃមាត្រា ៤៦ បានយ៉ាងត្រឹមត្រូវ ហើយការណ៍នេះ នឹងធ្វើអោយសេដ្ឋកិច្ចកម្ពុជាអាចរីកលូតលាស់បានល្អប្រសើរ។

# ឧបសម្ព័ន្ធ ១

# វិធីសាស្ត្រនៃការស្រាវជ្រាវ

## ១. សេចក្តីផ្តើម

របាយការណ៍នេះផ្អែកលើព័ត៌មានដែលបានមកពីប្រភពចំនួនបួនៈ

- ការសម្ភាសន៍ជាមួយមជ្ឈដ្ឋានពាក់ព័ន្ធ
- ព័ត៌មានទទួលបានមកពីក្រសួងយុត្តិធម៌
- ការពិនិត្យមើលព័ត៌មានទាក់ទងនឹងរឿងក្តីរំលោភលើសេចក្តីទុកចិត្ត ដែលគេអាចទទួលបានជាសាធារណៈ និង
- ការអង្កេតមតិយោបល់របស់អាជីវកម្ម។

## ២. ការសម្ភាសន៍ជាមួយមជ្ឈដ្ឋានពាក់ព័ន្ធ

យើងបានសម្ភាសជាមួយមជ្ឈដ្ឋានពាក់ព័ន្ធផ្សេងៗ ចំនួន ១៨ នាក់ ដោយរួមទាំងជនជាតិខ្មែរផង ជនបរទេសផង ក្នុងនោះមានៈ អាជីវករ មេធាវីពាណិជ្ជកម្ម មេធាវីការពារបទល្មើសព្រហ្មទណ្ឌ ទីប្រឹក្សាអាជីវកម្ម អ្នកតស៊ូមតិខាងសិទ្ធិមនុស្ស អង្គការសង្គមស៊ីវិល និងសមាជិកនៃអង្គការតុលាការ។ ក្នុងនោះ ក៏មានផងដែរនូវការសម្ភាសន៍ជាមួយបុគ្គល ដែលធ្លាប់ជួបប្រទះនឹងរឿងក្តីរំលោភលើសេចក្តីទុកចិត្ត មេធាវីដែលធ្លាប់ការពារជនជាប់ចោទពីបទរំលោភលើសេចក្តីទុកចិត្ត និងអាជីវករទាំងឡាយដែលព្រួយបារម្ភ ពីរបៀបដែលគេអនុវត្តមាត្រានៃការរំលោភសេចក្តីទុកចិត្ត។

## ៣. ការពិនិត្យមើលព័ត៌មានដែលទទួលបានពីក្រសួងយុត្តិធម៌

ក្រសួងយុត្តិធម៌បានផ្តល់ជូនគណៈកម្មាធិការពិសេស នូវទិន្នន័យស្ថិតិអំពីចំនួនសរុបនៃរឿងក្តីរំលោភលើសេចក្តីទុកចិត្ត។ គេបានសង្ខេបព័ត៌មានទាំងនោះ នៅក្នុងឧបសម្ព័ន្ធ ៤។ ក្រសួងពិតជាខិតខំផ្តល់ព័ត៌មាន សម្រាប់ការស្រាវជ្រាវនេះទៅតាមលទ្ធភាព ក៏ប៉ុន្តែ ក្រៅពីទិន្នន័យដែលគេបានផ្តល់អោយក្រសួងបានរក្សាទុកនូវព័ត៌មានមួយចំនួនទៀត។បច្ចុប្បន្ននេះ តុលាការមិនបានបោះពុម្ពផ្សាយនូវសាលក្រមសម្រេចនៃរឿងក្តីរំលោភលើសេចក្តីទុកចិត្តទេ ហើយគេក៏មិនអាចទទួលបានជាសាធារណៈដែរនូវព័ត៌មាន អំពីចំនួនរឿងក្តីនៃការរំលោភលើសេចក្តីទុកចិត្ត ដែលគេបានប្តឹងក្នុងមួយឆ្នាំៗ ភាពញឹកញាប់នៃការឃុំខ្លួនមុនពេលជំនុំជំរះក្តី ភាគរយនៃរឿងក្តីដែលនាំអោយមានការដាក់ទោសរយៈពេលមធ្យមនៃការកាត់ទោសអោយជាប់ពន្ធនាគារ ឬទំហំទឹកប្រាក់មធ្យមនៃការសងជំងឺចិត្ត។

យើងទទួលបានច្បាប់ចម្លងនៃសាលក្រមមួយចំនួនតូច ដែលគេមិនអាចទទួលបានពីក្រសួងយុត្តិធម៌ ពីប្រភពគួរអោយទុកចិត្តបានផ្សេងទៀត ដូចជាមេធាវីដែលមានកំណត់ត្រាពីរឿងក្តីដែលគេបានចូលរួម។

## ៤. ការពិនិត្យមើលរបាយការណ៍របស់សារព័ត៌មាន និងព័ត៌មានដែលទទួលបានជាសាធារណៈ

ថ្វីបើមានព័ត៌មានតិចតួចអំពីរឿងក្តីរំលោភលើសេចក្តីទុកចិត្ត ដែលគេអាចទទួលបានជាសាធារណៈក្តី ក្រុមអ្នកស្រាវជ្រាវបានពិនិត្យមើលយ៉ាងល្អិតល្អន់ លើសារព័ត៌មានកម្ពុជាធំៗមួយចំនួនក្នុងរយៈពេលជាង ៤ ឆ្នាំ ដើម្បីប្រមូលចងក្រងរបាយការណ៍អំពីរឿងក្តីពីការរំលោភលើសេចក្តីទុកចិត្តរបស់បណ្តាញផ្សាយព័ត៌មានទាំងនោះ។ សារព័ត៌មានដែលយើងបានពិនិត្យមើលនោះគឺ: The Phnom Penh Post, The Business Press, The Mirror, Development Weekly និង រស្មីកម្ពុជា។ យើងបានស្រាវជ្រាវរកព័ត៌មាននេះ នៅក្នុងសារព័ត៌មាននីមួយៗ សម្រាប់រយៈពេលពី ឆ្នាំ ២០០២ មកទល់នឹងឆ្នាំ ២០០៥។ ទិន្នន័យនៃបណ្តាញផ្សាយព័ត៌មានទាំងនេះ មានបានដាក់ភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ៣។ រឿងក្តីទាំងនេះ តាងអោយតែមួយភាគនៃចំនួនរឿងក្តីរំលោភលើសេចក្តីទុកចិត្តដែលបានកើតឡើងតែប៉ុណ្ណោះ។ រឿងក្តីទាំងឡាយ ដែលបានចូលទៅក្នុងទំព័រសារព័ត៌មានពិតជាត្រូវបានគេជ្រើសរើស ដោយសារគេយល់ឃើញថា វាជាព័ត៌មានដែលមនុស្សជាច្រើនចាប់អារម្មណ៍។ ហេតុដូចនេះហើយ គេមិនអាចចាត់ទុកវាថា ជាលទ្ធផលនៃការសម្ភាសន៍ដោយចៃដន្យ នៃរឿងក្តីរំលោភលើសេចក្តីទុកចិត្ត នៅក្នុងប្រទេសកម្ពុជាបានឡើយ។

ជាបន្ថែមទៅលើរបាយការណ៍សារព័ត៌មាន គេទទួលបានព័ត៌មានមួយភាគ ទាក់ទងនឹងរឿងក្តីរំលោភសេចក្តីទុកចិត្ត ចំនួន ២០ ពីមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ដែលគេប្រមូលបានក្នុងពេលតាមពិនិត្យមើលការជំនុំជំរះក្តី នៅក្នុងតុលាការកម្ពុជា ដែលជាផ្នែកមួយនៃគំរោងឃ្លាំមើលតុលាការរបស់អង្គការនេះ។ យើងក៏បានបញ្ចូលព័ត៌មានទាំងនេះ ទៅក្នុងទិន្នន័យនៃបណ្តាញផ្សាយព័ត៌មានដែរ។

## ៥. ការអង្កេតមតិយោបល់របស់អាជីវកម្ម

ជាបន្ថែមទៅលើប្រភពព័ត៌មានខាងលើ គេបានធ្វើការអង្កេតដោយគ្មានលក្ខណៈចៃដន្យ លើមតិអាជីវកម្ម ដោយបានសួរអាជីវករទាំងឡាយ អោយឆ្លើយទៅនឹងសំណួរទាក់ទងនឹងការយល់ឃើញរបស់ពួកគេ អំពីការរំលោភលើសេចក្តីទុកចិត្ត។

យើងបានបែងចែកសំណួរអង្កេតនោះទៅសមាគមអាជីវកម្មមួយចំនួន រួមមានទាំងអាជីវកម្មកម្ពុជា និងបរទេស សំខាន់ៗមួយចំនួន។ មានចម្លើយឆ្លើយតបចំនួនដប់មួយ ហើយយើងបានសង្ខេបលទ្ធផលទាំងនោះ នៅក្នុងឧបសម្ព័ន្ធ ៤។ គួរកត់សំគាល់ថា ដោយសារការអង្កេតនេះមានទំហំតូច

និងគ្មានលក្ខណៈចៃដន្យ ការរកឃើញទាំងឡាយ មិនអាចបង្ហាញថា មានភាពត្រឹមត្រូវល្អតាមន័យស្ថិតិឡើយ ។ ជាពិសេស ការជ្រើសរើសអ្នកឆ្លើយអង្កេតដោយខ្លួនឯង អាចធ្វើអោយចម្លើយមានភាពល្អៀង ហើយភាពល្អៀង នេះកាន់តែមានទំហំធំឡើង បើអ្នកឆ្លើយសំណួរមាន ការយល់ឃើដែលមានទំនោរខ្លាំងទៅរកអ្វីមួយ ពាក់ព័ន្ធនឹងរឿងក្តីរំលោភលើសេចក្តីទុកចិត្តនេះ (ទោះបែបវិជ្ជមានក្តី បែបអវិជ្ជមានក្តី) ច្រើនតែចង់ឆ្លើយជាង ។ ក៏ប៉ុន្តែ លទ្ធផលនៃការអង្កេត ត្រូវគ្នាជាមួយនឹងលទ្ធផលនៃការសម្ភាសន៍ ។

# ឧបសម្ព័ន្ធ ២
# ករណីសិក្សា

## ករណីសិក្សា ទី១

លោក **ក** ជាអាជីវករខ្មែរម្នាក់ ដែលបានចុះកិច្ចសន្យាមួយជាមួយលោក **ខ** ក្នុងឆ្នាំ ២000 ។ កិច្ចសន្យានោះ ធ្វើឡើងសម្រាប់ការទិញគ្រឿងចក្រ និងរូបធាតុសំណង់ តម្លៃ ៨0000 ដុល្លា ។ លោក **ខ** បានផ្គត់ផ្គង់ទំនិញមួយចំនួន ប៉ុន្តែទំនិញទាំងនោះមិនស្របតាមលក្ខខណ្ឌផ្គត់ផ្គង់ដែលចែងនៅក្នុងកិច្ចសន្យាទេ ដូចនេះ លោក **ក** បដិសេធមិនទទួលទំនិញ និងលុបកិច្ចសន្យាចោល ។ លោក **ខ** ទាមទារអោយបង់ប្រាក់តាមកិច្ចសន្យាតែលោក **ក** បដិសេធ ។

ពីរបីសប្តាហ៍ក្រោយមក គេបានកោះអញ្ជើញលោក **ក** ទៅកាន់ទីស្នាក់ការនគរបាលនៅល្ងាចថ្ងៃសុក្រមួយ ។ គេមិនបានប្រាប់លោក អំពីមូលហេតុនៃការកោះអញ្ជើញអោយទៅកាន់ទីស្នាក់ការនគរបាលនេះទេ ។ ពេលលោកទៅដល់ គេបានចាប់ខ្លួនលោក និងឃុំខ្លួនលោកនៅទីស្នាក់ការនគរបាលអស់ ៧២ ម៉ោង ។ គេបានចោទលោកពីបទរំលោភលើសេចក្តីទុកចិត្ត ចំពោះការមិនព្រមបង់ប្រាក់ទៅអោយលោក **ខ** ទៅតាមកិច្ចសន្យា ។ លោកបានទាមទាររកមេធាវី តែគេបានប្រាប់លោកថាលោកមិនអាចទទួលបានទេ ។ គេបានប្រាប់លោកជាច្រើនដងថា លោកអាចរួចខ្លួនពីការឃុំឃាំងបានបើសិនជា លោកយល់ព្រមបង់ប្រាក់អោយប៉ូលីស ៨0000 ដុល្លា (ចំនួនទឹកប្រាក់ដែលគេប្តឹងចោទពី "ការរំលោភលើសេចក្តីទុកចិត្ត" ជាមួយលោក **ខ**) ។ លោកបានបដិសេធ ។

នៅថ្ងៃច័ន្ទបន្ទាប់មក គេបាននាំខ្លួនលោកទៅកាន់តុលាការ ដែលនៅទីនោះ លោកត្រូវគេចោទប្រកាន់ពីបទរំលោភលើសេចក្តីទុកចិត្ត ហើយគេបានបញ្ជូនលោកទៅកាន់ទីឃុំឃាំង មុនការជំនុំជំរះក្តីនៅពន្ធនាគារព្រៃសរ ។ លោកបានជាប់ឃុំនៅព្រៃសរ អស់ពីរបីសប្តាហ៍ ក្នុងពេលដែលមេធាវីរបស់លោកចាត់ចែងធានាខ្លួនលោក ចេញពីមន្ទីរឃុំឃាំង ។ ទីបញ្ចប់ លោកអាចធានាខ្លួនចេញពីពន្ធនាគារបានដោយសារបានបង់ប្រាក់ ៤0000 ដុល្លា ទៅអោយតុលាការ ។

ក្នុងពេលជំនុំជំរះក្តី លោក **ខ** និងមេធាវីរបស់លោក មិនបានបង្ហាញខ្លួនឡើយ ។ មេធាវីរបស់លោក **ក** បានបង្ហាញសាក្សីនិងឯកសារនានាដែលបញ្ជាក់ថាលោក **ខ** មិនបានបំពេញករណីយកិច្ចជាភាគីកិច្ចសន្យារបស់ខ្លួនទេ និងថា គេបានលុបចោលកិច្ចសន្យាយ៉ាងត្រឹមត្រូវ ។ ទោះជាមានភស្តុតាងនេះក្តី ការជំនុំជំរះក្តីបានរកឃើញថា លោក **ខ** មានទោសពីបទរំលោភលើសេចក្តីទុកចិត្ត និងបានដាក់ទោសលោកអោយជាប់ពន្ធនាគារបីឆ្នាំ ។ លោកបានប្តឹងសារទុក្ខចំពោះសាលក្រមនេះ ទៅសាលាឧទ្ធរណ៍ ដែលបានសម្រេចចេញសាលក្រមបញ្ច្រាសពីសាលក្រមរបស់សាលាដំបូង និងលុបចោលការចោទប្រកាន់ ។

លោកមិនដែលអាចទទួលបានប្រាក់ដែលលោកបានបង់ធានាខ្លួន ៤០០០០ ដុល្លានោះមកវិញទេ ហើយបានចំណាយអស់ ២០០០០ ដុល្លា ជាបន្ថែមទៀតទៅលើថ្លៃឈ្នួលមេធាវី។ លោកក៏បានបាត់បង់កិត្តិយសអស់ជាច្រើនដែរ ហើយអាជីវកម្មរបស់លោកបានរងការខូចខាតក្នុងពេលដែលលោកជាប់ឃុំខ្លួនមុនការជំនុំជំរះក្តី។ ឥឡូវនេះ លោកប្រយ័ត្នប្រយែងខ្លាំងណាស់ ក្នុងការចុះហត្ថលេខាលើកិច្ចសន្យានានា និងបានបដិសេធចោលឱកាសវិនិយោគជាច្រើន ដោយសារតែមានហានិភ័យនៃការរំលោភលើសេចក្តីទុកចិត្ត។

*គេបានចងក្រងករណីសិក្សានេះឡើង ដោយផ្អែកលើការសម្ភាសន៍ ជាមួយបុគ្គលមួយចំនួនដែលបានផ្តល់ព័ត៌មាន ប្រហែលគ្នាអំពីការធ្លាប់រងការចោទប្រកាន់ ពីបទរំលោភលើសេចក្តីទុកចិត្តដែលកើតចេញមកពីវិវាទកិច្ចសន្យា។ យើងបានប្តូរព័ត៌មានអំពីអត្តសញ្ញាណសាមីជនទៅតាមសំណូមពររបស់អ្នកផ្តល់សម្ភាសន៍ទាំងនោះ។*

## ករណីសិក្សា ទី២

ក្នុងឆ្នាំ ២000 អ្នកស្រី ខ បានខ្ចីខ្សែកមាសពីអ្នកជិតខាង គឺអ្នកស្រី គ ដើម្បីពាក់ទៅចូលរួមពិធីអាពាហ៍ពិពាហ៍របស់បងប្អូន។ នៅក្នុងអាពាហ៍ពិពាហ៍នោះ ទំពក់ខ្សែកបានរបើក ហើយខ្សែករបូតជ្រុះបាត់។ក្រោយពេលចប់ពិធីអាពាហ៍ពិពាហ៍ទើបអ្នកស្រីខបានដឹងថាជ្រុះបាត់ខ្សែក។ គាត់បានត្រឡប់ទៅរកវិញ តែរកមិនឃើញឡើយ។

នៅពេលអ្នកស្រី គ សួររកខ្សែកមកវិញ អ្នកស្រី ខ បានស្នើសុំពេលខ្លះទៀតដើម្បីរកវា។ មួយ ឬពីរសប្តាហ៍ក្រោយមក អ្នកស្រី គ បានសួររកម្តងទៀត។ ពេលនោះ អ្នកស្រី ខ បានសារភាពថាគាត់បានជ្រុះវាបាត់ និងស្នើសុំពេលវេលា សម្រាប់បង់ជាសំណងតាមតម្លៃខ្សែក ដែលស្មើនឹងប្រាក់ ១00 ដុល្លា។ ក៏ប៉ុន្តែ អ្នកស្រី ខ ជាអ្នកក្រ និងមិនអាចរកប្រាក់បាន ១00 ដុល្លា ដើម្បីសងអ្នកស្រី គ បានទេ។ ជាបញ្ចប់ អ្នកស្រី គ បាត់បង់សេចក្តីអត់ធ្មត់ និងបានប្តឹងអ្នកស្រី ខ ពីបទរំលោភលើសេចក្តីទុកចិត្ត។

គេបានចាប់ខ្លួនអ្នកស្រី ខ យកទៅកាន់តុលាការរាជធានីភ្នំពេញ និងចោទប្រកាន់គាត់ពីបទរំលោភលើសេចក្តីទុកចិត្ត រួចឃុំខ្លួនមុនការជំនុំជំរះក្តី។ គេបានចាត់មេធាវីម្នាក់ ពីអង្គការមិនមែនរដ្ឋាភិបាល ដែលស្វែងរកការសុំធានាខ្លួនគាត់ចេញក្រៅឃុំ។ ចៅក្រមស៊ើបអង្កេតបានបដិសេធសេចក្តីស្នើសុំធានាខ្លួន។ មេធាវីរបស់គាត់បានប្តឹងសាទុក្ខ អំពីការបដិសេធការធានាខ្លួន ទៅសាលាឧទ្ធរណ៍ ហើយសាលាឧទ្ធរណ៍បានយល់ព្រមផ្តល់អោយ។ គេមិនបានទាមទារអោយគាត់បង់ប្រាក់ដើម្បីធានាខ្លួនឡើយ។ អ្នកស្រី ខ បានជាប់ឃុំនៅពន្ធនាគារប្រមាណជាពីរខែ មុននឹងត្រូវបានសាលាឧទ្ធរណ៍ផ្តល់ការធានាអោយនៅក្រៅឃុំ។

ក្រោយពីទទួលបានការធានាខ្លួននៅក្រៅឃុំ មេធាវីរបស់គាត់ បានសាកល្បងទំលាក់ចោលការប្រកាន់បទព្រហ្មទណ្ឌ។ មេធាវីបានដាក់សំណើសុំទៅចៅក្រមស៊ើបអង្កេត ដោយពន្យល់ថា អ្នកស្រី ខ មិនអាចនឹងមានទោសពីបទរំលោភលើសេចក្តីទុកចិត្តបានទេ ព្រោះគាត់គ្មានចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឡើយ។ គាត់មិនបានគៃបន្លំយកខ្សែកទេ គឺគាត់ជ្រុះវាបាត់។ ក្រៅពីនោះ គាត់មិនបានសាកល្បងគេចវេសពីករណីកិច្ចរបស់ខ្លួន ចំពោះអ្នកស្រី គ ឡើយ ប៉ុន្តែដោយសារគាត់ក្រីក្រពេក ទើបមិនអាចសងថ្លៃខ្សែកដែលបានបាត់នោះបាន។ ព្រះរាជអាជ្ញា និងអ្នកស្រី គ មិនបានជំទាស់នឹងសំណើសុំនោះទេ។ ទីបញ្ចប់ គេបានទំលាក់ចោលការចោទប្រកាន់បទព្រហ្មទណ្ឌ ហើយអ្នកស្រី ខ និងអ្នកស្រី គ បានដោះស្រាយរឿងក្តីរដ្ឋប្បវេណីនោះនៅក្រៅតុលាការ។

*គេចងក្រងករណីសិក្សានេះឡើង ដោយផ្អែកលើការសម្ភាសន៍ ជាមួយមេធាវីខ្មែរមួយចំនួនដែលធ្លាប់ការពារអ្នកដែល ត្រូវគេចោទប្រកាន់អំពីការខ្ចី ហើយបន្ទាប់មក មិនអាចសងទ្រព្យទាំងនោះអោយម្ចាស់គេវិញបាន។ យើងបានប្តូរព័ត៌មានអំពី អត្តសញ្ញាណសាមីជន ទៅតាមសំណូមពររបស់អ្នកផ្តល់សម្ភាសន៍។*

## ករណីសិក្សា ទី៣

ក្នុងឆ្នាំ ២០០១ ក្រុមហ៊ុន **ឃ** មកពីសិង្ហបុរី បានចុះកិច្ចសន្យាមួយ ជាមួយក្រុមហ៊ុន **ង** ដែលជាក្រុមហ៊ុនកម្ពុជា ដើម្បីនាំចូលកុំព្យូទ័រ។ ក្រុមហ៊ុន **ង** យល់ព្រមទិញទំនិញទាំងនោះ និងលក់វានៅក្នុងប្រទេសកម្ពុជា។ កិច្ចសន្យាត្រូវបានគេធ្វើឡើង សម្រាប់រយៈពេលមួយឆ្នាំ។ នៅចុងឆ្នាំទីមួយ ក្រុមហ៊ុន **ឃ** មិនពេញចិត្តនឹងការងាររបស់ក្រុមហ៊ុន **ង** ទេ។ ក្រុមហ៊ុន **ង** មិនបាននាំចូលកុំព្យូទ័រច្រើនតាមចំនួនដែលក្រុមហ៊ុនសិង្ហបុរី បានរំពឹងទុកឡើយ។ ក្រុមហ៊ុន **ឃ** បានសម្រេចចិត្តមិនបន្តកិច្ចសន្យាជាថ្មីទេ។ ក្រៅពីនោះ គេបានសម្រេចចិត្តស្វែងរកក្រុមហ៊ុនមួយទៀត អោយនាំចូលគ្រឿងកុំព្យូទ័ររបស់គេ។

នៅពេលដែលក្រុមហ៊ុន **ឃ** បានជូនព័ត៌មានដល់ក្រុមហ៊ុន **ង** ថាគេគ្មានបំណងបន្តកិច្ចសន្យាស្រាប់តែក្រុមហ៊ុន **ង** បានប្តឹងក្រុមហ៊ុន **ឃ** ពីបទព្រហ្មទណ្ឌនៃការរំលោភលើសេចក្តីទុកចិត្ត។ គេក៏បានប្តឹងបុគ្គលមួយចំនួន ជានិយោជិតនៃក្រុមហ៊ុន **ឃ** ផងដែរ ដោយក្នុងនេះមានទាំងអ្នកចាត់ការទូទៅផង។ គេបានចេញដីកាតាមចាប់ខ្លួន អ្នកចាត់ការទូទៅជនជាតិសិង្ហបុរីម្នាក់។ គេមិនអាចចាប់អ្នកចាត់ការទូទៅនោះបានទេ ព្រោះគាត់មិននៅក្នុងប្រទេសកម្ពុជា តែដីកានោះបានរារាំងយ៉ាងមានប្រសិទ្ធភាព មិនអោយគាត់ចូលមកក្នុងប្រទេសកម្ពុជាបានទៀតឡើយ។

ដីកាចាប់ខ្លួនទាំងនោះ ក៏បានរារាំងមិនអោយក្រុមហ៊ុន **ឃ** ស្វែងរកក្រុមហ៊ុនផ្សេងទៀតដើម្បីលក់គ្រឿងកុំព្យូទ័រ នៅកម្ពុជាបានដែរ។ ដោយមិនចង់អោយនាយកប្រតិបត្តិរបស់ខ្លួនប្រឈមមុខនឹងការជាប់ពន្ធនាគារ និងការខាតបង់កិត្តិយសដល់ក្រុមហ៊ុន ក្រុមហ៊ុន **ឃ** បានបង់ប្រាក់អោយក្រុមហ៊ុន **ង** ដើម្បីអោយគេទំលាក់ចោលការចោទប្រកាន់។ គេបានបង់ប្រាក់មុនពេលមានការជំនុំជំរះ ហើយទីបញ្ចប់ការចោទប្រកាន់នោះ ត្រូវគេរំសាយចោល។ ក៏ប៉ុន្តែ ក្រុមហ៊ុន **ឃ** បានដកខ្លួនទាំងស្រុងចេញពីកម្ពុជា និងមិនធ្វើអាជីវកម្មនៅទីនេះជាបន្តទៅទៀតឡើយ។ មុនពេលចាកចេញពីកម្ពុជា ក្រុមហ៊ុននេះធ្លាប់ធ្វើអាជីវកម្មមានតម្លៃរាប់សែនដុល្លា ក្នុងមួយឆ្នាំ។

*គេបានចងក្រងអង្គហេតុនេះឡើង ដោយផ្អែកលើការសម្ភាសន៍ជាមួយបុគ្គលមួយចំនួន ដែលបានផ្តល់ព័ត៌មានប្រហាក់ប្រហែលគ្នា អំពីរឿងក្តីរំលោភលើសេចក្តីទុកចិត្ត ដែលកើតចេញពីបរាជ័យរបស់កិច្ចសន្យាលក់-ទិញទំនិញ។ យើងបានប្តូរព័ត៌មាន អំពីអត្តសញ្ញាណរបស់សាមីជន ទៅតាមសំណូមពររបស់អ្នកផ្តល់សម្ភាសន៍ទាំងនោះ។*

## ករណីសិក្សា ទី៤

លោក **កែវ តាម** បានទិញដីមួយឡូត៍នៅភ្នំពេញ។ លោកបានស្នើស្ត្រីម្នាក់ឈ្មោះអ្នកស្រី **ឈុន ណៃស្វរ** អោយនៅចាំរក្សាដីនោះ។ នៅខែមីនា ឆ្នាំ ២០០១ លោកបានដឹងថាស្ត្រីនោះបានជួលដីរបស់លោក ទៅអោយឈ្មួញលក់គ្រឿងចក្រម្នាក់ ដោយមិនបានស្នើសុំការអនុញ្ញាតពីលោកឡើយ។ លោកបានប្តឹងអ្នកស្រី **ឈុន ណៃស្វរ** ពីបទរំលោភលើសេចក្តីទុកចិត្ត ហើយគេបានចាប់ខ្លួនស្ត្រីនោះ នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០០១ និងឃុំខ្លួនមុនការជំនុំជំរះ។

អ្នកស្រី **ឈុន** បានស្នើសុំរួចខ្លួននៅក្រៅឃុំមុនការជំនុំជំរះក្តីនោះ ដើម្បីអាចមើលថែកូនតូចៗរបស់គាត់បីនាក់ តែត្រូវចៅក្រមស៊ើបអង្កេតបដិសេធ។ អ្នកស្រីបានប្តឹងសាទុក្ខទៅសាលាឧទ្ធរណ៍ ដែលបានបដិសេធសំណើសុំនៅក្រៅឃុំនោះដូចគ្នាដែរ។ ជាបន្តមកទៀត អ្នកស្រីបានប្តឹងសាទុក្ខពីការឃុំខ្លួនមុនការជំនុំជំរះនោះ ទៅតុលាការកំពូល ដែលបានទទួលបណ្តឹងរបស់អ្នកស្រី នៅខែកញ្ញា ឆ្នាំ ២០០១។ នៅក្នុងការជំនុំជំរះឧទ្ធរណ៍ តុលាការកំពូលបានទទួលសេចក្តីថ្លែងការពីភាគីទាំងពីរ គឺជនជាប់ចោទ និងដើមចោទ។ អ្នកស្រី **ឈុន** ជាជនជាប់ចោទ បានជជែកវែកញែកថា អ្នកស្រីជឿថា លោក **កែវ តាម** បានអោយដីនោះទៅគាត់ ហើយគាត់មានសិទ្ធិជួលដីអោយគេ ព្រោះវាជារបស់គាត់។ អ្នកស្រីបានសារភាពថា គាត់បានធ្វើខុស ប៉ុន្តែគាត់គ្មានចេតនាយកដីមួយ ចំរៀកណា ពីលោក **កែវ តាម** ឡើយ។ ដោយហេតុនេះ អ្នកស្រីគ្មានចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលចាំបាច់សម្រាប់ចោទប្រកាន់ពីបទរំលោភលើសេចក្តីទុកចិត្តឡើយ។ អ្នកស្រីស្នើសុំនៅក្រៅឃុំ ដើម្បីថែទាំកូនៗរបស់គាត់។ តុលាការកំពូល ក៏បានស្តាប់សេចក្តីរាយការណ៍ពីចៅក្រមរាយការណ៍ និងស្តាប់អនុសាសន៍របស់អ្នកតំណាងការិយាល័យព្រះរាជអាជ្ញាផងដែរ។

នៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០០២ តុលាការកំពូលបានកាត់ក្តីថា ដីនោះពិតជាកម្មសិទ្ធិរបស់លោក **កែវ តាម** មែន ប៉ុន្តែ គេគួរដោះលែងអ្នកស្រី **ឈុន** អោយនៅក្រៅការឃុំខ្លួនមុនការជំនុំជំរះក្តី ដោយសារមូលហេតុពីរ: ១) អ្នកស្រីគ្មាន ចេតនាប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌទេ ព្រោះអ្នកស្រីយល់ថាដីនោះជារបស់គាត់ និង ២) គាត់បានជាប់ឃុំយូរណាស់មកហើយ (មកទល់ពេលនោះ គាត់បានជាប់ឃុំអស់ប្រាំបីខែហើយ)។ បន្ទាប់មកតុលាការកំពូល បានបញ្ជូនរឿងក្តីនោះទៅកាន់តុលាការរាជធានីភ្នំពេញវិញ ដើម្បីអាចជំនុំជំរះ ទៅតាមអង្គហេតុរបស់វា។

*អង្គហេតុនេះនៃរឿងក្តីនេះ បានមកពីសាលក្រមតុលាការកំពូលស្តីពីរឿងក្តី **កែវ តាម** ទល់នឹង **ឈុន ណៃស្វរ** (ក្តីព្រហ្មទណ្ឌលេខ ៦២ ចុះថ្ងៃ ៤ ខែកញ្ញា ឆ្នាំ ២០០១, សាលក្រមលេខ ៤ ចុះថ្ងៃ៩ ខែមករា ឆ្នាំ ២០០២)។*

## ករណីសិក្សា ទី៥

ក្នុងខែមេសា ១៩៩២ លោក **ម៉ិន ស្រ៊ុន** បានចូលជាដៃគូជាមួយលោក **ខុង តឿ** ដើម្បីដំឡើងម៉ាស៊ីនផលិតភ្លើងអគ្គិសនី ក្នុងភូមិមួយនៅខេត្តកំពង់ចាម ។ ពួកគេម្នាក់ៗ បានវិនិយោគនូវចំណែកភាគហ៊ុនជាទឹកប្រាក់ស្មើគ្នា ដើម្បីទិញម៉ាស៊ីនផលិតភ្លើងអគ្គិសនី និងសង់អគារដាក់ម៉ាស៊ីននេះ ។ ដៃគូម្នាក់ៗ មានកូនសោរមួយសម្រាប់ចូលអគារ ។ បីខែក្រោយមក ដៃគូទាំងពីរឈ្លោះទាស់ទែងគ្នា ។ លោក **ខុង តឿ** ចង់លក់ភាគហ៊ុនរបស់លោកទៅអោយភាគីទីបី ឯលោក **ម៉ិន ស្រ៊ុន** មិនចង់ អោយគាត់លក់ភាគហ៊ុនរបស់គាត់ទេ ។ ពួកគាត់មិនអាចស្រុះស្រួលគ្នាបានទេ ហើយទីបញ្ចប់ពួកគាត់សសម្រេចបិទម៉ាស៊ីនភ្លើង និងមិនប្រើវា ។ ក៏ប៉ុន្តែ លោក **ម៉ិន** បានបន្តប្រើវាដោយលួចលាក់ ដើម្បីរកចំណូលសម្រាប់ខ្លួនគាត់ផ្ទាល់ ។ មួយរយៈក្រោយមក លោក **ម៉ិន** បានស្នើអោយប្រពន្ធរបស់ខ្លួនទៅសួរប្រពន្ធរបស់ លោក **ខុង** ថាតើនាងអាចសុំខ្ចីកូនសោរ របស់លោក **ខុង** សម្រាប់ចូលអគារដាក់ម៉ាស៊ីនបានដែរឬទេ ។ ការណ៏នេះ ធ្វើអោយលោក **ម៉ិន** មានកូនសោរទាំងពីរ ចំណែកឯលោក **ខុង** គ្មានកូនសោរសោះ ។ បន្ទាប់មក លោក **ម៉ិន** បានលក់ម៉ាស៊ីនភ្លើងនោះ ទៅអោយភាគីទីបី ។

លោក **ខុង** បានប្តឹង ហើយលោក **ម៉ិន** ត្រូវគេចោទប្រកាន់ពីបទរំលោភលើសេចក្តីទុកចិត្តនៅក្នុងខែមីនា ឆ្នាំ១៩៩៤ ។ លោក **ម៉ិន** មានមេធាវី ហើយបានជជែកវែកញែកថា លោកគ្មានទោសទេ ព្រោះការលក់ម៉ាស៊ីនភ្លើង គឺជាផ្នែកមួយនៃកិច្ចសន្យាជាមួយលោក **ខុង** សម្រាប់រំសាយអាជីវកម្មរបស់ពួកគាត់ ដែលបានចែងថា លោក **ម៉ិន** អាចទទួលបានម៉ាស៊ីនភ្លើង ឯលោក **ខុង** អាចទទួលបានអគារដាក់ម៉ាស៊ីន និងដីដែលវាស្ថិតនៅពីលើ ។ ដោយផ្អែក លើភស្តុតាងដែលគេបានបង្ហាញនៅក្នុងការជំនុំជំរះក្តី តុលាការបានបដិសេធសេចក្តីរាយការណ៏របស់លោក **ម៉ិន** ។

តុលាការបានសសម្រេចថា គេឃើញមានភស្តុតាងគ្រប់គ្រាន់ អំពីការរំលោភលើសេចក្តីទុកចិត្តរបស់លោក **ម៉ិន** ។ ជាពិសេស តុលាការបានកត់សំគាល់ឃើញថាៈ ១) លោកបានប្រើប្រពន្ធរបស់លោកដើម្បីទទួលបានកូនសោរ របស់លោក **ខុង** ក្នុងបំណងគ្រប់គ្រងលើម៉ាស៊ីនភ្លើងតែម្នាក់ឯង និង ២) លោកបានលក់ម៉ាស៊ីនភ្លើងដោយលួចលាក់ ទៅអោយភាគីទីបី ដោយមិនប្រាប់លោក **ខុង** ។ តុលាការកាត់សេចក្តីថា លោក **ម៉ិន** "បានប្រព្រឹត្តដោយចេតនា" ក្នុងពេលដែលលោកបានតែបន្លំម៉ាស៊ីនភ្លើងនោះ ។ តុលាការបានកាត់ទោសលោក អោយជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ និងសាលក្រមព្យួរទោសពីរឆ្នាំ ព្រមទាំងបាន បញ្ជាអោយបង់សំណងជំងឺចិត្ត ទៅអោយលោក **ខុង** សម្រាប់ការខាត បង់ភាគហ៊ុននៃម៉ាស៊ីនភ្លើង ។

*អង្គហេតុនៃរឿងក្តីនេះ ផ្អែកលើសាលក្រមរបស់តុលាការខេត្តកំពង់ចាម ក្នុងរឿងក្តីលោក* ***ខុង តឿ*** *ទល់នឹងលោក* ***ម៉ិន ស្រ៊ុន*** *(សំណុំឯកសារព្រហ្មទណ្ឌលេខ ៤៧ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ១៩៩៤, សាលក្រមលេខ ៤១ ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ១៩៩៤) ។*

# ឧបសម្ព័ន្ធ ៣
# របាយការណ៍បានមកពីបណ្ដាញផ្សាយព័ត៌មាន

## ការវិភាគទិន្នន័យពីបណ្ដាញផ្សព្វផ្សាយព័ត៌មាន

| ចំនួនរឿងក្ដីដែលមានចេញដីកាឃាត់ខ្លួន | |
|---|---|
| រឿងក្ដីដែលមានព័ត៌មានអំពីការឃាត់ខ្លួន | ៣៤ |
| រឿងក្ដីដែលមានចេញដីកាឃាត់ខ្លួន | ៣៣ |
| ភាគរយនៃ រឿងក្ដីដែលមានចេញដីកាឃាត់ខ្លួន | ៩៧% |

| ចំនួនរឿងក្ដីដែលជនជាប់ចោទត្រូវគេឃាត់ខ្លួន | |
|---|---|
| រឿងក្ដីដែលមានព័ត៌មានអំពីការឃាត់ខ្លួន | ៣៤ |
| រឿងក្ដីដែលជនជាប់ចោទត្រូវគេឃាត់ខ្លួន | ៣២ |
| ភាគរយនៃរឿងក្ដីដែលជនជាប់ចោទត្រូវគេឃាត់ខ្លួន | ៩៤% |

| ចំនួនរឿងក្ដីដែលរឿងក្ដីដែលជនជាប់ចោទត្រូវបានគេឃុំខ្លួន មុនមានការជំនុំជំរះក្ដី | |
|---|---|
| រឿងក្ដីដែលមានព័ត៌មានលើការឃុំខ្លួនមុនមានការជំនុំជំរះក្ដី | ៣១ |
| រឿងក្ដីដែលជនជាប់ចោទត្រូវបានគេឃុំខ្លួនមុនមានការជំនុំជំរះក្ដី | ២៩ |
| ភាគរយនៃរឿងក្ដីដែលជនជាប់ចោទត្រូវបានគេឃុំខ្លួនមុនមានការជំនុំជំរះក្ដី | ៩៤% |

## ឧបសម្ព័ន្ធ ៤

# លទ្ធផលនៃការអង្កេត

## ការវិភាគលទ្ធផលនៃការអង្កេត

| សំណួរទី ១: តើតុលាការវិនិច្ឆ័យទោសពីបទល្មើសរំលោភលើសេចក្ដីទុកចិត្តបានត្រឹមត្រូវ និងយុត្តិធម៌ឬទេ? | |
|---|---|
| ត្រឹមត្រូវជានិច្ច | 0 |
| ត្រឹមត្រូវ | 0 |
| ពេលខ្លះត្រឹមត្រូវ | ៥ |
| មិនដែលត្រឹមត្រូវទេ | ៦ |
| ចម្លើយសរុប | ១១ |

| សំណួរទី ២: តើបណ្ដឹងព្រហ្មទណ្ឌមិនត្រឹមត្រូវ នៃការរំលោភលើសេចក្ដីទុកចិត្ត ធ្វើឡើងញឹកញយប៉ុណ្ណា ? | |
|---|---|
| ស្ទើរតែជានិច្ចកាល | ២ |
| ញឹកញយ | ៤ |
| ម្ដងម្កាល | ៣ |
| មិនដែលសោះ | ១ |
| ចម្លើយសរុប | ១០ |

| សំណួរទី ៣: តើការសូកបាន់អាចប៉ះពាល់ដល់លទ្ធផលនៃរឿងក្ដីរំលោភលើសេចក្ដីទុកចិត្តបានដែរ ឬទេ? | |
|---|---|
| ប៉ះពាល់ស្ទើរតែជានិច្ចកាល | ៨ |
| ប៉ះពាល់ជាញឹកញយ | ៣ |
| ប៉ះពាល់ម្ដងម្កាល | 0 |
| មិនដែលប៉ះពាល់សោះ | 0 |
| ចម្លើយសរុប | ១១ |

| សំណួរទី ៤: តើហានិភ័យខាងក្រោមនេះ ជះឥទ្ធិពលដល់លោក_អ្នកប៉ុណ្ណាដែរ? | | | |
|---|---|---|---|
| | បាត់បង់ប្រាក់ | បាត់បង់កេរ្តិ៍ឈ្មោះ | ជាប់ពន្ធនាគារ |
| ជះឥទ្ធិពលខ្លាំង | ៨ | ៧ | ៦ |
| ជះឥទ្ធិពល | ២ | ១ | ០ |
| ជះឥទ្ធិពលតិចតួច | ០ | ០ | ១ |
| អត់ជះឥទ្ធិពលអ្វីសោះ | ០ | ១ | ១ |
| ចម្លើយសរុប | ១០ | ៩ | ៨ |

| សំណួរទី ៥: តើលោក_អ្នកគិតថា ត្រូវចំណាយប្រាក់អស់ប៉ុន្មាននៅពេលត្រូវគេប្ដឹងចោទពីបទល្មើសរំលោភលើសេចក្ដីទុកចិត្ត? | |
|---|---|
| តិចជាង ៥០០០ ដុល្លា | ១ |
| ចន្លោះពី ៥០០០ ដុល្លា — ៥០០០០ ដុល្លា | ៩ |
| ចន្លោះពី ៥០ ០០០ ដុល្លា — ១៥០ ០០០ ដុល្លា | ០ |
| ចន្លោះពី ១៥០ ០០០ ដុល្លា — ៥០០ ០០០ ដុល្លា | ០ |
| ច្រើនជាង ៥០០ ០០០ ដុល្លា | ០ |
| ចម្លើយសរុប | ១០ |

| សំណួរទី ៦: តើលោក_អ្នក បដិសេធឱកាសវិនិយោគ ដោយសារតែហានិភ័យនៃការប្ដឹងចោទពីបទល្មើសរំលោភលើ សេចក្ដីទុកចិត្ត ញឹកញាប់ប៉ុណ្ណា? | |
|---|---|
| ញឹកញាប់ណាស់ | ៣ |
| ញឹកញាប់ | ៣ |
|ម្ដងម្កាល | ៣ |
| មិនធ្លាប់ | ១ |
| ចម្លើយសរុប | ១០ |

| សំណួរទី ៧: តើឱកាសវិនិយោគដែលលោក-អ្នកបានបដិសេធ ដោយសារតែហានិភ័យនៃការប្តឹងចោទពីបទល្មើស រំលោភលើសេចក្តីទុកចិត្ត មានតម្លៃគិតជាទឹកប្រាក់ប៉ុន្មានដែរ? | |
|---|---|
| ច្រើនជាង ៥០ ០០០ ដុល្លា | ២ |
| ចន្លោះពី ៥០ ០០០ ដុល្លា — ២៥០ ០០០ ដុល្លា | ០ |
| ចន្លោះពី ២៥០ ០០០ ដុល្លា — ៥០០ ០០០ ដុល្លា | ២ |
| ចន្លោះពី ៥០០ ០០០ ដុល្លា — ១ ០០០ ០០០ ដុល្លា | ១ |
| ចន្លោះពី ១ លានដុល្លា — ៥ លានដុល្លា | ២ |
| ច្រើនជាង៥ លានដុល្លា | ០ |
| ចម្លើយសរុប | ៧ |

សំណួរទី ៨: ចំពោះទស្សនៈផ្ទាល់របស់លោក-អ្នក តើការផ្លាស់ប្តូរខាងក្រោមនេះ អាចជួយកែប្រែស្ថានភាព អោយបានល្អ ប្រសើរឡើង ក្នុងកំរិតណាដែរ?

| | ហ្វឹកហ្វឺន និង បំពាក់បំប៉ន បន្ថែម ដល់នគរបាល | ហ្វឹកហ្វឺននិង បំពាក់បំប៉ន បន្ថែម ដល់ចៅក្រម | កាត់បន្ថយ ការឃុំខ្លួន មុនការជំនុំជំរះក្តី | លុបបំបាត់ចោល ទោសជាប់ពន្ធនាគារសម្រាប់ រឿងក្តីរំលោភ លើសេចក្តីទុកចិត្ត | បង្កើតតុលាការ ពាណិជ្ជកម្មពិសេស មួយសម្រាប់ដោះស្រាយរឿងក្តីរំលោភ លើសេចក្តីទុកចិត្ត |
|---|---|---|---|---|---|
| ប្រសើរខ្លាំង | ៥ | ៦ | ៤ | ១ | ៦ |
| ប្រសើរមធ្យម | ២ | ២ | ២ | ២ | ២ |
| ប្រសើរ | ១ | ១ | ៣ | ២ | ១ |
| មិនប្រសើរអ្វីទេ | ១ | ០ | ០ | ៣ | ០ |
| ចម្លើយសរុប | ៩ | ៩ | ៩ | ៨ | ៩ |

## ឧបសម្ព័ន្ធ ៥

# ការវិភាគបច្ចេកទេសផ្នែកច្បាប់ នៃមាត្រាស្តីអំពី ការរំលោភលើសេចក្តីទុកចិត្ត

## បទរំលោភលើសេចក្តីទុកចិត្ត

ដោយលោក កុយ នាម

### ក. សេចក្តីផ្តើម

បទរំលោភលើសេចក្តីទុកចិត្តគឺជាបទល្មើសមួយ ក្នុងបណ្តាបទល្មើសជាច្រើនទៀតប្រឆាំងនឹងទ្រព្យសម្បត្តិ។ បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិដែលគេដឹងជាទូទៅគឺការលួច។ លក្ខណៈសំខាន់នៃការលួចគឺ ទាក់ទងនឹងការដកហូតយករបស់ពីអ្នកណាម្នាក់ ដែលស្ថិតនៅក្នុងការកាន់កាប់របស់ជននោះ ដើម្បីឱ្យជននោះ បាត់បង់អំណាចកាន់កាប់របស់នោះជាអចិន្ត្រៃយ៍។ ការខុសគ្នានៃបទរំលោភលើសេចក្តីទុកចិត្តពីការលួចគឺថា នៅក្នុងការលួច ជនល្មើសមិនមានការកាន់កាប់ដោយស្របច្បាប់ទេ ចំណែកឯនៅក្នុងបទរំលោភលើសេចក្តីទុកចិត្តជនល្មើសមានការកាន់កាប់របស់ស្របច្បាប់ជាស្រេច ដោយមានការព្រមព្រៀងពីម្ចាស់ទៀតផង។ ជនល្មើសរំលោភលើការព្រមព្រៀងនេះ ដោយបន្លំដកហូតយកទ្រព្យរបស់ម្ចាស់មកធ្វើជារបស់ខ្លួន ឬជន្លៀសទ្រព្យនោះទៅឱ្យអ្នកណាម្នាក់ទៀត។ បើនិយាយជាភាសាសាមញ្ញ បទរំលោភទាំងពីរនេះគឺស្រដៀងគ្នា ដោយសារគោលបំណងនៃអំពើប្រព្រឹត្តមានដូចគ្នា គឺធ្វើឱ្យម្ចាស់បាត់បង់សម្បត្តិរបស់ខ្លួន។

ដោយសារបទល្មើសរំលោភលើសេចក្តីទុកចិត្តមានពាក្យ "រំលោភ" និង "ទុកចិត្ត" នៅក្នុងជីវិតជាក់ស្តែងគេតែងតែយល់ថា ការដែលកូនបំណុលធ្វើឱ្យម្ចាស់បំណុល "ខកចិត្ត" ឬ "បាត់បង់ការទុកចិត្ត" ដោយសារការមិនបានបំពេញតាមបំណងចិត្ត ពីសំណាក់កូនបំណុលចំពោះម្ចាស់បំណុល គឺការសងបំណុលតាមការសន្យា ដូច្នេះម្ចាស់បំណុលតែងតែចោទកូនបំណុលថាបាន "រំលោភសេចក្តីទុកចិត្ត"។ និយាយឱ្យងាយយល់ ករណីបែបនេះជាការរំលោភលើការសន្យា មិនមែនលើសេចក្តីទុកចិត្តទេ។ បទរំលោភសេចក្តីទុកចិត្តប្រហាក់ប្រហែលគ្នានឹងការលួច។

## ២. វិភាគអំពីរចនាសម្ព័ន្ធឃ្លាប្រយោគ និងសព្ទនៅក្នុងមាត្រា ៤៦ ស្ដីពី ការរំលោភលើសេចក្ដីទុកចិត្ត

បើធ្វើការប្រៀបធៀបរវាងមាត្រា៤០៨នៃក្រមព្រហ្មទណ្ឌចាស់របស់ប្រទេសបារាំង និងមាត្រា ៤៦ ស្ដីពីការរំលោភលើទំនុកចិត្តក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលរបស់ខ្មែរ គេអាចសន្និដ្ឋានបានថា ច្បាប់ខ្មែរស្ដីពីការរំលោភសេចក្ដីទុកចិត្ត ត្រូវបានចម្លងពីច្បាប់បារាំងនេះស្ទើរតែទាំងអស់។ ការនេះពិតជាដូច្នេះ ព្រោះថាច្បាប់ព្រហ្មទណ្ឌអន្តរកាល នេះត្រូវបានព្រាងដោយអ្នកជំនាញការបារាំងដែរនៅក្នុងឆ្នាំ១៩៩២។ តែនៅឆ្នាំ ១៩៩៤ បារាំងបានអនុម័តក្រមព្រហ្មទណ្ឌថ្មី ហើយឥឡូវនេះអ្នកជំនាញការច្បាប់បារាំងក៏បានមកជួយព្រាងក្រមព្រហ្មទណ្ឌឱ្យខ្មែរម្ដងទៀត។ បើយើងមើលអត្ថបទព្រាងនៃក្រមព្រហ្មទណ្ឌខ្មែរ មាត្រា៤០៤ (ស្ដីពីការរំលោភលើទំនុកចិត្ត) យើងឃើញថាម្ដងនេះទៀត យើងបានចម្លងពីមាត្រាថ្មី ៣១៤-១របស់បារាំងស្ដីពីបទល្មើសដូចគ្នានេះ។

ការបកប្រែពីអត្ថបទពីភាសាបរទេស មកជាភាសាខ្មែរតែងតែមានបញ្ហា តាំងពីវាក្យស័ព្ទ (vocabulary) រហូតដល់វាក្យសម្ព័ន្ធ (syntax)។ ឧទាហរណ៍ នៅក្នុងមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ពាក្យបារាំង représenter ត្រូវបានប្រែមកជាភាសាខ្មែរថា "តំណាង" ដែលពាក្យក្នុងន័យនៃច្បាប់នេះ គេគួរប្រែថា "បង្ហាញ" វិញទើបសមស្របនឹងអត្ថន័យរបស់វាពាក្យខ្លះទៀត ដូចជា possesseur និង détenteur ជាដើមគឺជាពាក្យពិបាកនឹងរកពាក្យខ្មែរមកដាក់ ព្រោះវាស្រដៀងៗគ្នា។ម្យ៉ាងវិញទៀត យើងឃើញទៀតថា ដោយសារខ្មែរយើងមិនប្រើក្បៀស[១] កំហុសក្នុងការវាយអក្សរដោយមិនបានដកឃ្លាធ្វើឱ្យ គេអានច្រឡំន័យរបស់ឃ្លា ដូចមានបង្ហាញនៅខាងក្រោម។ ដោយសារការបកប្រែ និងវាក្យសម្ព័ន្ធមានបញ្ហាខ្លះផង ការគ្រាន់តែអានអត្ថបទច្បាប់ ដោយមិនបានយល់ដល់គោលបំណង និងស្មារតីរបស់ច្បាប់ អាចធ្វើឱ្យយើងយល់ច្បាប់នោះខុសប្រាសចាកឆ្ងាយពីន័យពិតប្រាកដរបស់វា។

សូមអានមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលមានសេចក្ដីដូចតទៅនេះ ដែលយើងចម្លងឱ្យត្រូវទាំងស្រុង តាមលក្ខណៈនៃការសរសេរដើម:

> **មាត្រា ៤៦ : ការរំលោភលើសេចក្ដីទុកចិត្ត**
>
> ជនណាដែលតែបន្លំ ឬបំបាត់ អោយខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់ទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញ ឬគ្រប់ឯកសារដែលមាន ឬដែលចែងអំពីកាតព្វកិច្ច ឬការដោះបន្ទុកដែលគេប្រគល់អោយមកខ្លួន ក្នុងលក្ខណៈជាការជួល ជាការដាក់ផឹកល់ទុក ជាអាណត្តិ ជាការអោយខ្ចីប្រើ ឬដើម្បីការងារមានបៀវត្ស ឬគ្មានបៀវត្ស ដែលត្រូវប្រគល់អោយគេវិញ ឬធ្វើជាតំណាង ឬសំរាប់ប្រើប្រាស់ ឬជាមុខការមានកំណត់ ត្រូវមានទោសមជ្ឈិមពីបទរំលោភលើទំនុកចិត្ត ហើយត្រូវផ្ដន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

[១] តែទោះជាយ៉ាងណាក្ដីខ្ញុំបានឃើញមានការប្រើក្បៀសជារឿយៗនៅក្នុងក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ ១៩៥៩។ (សូមមើលជាឧទាហរណ៍ ត្រង់ចាប់ពីមាត្រា ៣៦៦ ឡើងទៅ)។

យើងសង្កេតឃើញថា ការមិនបានដកឃ្លាឬការមិនប្រើអាយតនិបាត (preposition) ដើម្បីបំបែកឱ្យដាច់រវាង "អ្នកកាន់កាប់" និង"ទ្រព្យសម្បត្តិ" អាចឱ្យអ្នកអានយល់ច្រឡំថា ការតែបន្លំ ឬការតែបំបាត់ ធ្វើឱ្យខូចប្រយោជន៍ ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់ទ្រព្យសម្បត្តិ។[២] ការពិតមាត្រានេះចង់ និយាយអំពីការតែបន្លំនូវទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញ ឬឯកសារ (ដែលចែងអំពីកាតព្វកិច្ច ឬដែលមានចែងពីការដោះបន្ទុក) គឺមិនមែនតែបន្លំអ្នកកាន់កាប់ទ្រព្យសម្បត្តិទេ។ ចំពោះអ្នកដែលត្រូវតែបន្លំនោះគឺ ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់។ ពាក្យ "ម្ចាស់កម្មសិទ្ធិ" ស្មើនឹងពាក្យបារាំងថា propriétaire ដែលជាអ្នកមានកម្មសិទ្ធិស្របច្បាប់ដើម្បីប្រើប្រាស់ ទទួលផល ចាត់ចែង (ដូចជាលក់ ធ្វើអំណោយជាដើម)។ យោងតាមលំដាប់ពាក្យដែលប្រើក្នុងអត្ថបទជាភាសាបារាំង ពាក្យ "ម្ចាស់ទីកន្លែង" ប្រហែលជាប្រែមកពី ពាក្យបារាំង possesseurs និងពាក្យ "អ្នកកាន់កាប់" ប្រែមកពី détenteur ព្រោះក្នុងអត្ថបទបារាំងគេដាក់តាមលំដាប់ propriétaires, possesseurs និង détenteurs។ ពាក្យទាំងពីរនេះ បើប្រែជាពាក្យសាមញ្ញស្មើរតែមានន័យថាកាន់កាប់ដូចគ្នា ប៉ុន្តែមានស្ថានភាពគតិយុត្តខុសគ្នាខ្លះ។[៣] ម្ចាស់កម្មសិទ្ធិមាន ដូចជាម្ចាស់រថយន្តដែលមានលិខិតកម្មសិទ្ធិត្រឹមត្រូវ។ Possesseurs មានដូចជាអ្នកដែលមានរថយន្ត តែមិនទាន់បានចុះបញ្ជីកម្មសិទ្ធិ ឬភោគីដី ចំណែកឯ détenteurs មានដូចជាអ្នកជួលផ្ទះគេនៅ អ្នកទទួលវត្ថុដែលគេដឹកលំទុកជាមួយ ឬ អ្នកទទួលរបស់គេទុកលក់ជាដើម។ ដើម្បីភាពងាយស្រួលក្នុងការសរសេរអត្ថបទនេះ ចាប់ពីចំណុចនេះទៅ បើអ្នកអាន ឃើញពាក្យ "ម្ចាស់របស់" ឬ "ម្ចាស់វត្ថុ ពាក្យនេះសំដៅដល់មនុស្សប្រភេទណាមួយនៃប្រភេទទាំងបីគឺ propriétaires, possesseurs និង détenteurs ។

តមកទៀតសួរថា តើគេប្រគល់ឱ្យតាមរបៀបណា?។ ចម្លើយ យើងឃើញថា ទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញ ឬឯកសារ ត្រូវបានប្រគល់មកឱ្យអ្នកដែលត្រូវជាប់ចោទពីបទរំលោភលើសេចក្តីទុកចិត្ត ជារបៀបជួល ឱ្យជារបៀបដាក់តំកល់ទុក ជាអាណត្តិ ជាការឱ្យខ្ចី ប្រគល់ឱ្យដើម្បីបំពេញការងារអ្វីមួយ (ដែលជននោះធ្វើយកកំរៃក្តី ឬមិនយកកំរៃក្តី)។

ចុងបំផុត ជនដែលត្រូវជាប់ចោទត្រូវប្រគល់ឱ្យម្ចាស់គេវិញ ឬថាត្រូវប្រើប្រាស់វាឱ្យត្រូវតាមគោលដៅដែលម្ចាស់ចង់ឱ្យប្រើ។ ក្នុងនេះដែរ យើងឃើញមានពាក្យ "ធ្វើជាតំណាង"។ យើងនឹងពិនិត្យនៅខាងក្រោយថា តើពាក្យនេះមានន័យដូចម្តេច។

ដើម្បីឱ្យងាយយល់គេគួរបំបែកឃ្លាផ្សេងៗនៅក្នុងមាត្រា ៤៦ តាមរបៀបដូចតទៅនេះ

[២] ពាក្យ possesseurs គឺសំដៅដល់ជនដែលមាន possession និង détenteur បានដល់ជនដែលមាន détention ។ គោលគំនិតគតិយុត្តនៃពាក្យ possession និង détention មានលក្ខណៈវែងឆ្ងាយមិនគួរយកមកបរិយាយនៅទីនេះទេ ប៉ុន្តែ អ្នកអានអាចរកឃើញនៅក្នុងគោលគំនិតច្បាប់ទាក់ទងនឹងកម្មសិទ្ធិ ជាពិសេសគោលគំនិត corpus និង animus ។

[៣] ពាក្យ possesseurs គឺសំដៅដល់ជនដែលមាន possession និង détenteur បានដល់ជនដែលមាន détention ។ គោលគំនិតគតិយុត្តនៃពាក្យ possession និង détention មានលក្ខណៈវែងឆ្ងាយមិនគួរយកមកបរិយាយនៅទីនេះទេ ប៉ុន្តែ អ្នកអានអាចរកឃើញនៅក្នុងគោលគំនិតច្បាប់ទាក់ទងនឹងកម្មសិទ្ធិ ជាពិសេសគោលគំនិត corpus និង animus ។

១. ជនណាដែលគៃបន្លំ ឬបំបាត់ឱ្យខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬអ្នកកាន់កាប់នូវ :

ក. ទ្រព្យសម្បត្តិ

ខ. ប្រាក់កាស

គ. ទំនិញ ឬ

ឃ. គ្រប់ឯកសារដែលមាន ឬចែង

ឃ១. កាតព្វកិច្ច ឬ

ឃ២. ការដោះបន្ទុក

២. ដែលគេប្រគល់ឱ្យមកខ្លួន

ក. ក្នុងលក្ខណៈជា :

ក១. ការជួល

ក២. ការដំកល់ទុក

ក៣. អាណត្តិ

ក៤. ការឱ្យខ្ចីប្រើ

ខ. ដើម្បីការងារមានបៀវត្ស ឬគ្មានបៀវត្ស

៣. ដែលត្រូវប្រគល់ឱ្យគេវិញ ឬធ្វើជាតំណាង[៤] ឬសំរាប់ប្រើប្រាស់ ឬជាមុខការមានកំណត់

៤. ត្រូវមានទោសមជ្ឈិមពីបទរំលោភលើទំនុកចិត្ត ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

តាមការបំបែកអត្ថបទនៃមាត្រា ៤៦ នេះយើងឃើញថា មាត្រានេះមានរចនាសម្ព័ន្ធដូចតទៅនេះ :

១. អំពើគៃបន្លំ ឬ បំបាត់ និងបច្ច័យនៃអំពើនេះ (ការខូចខាតប្រយោជន៍ដែលម្ចាស់វត្ថុត្រូវរងដោយសារអំពើគៃបន្លំ ឬបំបាត់)

២. វត្ថុឬកម្មវត្ថុនៃអំពើគៃបន្លំ ឬ បំបាត់ (ដូចជាទ្រព្យសម្បត្តិ ប្រាក់កាស ។ល។)

៣. ការផ្ទុកផ្តាក់វត្ថុ ឬកម្មវត្ថុនេះនៅជាមួយនឹងជនដែលត្រូវជាប់ចោទពីអំពើគៃបន្លំ ឬបំបាត់ ព្រមទាំងលក្ខខ័ណ្ឌនិងគោលបំណងនៃការផ្ទុកផ្តាក់នេះ (ដូចជា ផ្ទុកផ្តាក់ជាបៀបជួលឱ្យជាការដំកល់ ជាការឱ្យខ្ចីជាដើម)

៤. លក្ខខ័ណ្ឌមួយដែលបញ្ជាក់ថាម្ចាស់វត្ថុឬកម្មវត្ថុមិនមានបំណងបោះបង់កម្មសិទ្ធិ ឬ ផលប្រយោជន៍លើវត្ថុ ឬកម្មវត្ថុរបស់ខ្លួន ដោយកំណត់ថា ត្រូវតែប្រគល់ ឬបង្ហាញវត្ថុនោះមកខ្លួនវិញតាមពេលកំណត់ជាមុន ឬតាមការចង់បាន ឬចង់ឃើញរបស់ពីសំណាក់ម្ចាស់

៥. ផ្នែកចុងក្រោយ គឺការកំណត់កំរិតទោសដល់ជនដែលគៃបន្លំ ឬបំបាត់វត្ថុនោះ ។

[៤] ពាក្យនេះគួរដាក់ថា "បង្ហាញឡើងវិញ" ។

## គ. ធាតុផ្សំនៃបទល្មើសរំលោភលើសេចក្ដីទុកចិត្ត

### គ.១ ធាតុផ្សំសំភារៈ

ធាតុផ្សំខាងអំពើ គឺសំដៅដល់ ការកែបន្លំ ឬការបំបាត់ ។ ការកែបន្លំ ឬ ការបំបាត់នេះនឹងកើតមានឡើងនៅពេលណាដែលម្ចាស់វត្ថុ លែងអាចអនុវត្តសិទ្ធិរបស់ខ្លួនលើវត្ថុនោះ បន្ទាប់ពីការប្រព្រឹត្តបោកបន្លំ ពីសំណាក់អ្នកដែលគេបានផ្ញើផ្ដាក់វត្ថុនោះនៅជាមួយ ។

ការកែបន្លំ ឬការបំបាត់នៅក្នុងបទល្មើសរំលោភលើសេចក្ដីទុកចិត្ត មានការខុសគ្នាពីការលួចត្រង់ប្រការដែលថា នៅក្នុងការលួច ម្ចាស់វត្ថុមិនបានផ្ញើផ្ដាក់វត្ថុជាមួយអ្នកលួចទេ ។ ចំណែកឯនៅក្នុងបទល្មើសលើការរំលោភលើសេចក្ដីទុកចិត្ត ម្ចាស់វត្ថុបានទុកដាក់វត្ថុជាមួយជនជាប់ចោទ តាមរយៈការព្រមព្រៀងគ្នាមួយ ។ ការព្រមព្រៀងនេះបង្កើតបានជាកិច្ចសន្យាមួយ ដូចជាកិច្ចសន្យាជួលរថយន្តឱ្យអតិថិជនម្នាក់ទៅដឹកទំនិញជាដើម ។ កិច្ចសន្យានេះបានបង្កើតទំនាក់ទំនងមួយរវាងម្ចាស់របស់ និងអ្នកទទួលទុកដាក់របស់ ដែលអ្នកទទួលរបស់មានករណីយកិច្ចចំបងមួយហៅថា "ករណីយកិច្ចបំពេញទំនុកចិត្ត" ដែលភាសាអង់គ្លេសហៅថា "fiduciary duty" ។ អ្នកទទួលទុកដាក់របស់ត្រូវបំពេញករណីយកិច្ចរក្សាសុទ្ធចិត្តរបស់ខ្លួន ការជាទីទុកចិត្តរបស់អ្នកប្រគល់ និងភាពទៀងត្រង់មិនវៀចវេរចំពោះអ្នកប្រគល់ ។ ការកែបន្លំ ឬ ការបំបាត់ នឹងកើតមានឡើងនៅពេលណាអ្នកដែលទទួលទុកដាក់វត្ថុបានល្មើសលើករណីយកិច្ចនេះ ។

ដូច្នេះ កាលណាគេនិយាយអំពីបទល្មើសលើសេចក្ដីទុកចិត្ត ចំណុចមុនដំបូងបង្អស់ដែលត្រូវចោទសួរនោះគឺថា តើអ្នកទាំងពីរបានបង្កើតទំនាក់ទំនងកិច្ចសន្យាដែរឬទេ ។ នៅក្នុងមាត្រានៃបទល្មើសលើសេចក្ដីទុកចិត្ត គេបានរៀបរាប់កិច្ចសន្យា ឬទំនាក់ទំនងចំនួន ៥ គឺ កិច្ចសន្យាជួល កិច្ចសន្យាដាក់ដំកល់ទុក អាណត្តិ កិច្ចសន្យា ឱ្យខ្ចីប្រើ និងកិច្ចសន្យាការងារ ។[៥] ការដែលយើងមិនដាក់អាណត្តិជាកិច្ចសន្យានៅទីនេះ ពីព្រោះអាណត្តិនេះអាចកើតឡើងពីកិច្ចសន្យា ឬ ពីអំណាចតុលាការ ឬ អំណាចច្បាប់ ។ យើងនឹងពិភាក្សាបញ្ហានេះ នៅផ្នែកខាងក្រោយទៀត ។

### គ.២ ធាតុផ្សំខាងផ្លូវសតិ

ដូចគ្នានឹងបទល្មើសព្រហ្មទណ្ឌដទៃទៀតដែរ បទរំលោភលើសេចក្ដីទុកចិត្តតម្រូវឱ្យមានចេតនាដើម្បីប្រព្រឹត្តការកែបំបាត់ ។ ចេតនានេះគឺជាចេតនាបន្លំ (fraudulent intent) ។ ចេតនាបន្លំអាចសន្និដ្ឋានចេញពីការមិនស្មោះត្រង់ចំពោះអ្នកប្រគល់ ។ ឧទាហរណ៍ ជាងមាសដែលទទួលភារៈធ្វើខ្សែក ហើយបែរជាកាត់យកដុំមាសខ្លះ រួចហើយបញ្ចូលលោហៈផ្សេងដើម្បីបង្គ្រប់ទម្ងន់ដើមវិញ ។ បើជាងមាសគ្មានហេតុផលអ្វីពន្យល់ ក្រៅពីចង់យកដុំមាសខ្លះធ្វើជារបស់ខ្លួនទេនោះ នៅពេលនេះអសុទ្ធចិត្ត ពិតជាបានកើតឡើង ។

ផ្ទុយទៅវិញ បទល្មើសរំលោភលើសេចក្ដីទុកចិត្តមិនអាចកើតឡើងបានទេ បើគេមិនអាចបង្ហាញថា ជនជាប់ចោទមានចេតនាបន្លំ ។ ឧទាហរណ៍ លោក **ចាន់** នៅភ្នំពេញ ទទួលប្រាក់ពីមិត្តភ័ក្ដ្រ

[៥] ក្រមព្រហ្មទណ្ឌបារាំងថ្មី និងសេចក្ដីព្រាងក្រមព្រហ្មទណ្ឌថ្មីរបស់ខ្មែរមិនបានរាយពីប្រភេទនៃកិច្ចសន្យាដែលជាកម្មវត្ថុនៃច្បាប់ស្ដីពីបទរំលោភលើសេចក្ដីទុកចិត្តទេ ។

របស់ខ្លួន គឺលោក **ទាវសនា** នៅខេត្តបាត់ដំបង ដើម្បីទុកបង់ថ្លៃសាលាឱ្យកូន លោក **ទាវសនា** រៀន នៅភ្នំពេញ ដោយ លោក **ទាវសនា** យល់ព្រមឱ្យលោក **ចាន់** កាត់យកប្រាក់៥ភាគរយដើម្បីប្រើប្រាស់ ផ្ទាល់ខ្លួន។ នៅពេលដែលមានមនុស្សម្នាក់មកសុំចងការ ដោយសន្យាឱ្យចុងការខ្ពស់គួរសម លោក **ចាន់** ក៏ព្រមចងការឱ្យ ដោយគិតថានឹងធ្វើឱ្យទឹកប្រាក់ **ទាវសនា** បានកើនច្រើនបន្តិច។ តែក្រោយមក អ្នកខ្ចីប្រាក់នោះគេចបាត់មិនព្រមសង។ ក្នុងករណីនេះ លោក **ចាន់** ហាក់ដូចជាមិនមានចេតនានឹងបន្លំ ធ្វើឱ្យមិត្តរបស់ខ្លួនខូចខាតទេ។ តែយ៉ាងណាក្តី លោក **ចាន់** នៅតែទទួលខុសត្រូវសងសំណងរដ្ឋប្បវេណី ដោយសារគាត់រំលោភលើខកិច្ចសន្យាដែលតម្រូវឱ្យគាត់ទុកដាក់ប្រាក់នោះដើម្បីបង់ថ្លៃសាលា។

ផ្ទុយទៅវិញបើ លោក **ចាន់** យកប្រាក់ដែលផ្ញើទុកនោះទៅលេងល្បែងស៊ីសងហើយចាញ់ មិនអាចបង់ថ្លៃសាលាឱ្យកូនលោក**ទាវសនា** បាន គាត់ទំនងជាមានចេតនាបន្លំ ព្រោះគាត់គួរតែបានដឹងថា គ្រោះនៃការចាញ់ល្បែងមានកំរិតស្ទើរតែមួយរយភាគរយសំរាប់អ្នកលេងល្បែងទូទៅ។ អសុទ្ធចិត្តរបស់ ចុងចោទអាចត្រូវ សន្និដ្ឋានចេញពីកាលៈទេសៈជុំវិញអំពើរបស់គេ ដែលមនុស្សទូទៅអាចប្រមាណទុក បានថាអំពើនោះនឹងនាំមក នូវលទ្ធផលធ្វើឱ្យខូចខាតដល់ម្ចាស់របស់។

### គ.៣ ព្យសនកម្ម

ទោះបីធាតុផ្សំខាងលើត្រូវបានរកឃើញក្តី តែបើផលនៃការកែបន្លំមិននាំឱ្យមានការខូចខាត ដល់ម្ចាស់របស់ទេនោះ បទរំលោភលើសេចក្តីទុកចិត្តក៏មិនអាចកើតឡើងបានដែរ។ ព្យសនកម្មកើតឡើង កាលណា ម្ចាស់វត្ថុបាត់បង់ឬមិនអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនទៅលើវត្ថុដែលប្រគល់ទៅឱ្យចុងចោទ។

ក៏ប៉ុន្តែ ក្នុងករណីដល់ពេលប្រគល់វត្ថុទៅម្ចាស់ដើមវិញ តែចុងចោទមានការយឺតយ៉ាវ ក្នុងការប្រគល់វត្ថុនោះ ក៏មិនមែនមានន័យដាច់ខាតចុងចោទ បានប្រព្រឹត្តបទរំលោភលើសេចក្តីទុកចិត្ត ដែរ។ ការរងគ្រោះបាត់បង់វត្ថុរបស់ម្ចាស់ត្រូវលេចចេញពីលទ្ធផលនៃចេតនាបន្លំពិតៗរបស់ចុងចោទ។

## ឃ. វត្ថុឬកម្មវត្ថុនៃបទរំលោភ

មាត្រា ៤៦ នៃបទរំលោភលើសេចក្តីទុកចិត្តអនុវត្តបានលើវត្ថុដែលបានរៀបរាប់ក្នុងមាត្រានេះ ដូចជា ទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញ និងឯកសារ ដែលមានឬចែងអំពីកាតព្វកិច្ចឬការដោះបន្ទុក។[៦]

### ឃ.១ ទ្រព្យសម្បត្តិ

គេមិនដឹងច្បាស់ថា ពាក្យថាទ្រព្យសម្បត្តិនៅក្នុងមាត្រានេះ រាប់បញ្ចូលចលនទ្រព្យនិង អចលនទ្រព្យ ឬយ៉ាងណានោះទេ។ ដោយសារច្បាប់នេះត្រូវបានចម្លងចេញពីច្បាប់ព្រហ្មទណ្ឌបារាំង

[៦] ក្រមព្រហ្មទណ្ឌបារាំងថ្មី និងសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីរបស់ខ្មែរមិនបានរាយក្នុងលក្ខណៈមានកំរិតអំពីវត្ថុដែលស្ថិត ក្នុងវង្វង់ដែន អនុវត្តនៃច្បាប់ស្តីពីការរំលោភលើសេចក្តីទុកចិត្តដូចមុនទៀតទេ ដោយគ្រាន់តែរាប់បញ្ចូល "មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ"។ សូមមើលមាត្រា ៣១៤-១ នៃក្រមព្រហ្មទណ្ឌបារាំង និង មាត្រា ៤០៤ នៃសេចក្តីព្រាងក្រម ព្រហ្មទណ្ឌខ្មែរ។

គេគួរពិនិត្យមើលឫសគល់នៃពាក្យនេះ។ ទ្រព្យសម្បត្តិនៅក្នុងមាត្រា ៤៦ ដែលជាភាសាបារាំង គឺពាក្យ **"Biens"** ។ នៅក្នុង សាលដីការបស់សាលាវិនិច្ឆ័យបារាំងលេខ៦២៩៥ ចុះថ្ងៃទី១០ តុលា២០០១ ចែងថា "បទរំលោភលើសេចក្តីទុកចិត្តអាចទាក់ទងតែនឹង មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិផ្សេងៗ លើកលែងតែអចលនទ្រព្យចេញ"។ តុលាការនេះបន្តនៅចុងបញ្ចប់នៃសាលដីកាថា *"សាលាឧទ្ធរណ៍ ដែលផ្តន្ទាការប្រើប្រាស់ដោយរំលោភនូវ អចលនវត្ថុមួយ ដោយសារតែការមិនប្រគល់កូនសោដើម្បីឱ្យគេអាចចេញចូលក្នុងអចលនវត្ថុនោះបាន គឺមិនយល់ពីអត្ថន័យនិងដែនអនុវត្តនៃអត្ថបទច្បាប់ដែលបញ្ជាក់ខាងលើ"។*[៧]

ចំពោះប្រទេសបារាំង ហេតុផលដែលថា បទរំលោភនេះមិនអនុវត្តលើអចលនវត្ថុគឺដោយសារម្ចាស់អាចយកទ្រព្យរបស់ខ្លួនវិញបានដោយសារគេមានសិទ្ធិតាមយកវិញ **(droit de suite)**[៨] ។ ហេតុផលនេះអាចថាសមហេតុសមផល ដោយសារប្រទេសនេះមានប្រព័ន្ធកត់ត្រាកម្មសិទ្ធិ និងប្រវត្តិនៃការផ្ទេរ ឬផ្លាស់ប្តូរកម្មសិទ្ធិ ត្រឹមត្រូវនិងជាក់លាក់ កម្មសិទ្ធិលើអចលនវត្ថុមានស្ថេរភាពនិងមានយន្តការការពារហ្មឹងម៉ាត់ ដែលការបំបាត់ឬបង្វែរមិនអាចនឹងធ្វើបានដោយគ្មានការយល់ព្រមពីម្ចាស់។ ចំណែកឯចលនវត្ថុវិញពុំមានការការពារដូចអចលនវត្ថុទេ លើកលែងតែម្ចាស់មានលិខិតកម្មសិទ្ធិជាភស្តុតាង។

នៅប្រទេសអាមេរិក រដ្ឋខ្លះជាពិសេសនៅរដ្ឋអូក្លាហូម៉ា តុលាការឧទ្ធរណ៍ព្រហ្មទណ្ឌនៃ រដ្ឋនេះបានបកស្រាយទ្រព្យសម្បត្តិដែលចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌនៃរដ្ឋនេះថាជាចលនទ្រព្យ ទោះបីនៅក្នុងច្បាប់គេពុំបានចែងថាចលនទ្រព្យក្តី។ តុលាការរដ្ឋខ្លះ និងអ្នកនិពន្ធច្បាប់ខ្លះយល់ថា ការកៃបន្លំអាចរាប់បញ្ចូល អចលនទ្រព្យដែរ ប៉ុន្តែក៏មានតុលាការ និងអ្នកនិពន្ធខ្លះទៀតដែលយល់ថា បទល្មើសនេះគ្របដណ្តប់តែលើចលនទ្រព្យប៉ុណ្ណោះ។ តុលាការឧទ្ធរណ៍ព្រហ្មទណ្ឌ រដ្ឋអូក្លាហូម៉ា បានសន្និដ្ឋានថា បទល្មើសកៃបន្លំមានដើមកំណើតពីបទល្មើសលួច។ បទល្មើសលួច ដែលគ្របដណ្តប់តែចលនវត្ថុ ហើយមានធាតុផ្សំមួយគឺ "ការហូតយកទៅបាត់" នូវ "វត្ថុដែលជនល្មើសមិនមានភោគៈស្របច្បាប់" នោះបញ្ជាក់ឱ្យឃើញថា ច្បាប់ស្តីពីការលួចមិនអាចអនុវត្តបានចំពោះការកៃបន្លំវត្ថុ ដែលនៅក្នុងនោះជនល្មើសមានភោគៈស្របច្បាប់។ ដូច្នេះបទល្មើសស្តីពីការកៃបន្លំ គ្រាន់តែបន្ថែមចន្លោះប្រហោងដែលមាននៅច្បាប់ទាក់ទងនឹងបទល្មើសលួចប៉ុណ្ណោះ ដោយបន្ថែមធាតុផ្សំនៃ "ការដកហូតវត្ថុអ្នកដទៃដែលស្ថិតនៅក្នុងការកាន់កាប់ស្របច្បាប់របស់ជនល្មើស"។[៩]

បើអនុវត្តហេតុផលខាងលើមកប្រទេសខ្មែរវិញ គឺច្បាប់ស្តីពីបទរំលោភលើសេចក្តីទុកចិត្តផ្តន្ទាទោសតែទៅលើការប្រព្រឹត្តលើចលនវត្ថុជាជាងអចលនវត្ថុនោះ នៅប្រទេសខ្មែរអាចមានគុណវិបត្តិច្រើន ដោយសារម្ចាស់អចលនវត្ថុភាគច្រើនគ្មានលិខិតកម្មសិទ្ធិសំរាប់សំគាល់កម្មសិទ្ធិស្របច្បាប់របស់ខ្លួន ហើយពុំទាន់មាន ប្រព័ន្ធកត់ត្រាមាំទាំ ដែលជាការងាយក្នុងការកៃបន្លំឬបង្វែកម្មសិទ្ធិអ្នកដទៃ។

---

[៧] http://lexinter.net/JPTXT/bien_quelconque.htm, ៩ ឧសភា ២០០៣។

[៨] Françoise SIBAUD, De L'Abus de Confiance; <http://lexilis.free.fr/notesjur/note55.htm>

[៩] យោបល់របស់គណៈកម្មាធិការ, www.okcca.net/datafiles/legal/oklahoma/ouji/criminal/OUJI-CR%205-21.html

ឧទាហរណ៍នៃទ្រព្យសម្បត្តិមានដូចជា រថយន្តដែលគេទុកឱ្យជាងជួសជុល គ្រឿងអលង្កាដែលដាក់បញ្ចាំយានជំនិះដែលផ្ញើនៅទីផ្សារ ។ល ។

### ឃ.២ ប្រាក់កាស និង ទំនិញ

ប្រាក់កាស និងទំនិញគឺជាវត្ថុដែលងាយឱ្យនិយមន័យជាងគេ ។ ឧទាហរណ៍ ប្រាក់ដែល គណនេយ្យករកាន់កាប់ប្រាក់ដែលផ្ញើទុកនឹងអ្នកណាម្នាក់ ទំនិញដែលទទួលដឹកជញ្ជូនដោយក្រុមហ៊ុនដឹកនាំទំនិញដែលផ្ញើទុកក្នុងឃ្លាំង ។ល ។

នឹងកើតមានការកែបន្លំ កាលណាជនណាម្នាក់យកប្រាក់ ដែលគេបានប្រគល់ដើម្បីឱ្យធ្វើកិច្ចការអ្វីមួយមកធ្វើជារបស់ខ្លួន ។ ដូចគ្នាដែរ ចំពោះគណនេយ្យករដែលគ្រប់គ្រងប្រាក់សំរាប់បំរើការរបស់ក្រុមហ៊ុន តែបានដកយកប្រាក់នោះទៅចាយជាប្រយោជន៍ខ្លួនឯង ។ ទំនិញមួយចំនួនត្រូវបានកែបន្លំដែរ កាលណាក្រុមហ៊ុនដឹកជញ្ជូនបានដកយកពីកុងទើន័រ នូវរបស់ដែលគេជួលឱ្យដឹក ។

## ង. ទំនាក់ទំនងកិច្ចសន្យារវាងម្ចាស់វត្ថុ និងអ្នកទទួល

មាត្រា ៤៦ នៃបទរំលោភលើសេចក្តីទុកចិត្ត គ្របដណ្តប់តែលើប្រភេទនៃកិច្ចសន្យាមួយចំនួនប៉ុណ្ណោះ គឺកិច្ចសន្យាជួល កិច្ចសន្យាដំកល់ទុក អាណត្តិ កិច្ចសន្យាឱ្យខ្ចីប្រើ និងកិច្ចសន្យាការងារ ។ មុននឹងពិចារណាទៅដល់ចំណុច ថាតើមានការកែបន្លំ ឬគ្មាននោះ គេត្រូវកំណត់ថាតើមានទំនាក់ទំនងកិច្ចសន្យារវាងម្ចាស់វត្ថុ និងអ្នកទទួលដែរឬទេ ព្រោះបទរំលោភលើសេចក្តីទុកចិត្តកើតចេញពីការល្មើសលើខនៃកិច្ចសន្យាដែលបានរៀបរាប់ខាងដើមនេះ ។ មានសំណួរចោទសួរថា បើកិច្ចសន្យានោះគ្មានសុពលភាព តើតុលាការនៅតែអាចបន្តរឿងក្តីអាជ្ញានៃបទរំលោភលើសេចក្តីទុកចិត្តបានឬយ៉ាងណា ។ តាមករណីយុត្តិសាស្ត្របារាំង អសុពលភាពនៃកិច្ចសន្យា មិនអាចជាយកមកធ្វើជាមូលដ្ឋានសំរាប់រារាំងមិនឱ្យដំណើរការនៃបណ្តឹងអាជ្ញានៃបទរំលោភលើសេចក្តីទុកចិត្តទេ ។ ឧទាហរណ៍ បើមានកិច្ចសន្យារវាងភាគីម្ខាងដែល ជាអនីតិជនដើម្បីផ្ញើទុករបស់ រួចហើយភាគីម្ខាងទៀតដែលជានីតិជនបានកែបំបាត់របស់ផ្ញើនោះទៅ ភាគីនីតិជននោះមិនអាចលើកហេតុផលថា ដោយសារកិច្ចសន្យានេះគ្មានសុពលភាព ព្រោះធ្វើឡើងជាមួយភាគីមិនគ្រប់អាយុ ដូច្នេះគេគ្មានទំនាក់ទំនងកិច្ចសន្យារវាងគ្នានិងគ្នាបានទេ ។ ដំណើរការបណ្តឹងអាជ្ញានៅតែប្រព្រឹត្តដដែល ទោះបីកិច្ចសន្យានេះមានឬគ្មានសុពលភាពក្តី ។ ការសំខាន់គឺថា តើខនៃកិច្ចសន្យាមានបញ្ជាក់ជាពិសេសអំពីការប្រគល់វត្ថុ ហើយតើត្រូវចាត់ចែងវត្ថុនោះតាមរបៀបណានិងត្រូវប្រគល់ត្រឡប់វិញនៅពេលណា ។ ខទាំងនេះដែលបង្កើត កាតព្វកិច្ចរបស់អ្នកទទួលចំពោះម្ចាស់ ។ម្យ៉ាងវិញទៀត គេមិនអាចលើកពីអនីត្យានុកូលភាព (ភាពមិនស្របច្បាប់) នៃកិច្ចសន្យាដើម្បីបដិសេធទំនាក់ទំនងកិច្ចសន្យាបានទេ ឱ្យតែការទទួលខុសត្រូវរបស់ចុងចោទ ចំពោះម្ចាស់វត្ថុមិនមែនកើតមកពីការល្មើសលើកិច្ចសន្យា ប៉ុន្តែកើតមកការប្រព្រឹត្តបទល្មើស (រំលោភលើសេចក្តីទុកចិត្ត) ដែលមានធាតុផ្សំគ្រប់គ្រាន់សំរាប់ដាក់បន្ទុកលើចុងចោទ ។

ឧបសម្ព័ន្ធ ៦

ការពិភាក្សាលើ
វិស័យឯកជន
លេខ ២៣

### ង១. កិច្ចសន្យាជួល (Louage)

ក្រិត្យ-ច្បាប់លេខ៣៨ស្តីពី កិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យាក្នុងមាត្រា ១០០ ចែងថា "ការជួល គឺជាកិច្ចសន្យាដែល អ្នកជួលសន្យាថានឹងផ្តល់ទៅអោយអ្នកទទួលជួលនូវវត្ថុណាមួយដើម្បីប្រើប្រាស់ជាបណ្តោះអាសន្ន ដោយតម្រូវអោយគិតថ្លៃនៃការជួលវត្ថុនោះអោយអ្នកជួល "។ តាមនិយមន័យនៃកិច្ចសន្យាប្រភេទនេះ អ្នកជួល (lender) នៅរក្សាសិទ្ធិលើវត្ថុរបស់ខ្លួនដដែល ហើយអ្នកទទួលជួល (borrower) មានតែសិទ្ធិប្រើប្រាស់តែប៉ុណ្ណោះ។ គ្មានការផ្ទេរកម្មសិទ្ធិ ពីអ្នកជួល ទៅអ្នកទទួលជួលទេ។ រយៈពេលដែលត្រូវប្រគល់វត្ថុទៅឱ្យអ្នកជួលវិញ គឺអាស្រ័យទៅតាមខចែងក្នុងកិច្ចសន្យា ប៉ុន្តែ បើគ្មានការកំណត់ទេនោះ ច្បាប់សន្មត់ថាមានត្រឹមតែមួយឆ្នាំយ៉ាងយូរ (មាត្រា ១០១)។ វត្ថុដែលអាចជួលបានអាចជាចលន ឬអចលវត្ថុ។

### ង.២ កិច្ចសន្យាដាក់ដំកល់ទុក (Dépôt)

នៅក្នុងច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា គេហៅថា "កិច្ចសន្យានៃការផ្ញើទុក" (ក្នុងផ្នែកទី៦) ។មាត្រា៨៩ឱ្យនិយមន័យដូច្នេះថា: "កិច្ចសន្យានៃការផ្ញើទុក ជាកិច្ចសន្យាដែលជនម្នាក់ផ្ញើចលនវត្ថុណាមួយ នឹងជនណាមួយទៀតអោយរក្សាទុក ដោយឥតយកឈ្នួល ឬយកឈ្នួល ហើយអោយប្រគល់វត្ថុនោះទៅជនដែលយកមកផ្ញើនោះវិញ ឬប្រគល់អោយជនណាដែលអ្នកផ្ញើប្រាប់ឈ្មោះមកយ៉ាងច្បាស់តាមពេលសន្មត់ ឬនៅពេលដែលទារយកវត្ថុនោះវិញ។" អ្នកទទួលតំកល់ទុកគ្មានសិទ្ធិប្រើប្រាស់ ឬចាត់ចែងរបស់ដែលដំកល់ទុកទេ គឺគ្រាន់តែរក្សាទុកឱ្យម្ចាស់របស់ប៉ុណ្ណោះ។ ឧទាហរណ៍នៃកិច្ចសន្យា ប្រភេទនេះមានដូចជា ការផ្ញើរថយន្តនៅផ្សារ ឬនៅសាលារៀន ការផ្ញើគ្រឿងអលង្កានៅធនាគារ ការផ្ញើទំនិញនៅក្នុងផ្សារ ។ល។

### ង.៣ អាណត្តិ (Mandat)

អាណត្តិមានពីយ៉ាងគឺ អាណត្តិមួយត្រូវបានបង្កើតឡើងដោយកិច្ចសន្យា។ អាណត្តិម្យ៉ាងទៀតត្រូវបានបង្កើតឡើងដោយអំណាចច្បាប់ ឬដោយអំណាចតុលាការ។

ច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា មិនបានរាប់បញ្ចូលកិច្ចសន្យាអាណត្តិទេ។ ប៉ុន្តែនៅក្នុងសេចក្តីព្រាងក្រមរដ្ឋប្បវេណី មានបញ្ចូលកិច្ចសន្យាអាណត្តិ។ មាត្រា ៦៣៤ នៃសេចក្តីព្រាងនេះ ឱ្យនិយមន័យថា "អាណត្តិ សំដៅទៅលើកិច្ចសន្យាណាមួយដែលភាគីម្ខាង ហៅថាអាណត្តិទាយក ប្រគល់សិទ្ធិអំណាចឱ្យភាគីម្ខាងទៀត ហៅថាអាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក"។

តាមមាត្រាខាងលើនេះ ភ្នាក់ងារលក់ឥវ៉ាន់ឱ្យក្រុមហ៊ុនមួយ គឺជាអាណត្តិគាហក។ អ្នកត្រួតការនៅក្នុងការដ្ឋានសាងសង់មួយដែលមើលការខុសត្រូវជួសមុខឱ្យក្រុមហ៊ុន គឺជាអាណត្តិគាហកដែរ។ អាណត្តិគាហក អាចធ្វើការយកកំរៃ ឬមិនយកកំរៃ អាស្រ័យលើការព្រមព្រៀងគ្នាជាមួយអាណត្តិទាយក។ មាត្រា ៦៣៧ នៃសេចក្តីព្រាងនេះបំពាក់ "ករណីយកិច្ចចាត់ចែងការអាណត្តិ ដោយប្រុងប្រយ័ត្ន

ក្នុងនាមជាអ្នកគ្រប់គ្រងសុចរិតដោយផ្អែកតាមអត្ថន័យនៃអាណត្តិ"។ការរំលោភលើករណីយកិច្ចសុចរិតនេះ ដោយគែបន្លំឧបករណ៍ធ្វើការ ឬមូលនិធិសំរាប់ដំណើរបំពេញអាណត្តិ នឹងនាំឱ្យកើតមានបទរំលោភលើសេចក្តីទុកចិត្ត។

អាណត្តិម្យ៉ាងទៀតកើតឡើងដោយអំណាចតុលាការ ឬច្បាប់។ អាណត្តិដែលកើតឡើងដោយអំណាចតុលាការមានដូចជា អ្នកអនុវត្តសាលក្រម។ អ្នកអនុវត្តសាលក្រម ដែលគែបន្លំទ្រព្យសម្បត្តិដែលត្រូវរឹបអូសជាគុណប្រយោជន៍ដល់ម្ចាស់បំណុល គឺជាឧទាហរណ៍មួយនៃអាណត្តិដែលបង្កើតឡើងដោយអំណាចតុលាការ ព្រោះតុលាការជាអ្នកចាត់តាំងឱ្យចាត់ចែងកិច្ចការអនុវត្តសាលក្រមតុលាការ។

### ង.៤ កិច្ចសន្យាឱ្យខ្ចីប្រើ (Prêt á usage)

កិច្ចសន្យាប្រភេទនេះត្រូវបានឱ្យនិយមន័យក្នុងច្បាប់កិច្ចសន្យាខ្មែរបច្ចុប្បន្នក្នុងមាត្រា ៩៤ ថា "ការអោយខ្ចីប្រើគឺគ្មានយកការប្រាក់ ឬយកឈ្នួលអ្វីទេ។ អ្នកដែលអោយវត្ថុណាមួយទៅអោយគេខ្ចីប្រើនៅតែជាកម្មសិទ្ធិករនៃវត្ថុនោះដដែល។" មាត្រា ៩៦ តម្រូវឱ្យអ្នកខ្ចីមានករណីយកិច្ចថែទាំវត្ថុនោះដូចជាម្ចាស់នៃវត្ថុនោះដែរ។ ពេលវេលាត្រូវសង លើកលែងតែបានកំណត់គ្នា អ្នកឱ្យខ្ចីអាចទារយករបស់វិញនៅពេលណាក៏បាន។ ដូច្នេះ អ្នកខ្ចីត្រូវត្រៀមជានិច្ចដើម្បីប្រគល់របស់ទៅឱ្យម្ចាស់វិញ។ កិច្ចសន្យានេះខុសពីកិច្ចសន្យា ដំកល់ទុកត្រង់អ្នកខ្ចីអាចប្រើប្រាស់វត្ថុនោះស្របតាមការព្រមព្រៀងគ្នាជាមួយម្ចាស់។

### ង.៥ កិច្ចសន្យាការងារមានបៀវត្ស ឬគ្មានបៀវត្ស

កិច្ចសន្យានេះ អាចរួមបញ្ចូលកិច្ចសន្យាការងារស្របតាមច្បាប់ការងារ និងកិច្ចសន្យាសហគ្រាសក្នុងច្បាប់កិច្ចសន្យាបច្ចុប្បន្ន។ កិច្ចសន្យានៅក្នុងច្បាប់ការងារ សំដៅដល់ទំនាក់ទំនងផ្នែកការងាររវាងកម្មករ និយោជិតនិងនិយោជក។ ក៏ប៉ុន្តែ កិច្ចសន្យាសហគ្រាស អនុវត្តលើការងារដែលមនុស្សម្នាក់បំពេញឱ្យមនុស្ស ម្នាក់ទៀត (មាត្រា ៧២)។ ប៉ុន្តែកិច្ចសន្យាទាំងពីរយ៉ាងដែលពោលមកនេះសុទ្ធតែពាក់ព័ន្ធនឹងការឱ្យថ្លៃឈ្នួល។ ការងារដែលចែងនៅក្នុងមាត្រា ៤៦ នៃបទរំលោភលើសេចក្តីទុកចិត្តរាប់បញ្ចូលការងារដែលមិនយកថ្លៃឈ្នួលផងដែរ។ ជនជាប់ចោទ មិនអាចយកប្រការដែលខ្លួនធ្វើការមិនយកថ្លៃឈ្នួល មកធ្វើការដោះសាឱ្យរួចពីការទទួលខុសត្រូវពីការចោទប្រកាន់ពីបទរំលោភលើទំនុកចិត្តទេ ប្រសិនជាខ្លួនពិតជាបានគែបន្លំវត្ថុដែលគេប្រគល់មកខ្លួនដើម្បីបំពេញការងារ។ ឧទាហរណ៍ នៃកិច្ចសន្យាប្រភេទនេះមានដូចជា ការប្រគល់មាសឱ្យជាងមាសធ្វើគ្រឿងអលង្កា និយោជិតនៃក្រុមហ៊ុនមួយទទួលបន្ទុកថែរក្សាឃ្លាំងទំនិញ ការទុករថយន្តឱ្យរោងជាងជួសជុល។

## ច. ការអនុវត្តច្បាប់ស្តីពីការរំលោភលើសេចក្តីទុកចិត្ត នៅលើរឿងក្តីខ្លះដែលកំពុងកើតមាន នៅក្នុងប្រព័ន្ធតុលាការខ្មែរយើង

### ច.១ ការខកខានសងបំណុលតាមកិច្ចសន្យា

ការខកខានសងបំណុលតែងតែកើតមាននៅគ្រប់ប្រទេស គ្រប់ទីកន្លែង។ កិច្ចសន្យាឱ្យខ្ចីប្រាក់បំណុល គឺជាកិច្ចសន្យាមួយដែលផ្ទេរកម្មសិទ្ធិពីម្ចាស់ប្រាក់ទៅអ្នកខ្ចី។ កូនបំណុលមានសិទ្ធិលើរូបវត្ថុដែលជាសាច់ប្រាក់ ចំណែកឯម្ចាស់បំណុលវិញមានសិទ្ធិលើរូបកូនបំណុល តែគ្មានសិទ្ធិលើសាច់ប្រាក់ទេ។ ឧទាហរណ៏ ម្ចាស់បំណុល ម្នាក់ឱ្យកូនបំណុលម្នាក់ខ្ចីប្រាក់ចំនួន ៥ លានរៀលដើម្បីទៅប្រកបរបររបស់ខ្លួន។ នៅពេលដែលប្រាក់ត្រូវបាន ផ្ទេរទៅឱ្យកូនបំណុលហើយ កូនបំណុលជាម្ចាស់លើទឹកប្រាក់នោះ។ កូនបំណុលមានសិទ្ធិពេញលេញលើប្រាក់នោះ ដោយគាត់អាចចាត់ចែងអ្វីក៏បានដូចជាទិញឧបករណ៏សំរាប់ ប្រកបអាជីវកម្មរបស់គាត់ជាដើម។ ម្ចាស់ បំណុលគ្មានសិទ្ធិលើសាច់ប្រាក់នោះទេ តែគាត់មានសិទ្ធិលើកូនបំណុលឱ្យបំពេញកាតព្វកិច្ចសងបំណុលឱ្យគាត់វិញ។ ដោយសារកូនបំណុលជាម្ចាស់លើទឹកប្រាក់កម្ចីនោះ គាត់មិនអាចត្រូវបានចោទប្រកាន់ពីបទរំលោភលើ សេចក្តីទុកចិត្តបានទេ បើកាលណាគាត់យកទៅចាយខ្ជះខ្ជាយ ឬរកស៊ីខាតបង់អស់។ ផ្ទុយទៅវិញ បើសិន ជាដល់ពេលត្រូវសង ហើយគាត់មិនមានប្រាក់សងបំណុល កូនបំណុលត្រូវបានចាត់ទុកថាបាន ល្មើសកិច្ចសន្យា កម្ចី ហើយការល្មើសលើកិច្ចសន្យានេះគឺជាបញ្ហារដ្ឋប្បវេណីសុទ្ធសាធ។

លើកលែងតែកាលៈទេសៈជុំវិញការចរចាកិច្ចសន្យាដែលបង្ហាញឱ្យឃើញថា កូនបំណុលប្រើល្បិចកល បោកប្រាស់ដើម្បីឱ្យម្ចាស់បំណុលព្រមឱ្យប្រាក់ខ្ចី ទើបកូនបំណុលអាចត្រូវបានចោទប្រកាន់ពីបទមួយគឺការឆបោក តែមិនមែនបទរំលោភលើសេចក្តីទុកចិត្តទេ។ ប៉ុន្តែការនេះគេត្រូវសិក្សាឱ្យល្អិតល្អន់ថែមទៀតពី ធាតុផ្សំនៃបទល្មើសឆបោក។ ចំណែកឯនៅក្នុងការល្មើសធម្មតាលើកិច្ចសន្យា ម្ចាស់បំណុលអាចស្វែងរកឧបាស្រ័យ (ការទាមទារឱ្យជួសជុលឡើងវិញនូវអ្វីដែលខាតបង់) តាមនីតិវិធីរដ្ឋប្បវេណី។ជាធម្មតាម្ចាស់បំណុលដែលបានខាតបង់ប្រាក់តែងតែចង់រកមធ្យោបាយណាគ្រប់បែបយ៉ាងដើម្បីឱ្យកូនបំណុលសងប្រាក់មកខ្លួនវិញ រួមទាំងការសុំឱ្យប៉ូលីសចាប់កូនបំណុលឃុំដើម្បីគំរាមឱ្យសង ឬការប្តឹងទៅតុលាការឱ្យចោទប្រកាន់ពី បទរំលោភលើសេចក្តីទុកចិត្ត។ប៉ុន្តែ បើរឿងនេះជារឿងកិច្ចសន្យាធម្មតា ម្ចាស់បំណុលនិងប៉ូលីសអាចនឹងត្រូវ បានចោទប្រកាន់ពីបទព្រហ្មទណ្ឌឃុំឃាំងមនុស្សដោយខុសច្បាប់។ ចំណែកឯចៅក្រមឬព្រះរាជអាជ្ញាអាចត្រូវ បានជនរងគ្រោះប្តឹងទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមឱ្យពិនិត្យលើភាពប្រទ្បាក់ប្រឡូសរបស់ចៅក្រម ឬ ព្រះរាជអាជ្ញា បើចៅក្រម/ព្រះរាជអាជ្ញាចូលរួមក្នុងការឃុំខ្លួនដោយគ្មានហេតុផលផ្លូវច្បាប់នេះ។

ការខកខានមិនបានសងបំណុលតាមពេលសន្យា អាចកើតចេញពីធនក្ស័យ ការខាតបង់ដោយសារ គ្រោះអន្តរាយផ្សេងៗ ដោយសារការធ្វើផែនការអាជីវកម្មមិនបានល្អិតល្អន់ ឬក៏ដោយសារកូនបំណុលរបស់ កូនបំណុលមិនបានសងបំណុលមកខ្លួនឱ្យទាន់ពេលដែរ។ ដើម្បីចៀសវាងការមិនសងបំណុល ម្ចាស់បំណុល មុននឹងឱ្យកូនបំណុលខ្ចី ត្រូវធ្វើការវាយតម្លៃជំហរឥណទានរបស់កូនបំណុល

(សមត្ថភាពរបស់កូនបំណុល ដើម្បីសងបំណុលវិញ) ។ នៅក្នុងប្រទេសដែលអនុវត្តសេដ្ឋកិច្ចទីផ្សារ ច្បាប់ការពារសេរីភាពក្នុងការធ្វើកិច្ចសន្យា ដើម្បីធ្វើឱ្យចរន្តសេដ្ឋកិច្ចហូរទៅដោយគ្មានឧបសគ្គ។ បើរដ្ឋចូលជ្រៀតជ្រែកនៅក្នុងសេរីភាពនៃកិច្ចសន្យា ដូចជាការអនុវត្តដោយបំពាននូវច្បាប់ស្តីពីការរំលោភលើសេចក្តីទុកចិត្តដោយដាក់គុកដល់កូន បំណុលខកខានកាតព្វកិច្ច នោះនឹងបង្កើតឱ្យមានភាពមិនទៀង (uncertainty) និងភាពមិនអាចប្រមាណ បាន (predictability) នៅក្នុងអំពើចុះកិច្ចសន្យា ព្រោះគេស្ទាក់ស្ទើរក្នុងខ្ចីបុលព្រោះការមិនបានបំពេញកាតព្វកិច្ច នៃកិច្ចសន្យានាំនឹងនាំឱ្យមានផលវិបាកខាងផ្នែកព្រហ្មទណ្ឌ ដែលមនុស្សគ្រប់រូបតែងតែខ្លាចរអាព្រោះវាទាក់ ទងនឹងការបាត់បង់សេរីភាពដោយសារទណ្ឌកម្មព្រហ្មទណ្ឌ។ ច្បាប់ស្តីពីបទល្មើសលើសេចក្តីទុកចិត្ត មានគោល បំណងការពារទ្រព្យសម្បត្តិរបស់ម្ចាស់ពីចេតនាគៃបន្លំ មិនមែនដើម្បីបង្អាក់សេរីភាពនៃ ការធ្វើកិច្ចសន្យាជា ធម្មតានោះទេ។ ភាគីដែលចុះកិច្ចសន្យាដោយស្ម័គ្រចិត្តបានទទួលយកហានិភ័យ (risk) ដែលជារឿងធម្មតា នៃដំណើរការអាជីវកម្មទូទៅ។

## ច.២ ការចរចាកិច្ចសន្យាមិនបានសំរេច

មុននឹងបានដល់ការចុះហត្ថលេខាលើកិច្ចសន្យាមួយ ភាគីតែងតែបានចរចាគ្នាពីលក្ខខ័ណ្ឌនិងប្រការផ្សេងៗដែលត្រូវបញ្ចូលក្នុងកិច្ចសន្យា។ ប៉ុន្តែរាល់ការចរចា មិនមែនសុទ្ធតែបានសំរេចទាំងអស់ទេ។ នៅចំណុចណាមួយ ភាគីម្ខាង ឬភាគីទាំងពីរអាចបោះបង់បំណងចុះកិច្ចសន្យាជាមួយគ្នាដោយសារលក្ខខ័ណ្ឌនិងប្រការ ផ្សេងៗដែលស្នើឡើងមិនបានយល់ព្រមនឹងគ្នា។ ដូច្នេះ មិនមានកិច្ចសន្យាណាមួយត្រូវបានបង្កើតឡើងទេ។ ភាគីណាមួយអាចមានការ"ខកចិត្ត"ពីដំណើរការចរចា ដោយសារតែកិច្ចសន្យាដែលគេចង់បាននោះមិនអាច កើតឡើងបាន។ ប៉ុន្តែ ក្នុងភាសាមញ្ញក្តី ក្នុងភាសាច្បាប់ក្តី ការ "ខកចិត្ត" និង "ការរំលោភលើសេចក្តីទុកចិត្ត" មានន័យមិនដូចគ្នាទេ។ ការខកចិត្តគឺអ្វីដែលមិនដល់ការរំពឹងទុករបស់យើង។ចំណែកឯ"ការរំលោភលើ សេចក្តីទុកចិត្ត"គឺអ្វីដែលមនុស្សម្នាក់បានបន្ទាក់បន្ទុករបស់អ្វីមួយឱ្យមនុស្សម្នាក់ទៀត តែមនុស្សម្នាក់នេះបាន យករបស់នោះ ទៅធ្វើអ្វីមួយ ខុសពីបំណងដើមរបស់អ្នកទីមួយធ្វើឱ្យអ្នកទីមួយនេះទទួលរងការខូចខាតពីទង្វើ របស់អ្នកទីពីរ។ បើការចរចាណាមួយអាចនាំផលអាក្រក់ដល់ខ្លួន ដោយសារការចរចានោះអាចមិនបានសំរេច គ្មានមនុស្សណាម្នាក់នឹងហ៊ានចូលក្នុងការចរចានោះទេ។ ដូច្នេះដំណើរការអាជីវកម្មផងទាំងពួងនឹងមិនអាចប្រព្រឹត្តទៅកើតទេ ដោយសារការចោទប្រកាន់ពីបទរំលោភលើសេចក្តីទុកចិត្តនឹងបង្កើតឱ្យមាន "ហានិភ័យ ខ្ពស់ដល់ដៃគូចរចា។ គោលការណ៍នៃសេដ្ឋកិច្ចទីផ្សារសេរីដែលរដ្ឋធម្មនុញ្ញខ្មែរយើងបានលើកតំកើងនោះ ជំរុញឱ្យមានសេរីភាពក្នុងការធ្វើកិច្ចសន្យា ដោយមិនមានការភ័យខ្លាចការគំរាមកំហែងដោយថាហេតុណាមួយ។

## ច.៣ ការជួលទីកន្លែងមួយ

ការជួលទីកន្លែង ដូចជាទីកន្លែងសំរាប់ប្រកបអាជីវកម្មគឺជាកិច្ចសន្យាដែលភាគីម្ចាស់កន្លែងសុខចិត្ត ជួលទីកន្លែងរបស់ខ្លួនឱ្យភាគីម្ខាងទៀតយកទៅប្រើការជាថ្នូរនឹងថ្លៃឈ្នួល។ នៅប្រទេសខ្មែរ គេច្រើនធ្វើ កិច្ចសន្យាដោយកំណត់រយៈពេលនៃការជួល ព្រមទាំងការបង់ប្រាក់ដិកល់ជាមុនខ្លះដើម្បី

ធានាថាបើអ្នកសុំជួល ទីកន្លែងឈប់ជួលមុនរយៈពេលដែលកំណត់ជាមុន ម្ចាស់ទីកន្លែងនឹងរឹបអូសយកប្រាក់ដិកល់នោះ។ កិច្ចសន្យា ជួលនេះគឺខុសពីកិច្ចសន្យាជួលដែលបានពោលនៅក្នុងផ្នែក ង១ ខាងលើ។ កិច្ចសន្យាជួលក្នុងផ្នែក ង១ នេះ គឺ ភាគីម្នាក់ជួលរបស់អ្វីមួយដូចជារថយន្តជាដើម ហើយភាគីម្ខាងទៀតបន្ទំយករថយន្តនោះទៅបាត់ ដែលជា ហេតុធ្វើឱ្យខាតបង់ដល់ម្ចាស់រថយន្ត។ ចំណែកក្នុងឧទាហរណ៍នៃការជួលទីកន្លែងនៅទីនេះ គឺអ្នកសុំជួលគ្មាន ធ្វើអ្វីឱ្យខូចខាតដល់ម្ចាស់ទីកន្លែងទេ ដោយគ្រាន់តែល្មើសកិច្ចសន្យាឈប់ជួលមុនដល់កាលកំណត់។ ថ្វីបើ អ្នកសុំជួលធ្វើឱ្យម្ចាស់ទីកន្លែង "ខកចិត្ត" ឬ "ឈឺចិត្ត" ដោយសារគាត់មិនអាចរកអ្នកណាមកជួលជំនួស ដែលជាហេតុធ្វើឱ្យ គាត់ខាតបង់ប្រាក់ថ្លៃឈ្នួលដែលគាត់រំពឹងទុកចាប់ពីពេលអ្នកសុំជួលឈប់ជួល រហូតដល់អ្នកសុំជួលថ្មីចូលមកជួលជំនួសនោះ គេមិនអាចចោទអ្នកសុំជួលថាបានប្រព្រឹត្តបទរំលោភលើសេចក្តីទុកចិត្ត របស់ម្ចាស់ទីកន្លែងបានទេ ព្រោះថាម្ចាស់ទីកន្លែងនៅតែមានសិទ្ធិនិងអំណាចលើទីកន្លែងរបស់ខ្លួនដដែលគ្មាន បាត់បង់ទៅណា។ អ្នកសុំជួលអាចរំលោភលើខចែងនៃកិច្ចសន្យា តែការរំលោភបែបនេះគឺជាជម្លោះកិច្ចសន្យា សុទ្ធសាធដែលគេត្រូវដោះស្រាយដោយសំណងនៃការខូចខាតដែលកើតចេញពីការរំលោភនេះ ប៉ុន្តែអ្នកសុំជួលមិនអាចមានទោសពីបទរំលោភលើសេចក្តីទុកចិត្តទេ។

ជួនកាលទៀត បើអ្នកសុំជួលធ្វើឱ្យខូចខាតរបស់របរខ្លះនៅក្នុងទីកន្លែងនោះ នេះក៏មិនមែនជាការធ្វើឱ្យខូចខាត ក្នុងន័យនៃព្យសនកម្មដែលជាធាតុផ្សំមួយក្នុងបណ្តាធាតុផ្សំដទៃទៀត នៃបទរំលោភលើសេចក្តីទុកចិត្តដែរ។ ការធ្វើឱ្យខូចខាតបែបនេះ គឺជាការទទួលខុសត្រូវក្រៅកិច្ចសន្យា (non-contractual or tortious liability) ដែលត្រូវទូទាត់ជា មួយម្ចាស់ទីកន្លែងដោយសំណងរដ្ឋប្បវេណី។

## ឆ. សេចក្តីសន្និដ្ឋាន

ការអនុវត្តច្បាប់ដោយមិនត្រឹមត្រូវ មិនគ្រាន់តែធ្វើឱ្យខូចខាតដល់សិទ្ធិនិង សេរីភាពរបស់ពលរដ្ឋ ប៉ុណ្ណោះទេ តែអាចធ្វើឱ្យអន្តរាយដល់សេដ្ឋកិច្ចជាតិទៀតផង ដោយសារតែមនុស្សគ្មានទំនុកចិត្តដល់ប្រព័ន្ធ ច្បាប់មួយដែលអាចការពារខ្លួនរបស់គេ។ ច្បាប់ស្តីពីបទរំលោភលើសេចក្តីទុកចិត្តការពារទ្រព្យសម្បត្តិដែល ត្រូវបានមនុស្សក្បត់កេងប្រវ័ញ្ចយកទៅ។ លក្ខណៈពិសេសនៃច្បាប់នេះគឺថា (១) ម្ចាស់ទ្រព្យបានបន្ទុកបន្ទាក់ ទ្រព្យរបស់ខ្លួនជាមួយមនុស្សម្នាក់ (២) តាមខចែងដែលមានក្នុងកិច្ចសន្យាណាមួយក្នុងបណ្តាកិច្ចសន្យា ៥ យ៉ាងខាងលើ (៣) ដោយម្ចាស់នៅតែរក្សាសិទ្ធិកម្មសិទ្ធិលើទ្រព្យនោះដដែល គឺគ្មានការផ្ទេរកម្មសិទ្ធិណាមួយ ពីម្ចាស់ទៅឱ្យអ្នកទទួលទ្រព្យនោះទេ ហើយក្រោយពីបានសិទ្ធិត្រួតត្រាលើទ្រព្យនោះមក (៤) អ្នកទទួលទ្រព្យ ក៏អនុវត្តចេតនាអាក្រក់កេងប្រវ័ញ្ច ឬចាត់ចែងទ្រព្យនោះផ្ទុយពីខចែងឬការព្រមព្រៀងគ្នានៅក្នុងកិច្ច សន្យា (៥) ដែលជាហេតុធ្វើឱ្យមានការខូចខាតដល់ម្ចាស់។ ម្យ៉ាងវិញទៀតការរំលោភលើកិច្ចសន្យាមិនមែន សុទ្ធតែជាការ "រំលោភលើសេចក្តីទុកចិត្ត" ទេ។ គេត្រូវពិនិត្យដោយល្អិតល្អន់អំពីធាតុផ្សំនៃបទល្មើសនេះ។

# ឧបសម្ព័ន្ធ ៦

# ការវិភាគព័ត៌មាន ដែលទទួលបានមកពីក្រសួងយុត្តិធម៌

ការវិភាគព័ត៌មានដែលទទួលបានមកពីក្រសួងយុត្តិធម៌

**តារាងទី១: ចំនួនរឿងក្តីពីបទរំលោភលើសេចក្តីទុកចិត្ត នៅក្នុងខេត្តចំនួនបី (ខេត្តបាត់ដំបង ក្រុងព្រះសីហនុ និងខេត្តកំពង់ចាម) និងនៅក្នុងទីក្រុងភ្នំពេញ គិតពីឆ្នាំ ២០០២ ដល់ ២០០៥**

| ខេត្ត/ក្រុង | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | សរុបតាមខេត្តនីមួយៗ | ភាគរយនៃចំនួនសរុប |
|---|---|---|---|---|---|---|
| ភ្នំពេញ[១០] | មិនដឹង | មិនដឹង | មិនដឹង | មិនដឹង | ៨៦១ | ៧១.៦% |
| បាត់ដំបង | ៤៩ | ៦៥ | ៤៩ | ៤២ | ២០៥ | ១៧.១% |
| ក្រុងព្រះសីហនុ | ២៧ | ២១ | ២៩ | ២២ | ៩៩ | ៨.២% |
| កំពង់ចាម | ៣ | ៤ | ១៣ | ១៧ | ៣៧ | ៣.១% |
| សរុបចំនួនរឿងក្តីរំលោភលើសេចក្តីទុកចិត្ត | | | | | ១ ២០២ | |

*ប្រភពព័ត៌មាន: ដកស្រង់ចេញពីឯកសារដែលបានចងក្រងដោយ អយ្យការអមតុលាការខេត្ត-ក្រុងនីមួយៗ ហើយដែលបានផ្តល់អោយ ដោយក្រសួងយុត្តិធម៌ នៅឆ្នាំ ២០០៦។*

១០ ក្រុងភ្នំពេញរាយការណ៍តែព័ត៌មានសរុប ពីឆ្នាំ ២០០២ ដល់ឆ្នាំ ២០០៥ និងព័ត៌មានសរុបពី ឆ្នាំ ២០០០ ដល់ឆ្នាំ ២០០៥។ តារាងទី ១ ប្រើព័ត៌មានសរុប ពីឆ្នាំ ២០០២ ដល់ឆ្នាំ ២០០៥ ឯចំណែកតារាងទី ២ ប្រើព័ត៌មានសរុប ពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០០៥។ យើងសម្រេច ចិត្តធ្វើដូចនេះ ដោយផ្អែកលើព័ត៌មានដែលបានមកពីតាមខេត្តនានា ដែលរាយការណ៍ក្នុងបែបបទផ្សេងៗពីគ្នា។

ឧបសម្ព័ន្ធ ៦

### តារាងទី២: ការប្រៀបធៀបរឿងក្ដីរំលោភលើសេចក្ដីទុកចិត្ត ទៅនឹងបទឧក្រិដ្ឋមួយចំនួន នៅក្នុងទីក្រុងភ្នំពេញ គិតពីឆ្នាំ ២០០០ ដល ២០០៥

| បទឧក្រិដ្ឋ | ចំនួនរឿងក្ដី | សរុបជាភាគរយ |
| --- | --- | --- |
| បទរំលោភលើសេចក្ដីទុកចិត្ត | ១ ១៣៦ | ៨,២% |
| អំពើឆបោក | ១ ១៦៧ | ៨,៥% |
| ចោរកម្ម | ២ ១៥៩ | ១៥,៧% |
| អំពើប្លន់ | ១ ៦៦៣ | ១២,១% |
| បង្ករបួសស្នាមដោយចេតនា | ២ ៥៦៦ | ១៨,៦% |
| សរុបចំនួនរឿងក្ដី[១១] | ១៣ ៧៧០ | |

*ប្រភពព័ត៌មាន: ដកស្រង់ចេញពីឯកសារដែលបានចងក្រងដោយអយ្យការអមតុលាការខេត្ត-ក្រុងនីមួយៗ ហើយដែលបានផ្ដល់អោយ ដោយក្រសួងយុត្តិធម៌នៅឆ្នាំ ២០០៦ ។*

### តារាងទី៣: ការប្រៀបធៀបចំនួនរឿងក្ដីរំលោភលើសេចក្ដីទុកចិត្ត គិតជាភាគរយនៃរឿងក្ដីសរុបនៅក្នុងទីក្រុងភ្នំពេញ ខេត្តបាត់ដំបង និងខេត្តកំពង់ចាម, គិតពីឆ្នាំ ២០០០ ដល់ ២០០៥

| ខេត្ត/ក្រុង | រឿងក្ដីរំលោភលើសេចក្ដីទុកចិត្ត | ចំនួនរឿងក្ដីសរុប | រឿងក្ដីរំលោភលើសេចក្ដីទុកចិត្ត គិតជាភាគរយនៃចំនួនរឿងក្ដីសរុប |
| --- | --- | --- | --- |
| ភ្នំពេញ | ១ ១៣៦ | ១៣ ៧៧០ | ៨,២% |
| បាត់ដំបង | ២៥៩ | ៥ ០៥៩ | ៥,១% |
| កំពង់ចាម | ៥៨ | ៣ ៣៦៨ | ១,៧% |

*ប្រភពព័ត៌មាន: ដកស្រង់ចេញពីឯកសារដែលបានចងក្រងដោយអយ្យការអមតុលាការខេត្ត-ក្រុងនីមួយៗ ហើយដែលបានផ្ដល់អោយ ដោយក្រសួងយុត្តិធម៌នៅឆ្នាំ ២០០៦ ។*

---

[១១] តួលេខនេះតាងអោយតួលេខសរុបនៃបទល្មើសនៅទីក្រុងភ្នំពេញ គិតចាប់ពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០០៥ ដោយរួមទាំងបទល្មើសប្រភេទផ្សេងៗទៀត ដែលយើងមិនបានរាប់បញ្ចូល ក្នុងតារាងទី ២ ។

ឧបសម្ព័ន្ធ ៧

# សេចក្តីណែនាំរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល ស្តីអំពីបទព្រហ្មទណ្ឌនៃការរំលោភលើសេចក្តីទុកចិត្ត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការក្រសួងយុត្តិធម៌**

**លេខៈ** [illegible]

ភ្នំពេញ. ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

**សេចក្តីណែនាំរួម**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង ប្រធានតុលាការកំពូល**

**សូមជំរាបមក**

- **លោកប្រធាន អនុប្រធាន និងចៅក្រមគ្រប់តុលាការខេត្ត-ក្រុង**
- **លោកព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង អមតុលាការខេត្ត-ក្រុង**

**កម្មវត្ថុ** : សេចក្តីណែនាំអំពីការអនុវត្តមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

កន្លងមកក្រសួងយុត្តិធម៌ និងតុលាការកំពូលបានពិនិត្យឃើញថា ការអនុវត្តមាត្រា ៤៦ ស្តីពីអំពើរំលោភលើសេចក្តីទុកចិត្ត នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩២ មិនទាន់បានឯកភាពគ្នានៅឡើយ នៅតាមតុលាការទូទាំងប្រទេស ។ ម្យ៉ាងវិញទៀតចំពោះការបែងចែកវិវាទរដ្ឋប្បវេណី ដែលជាការមិនបំពេញករណីយកិច្ចកើតចេញពីកិច្ចសន្យា និងអំពើដែលរួមផ្សំជាបទល្មើសរំលោភលើសេចក្តីទុកចិត្ត កំពុងស្ថិតនៅជាបញ្ហាដែលទាមទារឱ្យមានការដោះស្រាយផងដែរ ។

ការរំលោភសេចក្តីទុកចិត្ត គឺជាអំពើកែបន្លំ ឬបំបាត់ រំលោភកាន់កាប់មួយចំណែក ឬទាំងអស់នូវទ្រព្យសម្បត្តិអ្នកដទៃ ដែលគេបានប្រគល់អោយខ្លួនអាស្រ័យដោយការជឿទុកចិត្តរបស់ម្ចាស់ទ្រព្យ ឬអ្នកកាន់កាប់ទ្រព្យដែលសង្ឃឹមថា ទទួលបានមកវិញនូវទ្រព្យសម្បត្តិ ឬលទ្ធផលនៃការងារណាមួយពីអ្នកទទួលនូវទ្រព្យទាំងនោះ ។

ដើម្បីជាមូលដ្ឋានសំរាប់ការចោទប្រកាន់ និងការវិនិច្ឆ័យរឿងក្តី និងការបែងចែករវាងវិវាទរដ្ឋប្បវេណី និងបទល្មើសរំលោភលើសេចក្តីទុកចិត្ត ក្រសួងយុត្តិធម៌ និងតុលាការកំពូល សូមធ្វើការណែនាំដល់តុលាការ និងអយ្យការខេត្ត-ក្រុង យកចិត្តទុកដាក់ ពិចារណាលើសញ្ញាណគតិយុត្ត ដែលបានបញ្ញត្តិក្នុងមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូចរៀបរាប់ខាងក្រោម ។

**ធាតុផ្សំនៃបទល្មើសរំលោភលើសេចក្តីទុកចិត្តមាន:**

១. មានច្បាប់ចែង ឧទាហរណ៍ មាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល



ផ្លូវសម្តេចសុធារស.ខ័ណ្ឌដូនពេញ.ក្រុងភ្នំពេញ ទូរស័ព្ទ : 023.212.693 . 211.038 . 215.349 . 215.364 ទូរសារ : 023.364.119

២. ជនល្មើសមានចេតនាទុច្ចរិត តែបន្លំ ឬបំបាត់ទ្រព្យដែលខ្លួនបានទទួល ពោលគឺការមិនបានប្រគល់ ឬបង្ហាញនូវទ្រព្យ ឬលទ្ធផលនៃការងារកើតឡើងដោយឆន្ទៈមិនប្រគល់ពិតប្រាកដ ដែលពុំមែនកើតឡើងដោយឧបសគ្គសត្យានុម័តនោះឡើយ ហើយត្រូវមានអំពើតែបន្លំ ឬបំបាត់ទ្រព្យសម្បត្តិប្រព្រឹត្តដោយអ្នកទទួលបាននូវទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យា ដែលស្តែងឡើងក្រោមរូបភាពជាការមិនប្រគល់ ឬប្រគល់ តែបានបន្លំបរិមាណ ឬគុណភាពនៃទ្រព្យសម្បត្តិទាំងនោះ ។

៣. សំភារៈ ឬមុខសញ្ញា នៃបទរំលោភលើសេចក្តីទុកចិត្តរួមមាន :

ទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញ គ្រប់ឯកសារដែលមាន ឬដែលចែងអំពីកាតព្វកិច្ច ឬការដោះបន្ទុកដែលគេប្រកាសអោយដកខ្លួន ក្នុងលក្ខណៈជាការជួល ការតំកល់ទុក ជាអាណត្តិ ជាការអោយខ្ចីប្រើ ឬដើម្បីការងារមានបៀវត្ស ឬគ្មានបៀវត្ស ដែលត្រូវប្រគល់អោយគេវិញ ឬធ្វើជាតំណាង ឬសំរាប់ប្រើប្រាស់ ឬជាមុខការមានកំណត់ ដែលម្ចាស់ទ្រព្យបានផ្ទុកផ្តាក់ទ្រព្យរបស់ខ្លួនអោយទៅភាគីម្ខាង ហើយភាគីម្ខាងបានទទួលទ្រព្យនេះដោយស្របច្បាប់ តាមរយៈកិច្ចសន្យាប្រាំមួយប្រភេទគឺៈ កិច្ចសន្យាជួល កិច្ចសន្យាផ្ញើទុក កិច្ចសន្យាបញ្ចាំ កិច្ចសន្យាអោយខ្ចីប្រើ កិច្ចសន្យាអាណត្តិ និងកិច្ចសន្យាការងាររវាងកម្មករ និងនិយោជិត ឬមិនមែនរវាងនិយោជក និងកម្មករ, និយោជិត ។

៤. មានការអន្តរាយ ពោលគឺខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬ អ្នកកាន់កាប់ដែលបានប្រគល់នូវទ្រព្យទាំងនោះ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូល សូមរំលឹក និងសូមឱ្យលោកចៅក្រម ពិចារណាឱ្យបានល្អិតល្អន់ចំពោះការមិនបានបំពេញករណីយកិច្ច ដែលកើតចេញពីកិច្ចសន្យារដ្ឋប្បវេណីផ្សេងទៀត ក្រៅពីប្រភេទកិច្ចសន្យាទាំង ៦ ដែលបានលើកឡើងខាងលើ ដូចជាកិច្ចសន្យាលក់-ទិញ កិច្ចសន្យាខ្ចីបរិភោគ(ដូចជាកិច្ចសន្យាខ្ចីប្រាក់) កិច្ចសន្យាឱ្យ ឬប្រទានកម្ម ដែលភ្ជាប់ករណីយកិច្ច.........ទោះបីដោយមូលហេតុណាក៏ដោយ ដែលអ្នកទទួលបាននូវទ្រព្យ មិនបានបំពេញករណីយកិច្ចប្រគល់ឱ្យទៅអ្នកប្រគល់វិញ នូវទ្រព្យនោះមិនមែនជាអំពើតែបន្លំ ឬបំបាត់ ដែលរួមផ្សំជាបទល្មើសរំលោភលើសេចក្តីទុកចិត្តនោះឡើយ ។

ការធ្វើឱ្យខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិតាមរយៈអំពើណាមួយ ដែលមិនរួមផ្សំជាបទល្មើសរំលោភលើសេចក្តីទុកចិត្ត អាចជាបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ប្រសិនបើអំពើនោះត្រូវបានចែងក្នុងច្បាប់ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូល នឹងមានវិធានការតាមផ្លូវច្បាប់ចំពោះការមិនអនុវត្តឱ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូលសង្ឃឹមថា អស់លោកចៅក្រម នឹងយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការអនុវត្តឱ្យបានត្រឹមត្រូវនូវបញ្ញត្តិមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដើម្បីការពារសិទ្ធិរបស់ ពលរដ្ឋ ជួយរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងបង្កើនការជឿជាក់របស់ពលរដ្ឋ និងអ្នកវិនិយោគលើ ប្រព័ន្ធតុលាការ និងច្បាប់របស់កម្ពុជា ។

**ប្រធានតុលាការកំពូល**

ឌិត មុន្ទី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

អង្គ វង្សវឌ្ឍានា

<u>ចម្លងជូន</u> :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍ និង មហាអយ្យការ
- ឯកសារ-កាលប្បវត្តិ

International Finance Corporation
World Bank Group


**ការិយាល័យនៅហាណូយ**
63 Ly Thai To St., 3rd floor
Hanoi, Vietnam
Tel: (84 4) 824 7892
Fax: (84 4) 824 7898

**ការិយាល័យនៅទីក្រុងហូជីមិញ**
Somerset Chancellor Court
21-23 Nguyen Thi Minh Khai St. 3rd floor
Dist.1, Ho Chi Minh City, Vietnam
Tel: (84 8) 823 5266
Fax: (84 8) 823 5271

**ការិយាល័យនៅភ្នំពេញ**
70 Norodom Blvd., Sangkat Chey Chumnas
Phnom Penh, P.O Box 1115, Cambodia
Tel: (855 23) 210 922
Fax: (855 23) 215 157

**ការិយាល័យនៅវៀងច័ន្ទ**
90 Phonexay Rd, P.O Box 9690
Vientiane, Lao P.D.R.
Tel: (856 21) 450 017-9
Fax: (856 21) 450 020


សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) គឺជាផ្នែកឯកជន នៃក្រុមធនាគារពិភពលោក ដែលជួយជំរុញអោយសេដ្ឋកិច្ច នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍនានា អោយលូតលាស់ ប្រកបដោយនិរន្តភាព តាមរយៈការផ្តល់ហិរញ្ញប្បទានដល់ ការវិនិយោគផ្នែកឯកជន កៀរគ និងបែងចែកមូលធន ឯកជន នៅក្នុងទីផ្សារហិរញ្ញវត្ថុក្នុងស្រុក និងអន្តរជាតិ ព្រមទាំង ផ្តល់សេវាប្រឹក្សាយោបល់ និង សេវាសម្រាលហានិយភ័យដល់ អាជីវកម្ម និងរដ្ឋាភិបាលនានា ។ នៅក្នុងតំបន់ទន្លេមេគង្គ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ គ្រប់គ្រងកម្មវិធីអភិវឌ្ឍន៏វិស័យ ឯកជនតំបន់ទន្លេមេគង្គ (MPDF) ដែលជាកម្មវិធីផ្តល់សេវា ប្រឹក្សាយោបល់ ធ្វើការនៅក្នុង សាធារណរដ្ឋប្រជាមានិត ប្រជាធិបតេយ្យឡាវ ប្រទេសវៀតណាម និងកម្ពុជា ។ ម្ចាស់ជំនួយ របស់កម្មវិធីអភិវឌ្ឍន៏វិស័យឯកជនតំបន់ទន្លេមេគង្គ នៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិរួមមាន អូស្ត្រាលី កាណាដា សហគមន៏អឺរ៉ុប ហ្វាំងឡង់ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ អៀឡង់ ជប៉ុន នូវែលហ្សេឡង់  ហូឡង់ ណរវែស ស៊ុយអែត និង ស្វីស ។

**www.mpdf.org**